# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និងវិទ្យាសាស្ត្រសេដ្ឋកិច្ច


## សារណាបញ្ចប់ការសិក្សា

# ស្ថាប័នធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា


សាស្ត្រាចារ្យណែនាំ

លោកស្រី **សំណាង ផលដេត**

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖**ប៉ាក សារ៉ាវុធ**

**អោក សុវណ្ណស័ក្ក**



បរិញ្ញាបត្រ **នីតិសាស្ត្រ** ឆ្នាំចូលសិក្សា ២០១៧

ជំនាន់ទី ២១ ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ **អោក សុវណ្ណាស័ក្ក** និង **ប៉ាក សារ៉ាវុធ** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី២១ ផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០១៧-២០២១។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅបំផុត ចំពោះ **លោកឪពុក អោក សំអុល និង អ្នកម្តាយ គឹម ស្រីពៅ** ព្រមទាំង **លោកឪពុក ប៉ាក ម៉ូវ** និង **អ្នកម្តាយ ខ៉ែត ឌីន** ជាទីគោរពស្រឡាញ់នៃកូនដែលលោកបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូន ប្រកបដោយព្រហ្មវិហារធម៌ទាំងបួនគឺ **មេត្តា ករុណា មុទិតា** និង**ឧបេក្ខា** ចំពោះរូបកូនៗតាំងពីតូចដល់ធំពេញវ័យ ដែលរូបលោកទាំងពីរបានលះបង់គ្រប់បែបយ៉ាងនូវកម្លាំងកាយ ចិត្ត ថវិកា ការអប់រំ ទូន្មានប្រៀនប្រដៅ ពោលលោកអ្នកមានគុណទាំង៤គឺជាគ្រូដើមរបស់យើងខ្ញុំទាំងពីរនាក់។ មិនត្រឹមតែប៉ុណ្ណោះ លោកតែងជំរុញលើកទឹកចិត្តដល់កូនៗក្នុងការសិក្សារៀនសូត្រ តាំងពីរូបកូនៗនៅបឋមវ័យរហូតពេលកូនៗបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រប្រកបដោយភាពជោគជ័យ។

ទន្ទឹមនឹងនេះ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង** និង**លោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំបង្ហាត់បង្ហាញ និងផ្តល់ជាចំណេះដឹង ព្រមទាំងបទពិសោធន៍ជាច្រើនដល់យើងខ្ញុំ ទើបយើងខ្ញុំអាចសរសេរសារណាប្រកបដោយជោគជ័យ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅចំពោះលោកស្រីសាស្ត្រាចារ្យ **សំណាង ផលដេត** ជាសាស្ត្រាចារ្យណែនាំ ដែលបានជួយផ្តល់យោបល់ កែតម្រូវ និងជំរុញឲ្យកិច្ចការសរសេរសារណាទទួលបានជោគជ័យ។

ចុងបញ្ចប់នេះ យើងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រសិទ្ធពរជ័យជូនអ្នកមានគុណទាំងទ្វេ **ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ និស្សិត** និងមិត្តអ្នកអានទាំងអស់ឲ្យជួបតែនឹងសេចក្តីសុខ សេចក្តីចម្រើននៅក្នុងជីវិតរៀងទៅ ព្រមទាំងជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល៤ឆ្នាំកន្លង និងបានសិក្សាលើមុខវិជ្ជាជាច្រើនផ្នែកនីតិឯកជន និងនីតិសាធារណៈរួចមក យើងខ្ញុំទាំងពីរបានទទួលចំណេះដឹងទូលំទូលាយលើមុខវិជ្ជាទាំងអស់នោះ ក្រោមការខិតខំប្រឹងប្រែងយកចិត្តទុកដាក់បង្ហាត់បង្រៀនពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យទាំងអស់មកដល់យើងខ្ញុំ។ ដោយការជ្រោមជ្រែង និងការយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្ហាត់បង្រៀនអស់ពីកម្លាំងកាយចិត្តទាំងអស់នេះហើយ ទើបអាចធ្វើឲ្យយើងខ្ញុំឈានមកដល់ការចងក្រងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។ ការរៀបចំសរសេរសារណានេះឡើង ក្នុងគោលដៅដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២១ និងដើម្បីចូលរួមចំណែកក្នុងសង្គម។ បន្ថែមពីនេះការសរសេរសារណា គឺតម្រូវឲ្យយើងមានសមត្ថភាព និងចំណេះដឹងខ្ពស់ក្នុងការចងក្រងវាឡើងមក ព្រោះថាការចងក្រងឯកសារណាមួយឡើងមក យើងជួបប្រទះនឹងការលំបាកច្រើន ទើបយើងអាចទទួលបាននូវលទ្ធផលល្អ។

ការសរសេរសារណាបញ្ចប់ការសិក្សានេះ ដើម្បីរួមចំណែកក្នុងការជួយសង្គមតាមរយៈការស្រាវជ្រាវរបស់យើងខ្ញុំ ដែលបានសម្រេចចិត្តជ្រើសយកប្រធានបទមួយដែលទាក់ទងទៅនឹងផ្នែកនីតិសាធារណៈ គឺមានចំណងជើងថា "**ស្ថាប័នធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**" ដែលជាកម្មវត្ថុនៃការស្រាវជ្រាវនេះ។ មូលហេតុនៃការជ្រើសរើសប្រធានបទនេះគឺមានគោលបំណងឲ្យប្រជាជនកម្ពុជា ក៏ដូចជានិស្សិត បញ្ញវន្តបានយល់ស៊ីជម្រៅនៅក្នុងរចនាសម្ព័ន្ធរួមជាមួយតួនាទីរបស់ស្ថាប័នកំពូលទាំងបី។ នៅក្នុងការស្រាវជ្រាវនេះយើងបានស្វែងរកឯកសារដែលមានតម្លៃគតិយុត្តមកធ្វើជាមូលដ្ឋានក្នុងការស្រាវជ្រាវ។ យើងខ្ញុំសង្ឃឹមថាសារណានេះនឹងអាចជំនួយដល់ការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត និងប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលចង់ស្វែងយល់ទាក់ទងនឹងស្ថាប័នធម្មនុញ្ញ ដែលមានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ហើយទុកជាស្នាដៃដល់អ្នកសិក្សាជំនាន់ក្រោយសិក្សាបន្ថែមឲ្យកាន់តែច្បាស់អំពីអង្គការធម្មនុញ្ញក្នុងព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំសូមអភ័យទោសទុកជាមុននៅរាល់ចំណុចខ្វះខាតមួយចំនួន ដូចជាពាក្យពេចន៍ ខ្លឹមសារ អត្ថន័យ ឬអក្ខរាវិរុទ្ធទាំងឡាយដែលមាននៅក្នុងកិច្ចការស្រាវជ្រាវមួយនេះដោយអចេតនា ហើយក្រុមយើងខ្ញុំនឹងទទួលស្វាគមន៍ជានិច្ចរាល់ការរិះគន់ក្នុងអត្ថន័យស្ថាបនា ជាមួយនឹងគំនិតល្អៗរបស់មិត្តអ្នកអានទាំងអស់ ដើម្បីធ្វើការកែលម្អរ និងធ្វើឲ្យល្អប្រសើរជាងមុន។

# មាតិកា

ទំព័រ

## សេចក្តីផ្តើម


១. លំនាំបញ្ហា ........................................................................................................ ១

២. ចំណោទបញ្ហា ...................................................................................................... ១

៣. គោលបំណងនៃការស្រាវជ្រាវ.................................................................................... ១

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ .......................................................................២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ......................................................................................២

៦. វិធីសាស្ត្រស្រាវជ្រាវ ....................................................................................................២

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .......................................................................................២


## ជំពូកទី១ ស្ថាប័ននីតិប្បញ្ញត្តិ


**១.១ រចនាសម្ព័ន្ធ និងដំណើរប្រព្រឹត្តិទៅរបស់រដ្ឋសភា**.................................................................. ៤

១.១.១ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ........................................................................ ៤

១.១.១.១ សមាសភាពកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា................................................................ ៤

១.១.១.២ មុខងារ និងភារកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា............................................ ៤

១.១.១.៣ តួនាទីប្រធានរដ្ឋសភា ................................................................................... ៥

១.១.១.៤ តួនាទីអនុប្រធាន ........................................................................................៧

១.១.២ គណៈកម្មការជំនាញក្នុងរដ្ឋសភា ..............................................................................៧

១.១.២.១ សមាសភាព កម្មការជំនាញក្នុងរដ្ឋសភា ..................................................................៧

១.១.២.២តួនាទីរបស់គណៈកម្មការជំនាញនានាក្នុងរដ្ឋសភា.........................................................៧

ក. គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា........... ៨

ខ. គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម .......................................... ១០

គ. គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក.................. ១១

ឃ. គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ ...........................................១៣

ង. គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន............. ១៥

ច. គណៈកម្មការនីតិកម្ម និងយុត្តិធម៌ ..................................................................១៧

ឆ. គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍ .............. ១៩

ជ. គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី......២០
ឈ. គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់......២១
ញ. គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ......២១
១.១.៣ លក្ខខណ្ឌនៃការឈរឈ្មោះ និងមិនអាចឈរឈ្មោះជាអ្នកតំណាងរាស្ត្រ......២២
១.១.៣.១ លក្ខខណ្ឌនៃការឈរឈ្មោះ......២២
១.១.៣.២ លក្ខខណ្ឌនៃការមិនអាចឈរឈ្មោះ......២២
១.១.៤ នីតិវិធីក្នុងការចូលកាន់តំណែងរបស់សមាជិកសភា......២៣
១.១.៤.១ ករណីធម្មតា......២៣
១.១.៤.២ ករណីពិសេស......២៣
១.១.៥ សុពលភាពអ្នកតំណាងរាស្ត្រ......២៤
១.១.៦ តួនាទីអ្នកតំណាងរាស្ត្រ និងការបាត់បងសមាជិកភាព......២៤
១.១.៦.១ តួនាទីអ្នកតំណាងរាស្ត្រ......២៤
១.១.៦.២ ការបាត់បង់សមាជិកភាពសភា......២៥
១.១.៧ អភ័យឯកសិទ្ធិសភា......២៥
១.១.៨ អំពីវិសមិតភាព......២៦
១.១.៩ ការប្រជុំនៅក្នុងរដ្ឋសភា......២៦
១.១.៩.១ ការប្រជុំជាសាមញ្ញ......២៦
១.១.៩.២ ការប្រជុំវិសាមញ្ញ......២៦
១.១.៩.៣ ការប្រជុំរាល់ថ្ងៃ......២៦
១.១.៩.៤ កូរ៉ុមនៃការប្រជុំ......២៧
១.១.១០ ការអនុម័តច្បាប់......២៧
១.១.១០.១ ការអនុម័តដោយវិធីលើកដៃ......២៧
១.១.១០.២ ការអនុម័តដោយចំហ......២៨
១.១.១០.៣ ការអនុម័តដោយសម្ងាត់......២៨
១.១.១១ អាណត្តិរបស់រដ្ឋសភា......២៩
១.១.១២ ការគ្រប់គ្រងអគ្គលេខាធិការដ្ឋានរដ្ឋសភា......២៩

១.១.១២.១ រចនាសម្ព័ន្ធដឹកនាំ ........ ២៩

១.១.១២.២ តួនាទីភារកិច្ចរបស់អគ្គលេខាធិការរដ្ឋសភា ........ ៣០

**១.២ រចនាសម្ព័ន្ធ និងដំណើរប្រព្រឹត្តិទៅរបស់ព្រឹទ្ធសភា ........ ៣១**

១.២.១ លក្ខខណ្ឌ និងកិច្ចដំណើការនៃការបោះឆ្នោតជ្រើសតាំងព្រឹទ្ធសភា ........ ៣១

១.២.១.១ លក្ខខណ្ឌក្នុងការឈរឈ្មោះ ........ ៣២

១.២.១.២ លក្ខខណ្ឌមិនអាចឈរឈ្មោះបាន ........ ៣២

១.២.១.៣ លក្ខខណ្ឌឈរឈ្មោះចំពោះអ្នកច្បាប់ហាម ........ ៣២

១.២.២ បុព្វសិទ្ធិសមាជិកភាព និងអភ័យឯកសិទ្ធិសភា ........ ៣៣

១.២.២.១បុព្វសិទ្ធិសមាជិកភាព ........ ៣៣

១.២.២.២ អភ័យឯកសិទ្ធិសភា ........ ៣៣

ក.អភ័យឯកសិទ្ធិដាច់ខាត ........ ៣៣

ខ.អភ័យឯកសិទ្ធិដោយប្រៀប ........ ៣៣

១.២.៣ សមាជិកព្រឹទ្ធសភា ........ ៣៤

១.២.៤ វិសមិតភាពនៃសមាជិកព្រឹទ្ធសភា ........ ៣៥

១.២.៥ ការបាត់បង់សមាជិកភាពព្រឹទ្ធសភា ........ ៣៥

១.២.៦ គណៈកម្មការអចិន្ត្រៃយ៍ព្រឹទ្ធសភា ........ ៣៦

១.២.៦.១ សមាសភាពគណៈកម្មការអចិន្ត្រៃយ៍ព្រឹទ្ធសភា ........ ៣៦

១.២.៦.២ តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ........ ៣៦

១.២.៧ ការបង្កើតគណៈកម្មការជំនាញព្រឹទ្ធសភា ........ ៣៨

១.២.៧.១ សមាសភាពកម្មការជំនាញព្រឹទ្ធសភា ........ ៣៨

១.២.៧.២ តួនាទីកម្មការជំនាញព្រឹទ្ធសភា ........ ៣៩

១.២.៨ ការអនុវត្តអំណាចរបស់ព្រឹទ្ធសភា ........ ៤០

១.២.៨.១ ការផ្តើមធ្វើច្បាប់ ........ ៤០

១.២.៨.២ ការត្រួតពិនិត្យច្បាប់ ........ ៤០

១.២.៨.៣ ការអនុម័តរបស់ព្រឹទ្ធសភា ........ ៤១

១.២.៩ ការប្រជុំ ........ ៤២

១.២.៩.១ ការប្រជុំសាមញ្ញ ........ ៤២

១.២.៩.២ ការប្រជុំវិសាមញ្ញ ........ ៤២

១.២.៩.៣ ការប្រជុំរាល់ថ្ងៃ ........ ៤២
១.២.១០ នីតិវិធីនៃការអនុម័ត ........ ៤៣
១.២.១០.១ ការអនុម័តដោយវិធីលើកដៃ ........ ៤៣
១.២.១០.២ ការអនុម័តដោយបោះឆ្នោតចំហ ........ ៤៣
១.២.១០.៣ ការអនុម័តដោយសម្ងាត់ ........ ៤៤
១.២.១១ អគ្គនាយកដ្ឋានព្រឹទ្ធសភា ........ ៤៤
១.២.១១.១ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ........ ៤៤
១.២.១១.២ អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ........ ៤៤
១.២.១១.៣ អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី ........ ៤៤
១.២.១១.៤ អគ្គនាយកដ្ឋានស្រាវជ្រាវ ........ ៤៥
១.២.១១.៥ អគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ ........ ៤៥
១.២.១២ អគ្គាធិការដ្ឋាន ........ ៤៥

## ជំពូកទី២ ស្ថាប័នរាជរដ្ឋាភិបាល

**២.១ការរៀបចំនិងការប្រព្រឹត្តទៅនៃដំណើរការដឹកនាំរដ្ឋរបស់ស្ថាប័នរាជរដ្ឋាភិបាល** ... ៤៦
**២.២ ការប្រជុំរបស់គណៈរដ្ឋមន្ត្រី** ........ ៤៦
២.២.១ ការប្រជុំលើកទី១ ........ ៤៦
២.២.២ កិច្ចប្រជុំអន្តរក្រសួង ........ ៤៦
២.២.៣ កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ........ ៤៧
**២.៣ តួនាទីគណៈរដ្ឋមន្ត្រី** ........ ៤៧
២.៣.១ តួនាទីសម្របសម្រួលការងារប្រចាំថ្ងៃរបស់គណៈរដ្ឋមន្ត្រី ........ ៤៧
២.៣.២ តួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាល ........ ៤៨
២.៣.៣ តួនាទីគ្រប់គ្រង និងចាត់ចែងការងាររបស់ទីស្តីការគណៈរដ្ឋមន្ត្រី ........ ៤៩
**២.៤ សមត្ថកិច្ចរបស់នាយករដ្ឋមន្ត្រី និងសមាជិករដ្ឋាភិបាល** ........ ៥០
២.៤.១ នាយករដ្ឋមន្ត្រី ........ ៥០
២.៤.២ តួនាទី និងភារកិច្ចឧបនាយករដ្ឋមន្ត្រី ........ ៥២
២.៤.៣ តួនាទី និងភារកិច្ចទេសរដ្ឋមន្ត្រី ........ ៥២
២.៤.៤ តួនាទី និងភារកិច្ចរដ្ឋមន្ត្រី ........ ៥២

២.៤.៥ តួនាទី និងភារកិច្ចរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ..... ៥៣
២.៤.៦ តួនាទី និងភារកិច្ចរដ្ឋលេខាធិការ ..... ៥៣
២.៤.៧ តួនាទី និងភារកិច្ចអនុរដ្ឋលេខាធិការ ..... ៥៣
**២.៥ ការរំលាយរាជរដ្ឋាភិបាល** ..... ៥៤

## ជំពូកទី៣ ស្ថាប័នតុលាការ

**៣.១ សាលាដំបូងជម្រះក្តីថ្នាក់ទី១** ..... ៥៥
៣.១.១ សាលាដំបូង ..... ៥៥
៣.១.១.១ អង្គការលេខសាលាដំបូង ..... ៥៥
៣.១.១.២ សមត្ថកិច្ចរបស់សាលាដំបូង ..... ៥៥
៣.១.១.២ នីតិវិធីក្នុងពេលសវនាការរបស់សាលាដំបូង ..... ៥៦
៣.១.២ តុលាការយោធា ..... ៥៦
**៣.២ សាលាជម្រះក្តីថ្នាក់ទី២** ..... ៥៦
៣.២.១. អង្គការលេខសាលាឧទ្ធរណ៍ ..... ៥៧
៣.២.២ សមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ ..... ៥៧
៣.២.៣ នីតិវិធីក្នុងពេលសវនាការរបស់សាលាឧទ្ធរណ៍ ..... ៥៧
**៣.៣ តុលាការកំពូល** ..... ៥៧
៣.៣.១. អង្គការលេខភាព ..... ៥៨
៣.៣.២ សមត្ថកិច្ចរបស់តុលាការកំពូល ..... ៥៨
៣.៣.២.១ នីតិវិធីក្នុងពេលសវនាការលើអង្គច្បាប់ ..... ៥៨
៣.៣.២.២ នីតិវិធីក្នុងពេលសវនាការលើអង្គហេតុ និងអង្គច្បាប់ ..... ៥៨
**៣.៤ ការចេញសេចក្តីសម្រេចរបស់សាលាជម្រះក្តីថ្នាក់ទី១ និងថ្នាក់ទី២** ..... ៥៩
៣.៤.១ រឿងក្តីព្រហ្មទណ្ឌ ..... ៥៩
៣.៤.២ រឿងក្តីរដ្ឋប្បវេណី ..... ៦១
**៣.៥ ស្ថាប័នអយ្យការ និងមហាអយ្យការ** ..... ៦១
៣.៥.១ អយ្យការអមតុលាការដំបូង ..... ៦១
៣.៥.១.១ សមាសភាព អយ្យការអមតុលាការដំបូង ..... ៦១
៣.៥.១.២ មុខងារ និងភារកិច្ចអយ្យការអមតុលាការដំបូង ..... ៦២
៣.៥.២ មហាអយ្យការអមសាលាឧទ្ធរណ៍ ..... ៦៣

៣.៤.២.១ សមាសភាពមហាអយ្យការអមសាលាឧទ្ធរណ៍ ...... ៦៣
៣.៥.២.២ មុខងារ និងភារកិច្ច ...... ៦៣
៣.៥.៣ មហាអយ្យការអមតុលាការកំពូល ...... ៦៣
៣.៥.៣.១ សមាសភាពមហាអយ្យការអមតុលាការកំពូល ...... ៦៣
៣.៥.៣.២ មុខងារ និងភារកិច្ច មហាអយ្យការអមតុលាការកំពូល ...... ៦៤
**៣.៦.ការដាក់ទិន័យចំពោះអ្នកវិជ្ជាជីវៈក្នុងការប្រព្រឹត្តកំហុស** ...... ៦៤
៣.៦.១ ទណ្ឌកម្មទី១ ...... ៦៤
៣.៦.២ ទណ្ឌកម្មទី២ ...... ៦៤
**៣.៧. ឯករាជ្យភាពនៃស្ថាប័នតុលាការ** ...... ៦៥
៣.៧.១ ការកំណត់ដោយច្បាប់ ...... ៦៥
៣.៧.២ លក្ខណៈសម្បត្តិនៃចៅក្រម ...... ៦៥
៣.៧.១.១ ការមានម្ចាស់ការក្នុងការកាត់ក្តី ...... ៦៥
៣.៧.១.២ ការមិនមានភាពលម្អៀងនៃចៅក្រម ...... ៦៥
៣.៧.១.៣ មិនស្ថិតក្រោមឥទ្ធិពលនៃមជ្ឈដ្ឋានដទៃ ...... ៦៦
៣.៧.១.៤ ត្រូវជៀសវាងឲ្យផុតនូវអានាគតិទាំងបួន ...... ៦៦
៣.៧.១.៥ ប្រកាន់ខ្ជាប់នូវសីលធម៌ និងគុណធម៌ ...... ៦៦

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ...... ៦៧
២.ការផ្តល់អនុសាសន៍ ...... ៦៧
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

នៅក្នុងសាកលលោកធម្មជាតិបង្កើតមនុស្សមកតែងមានការចងក្រងគ្នាជាសម្ព័ន្ធមនុស្សជាគ្រួសារ និងប្រមូលផ្តុំគ្នាជាច្រើនគ្រួសារបង្កើតបានជាសង្គមមនុស្សប្រកដដោយភាពសម្បូរបែប ក្នុងការរស់នៅដោយវិវត្តតាមការការអភិវឌ្ឍរបស់ចក្រវាល។ លុះពេលដែលពិភពលោកចាប់ផ្តើមស៊ីវិល័យ ការរស់មនុស្សនៅរមែងមានតម្រូវការជាច្រើនរួមមាន តម្រូវការម្ហូបអាហារ សំលៀកបំពាក់ សិទ្ធសេរីភាព និងតម្រូវការជាច្រើនទៀត។ ទន្ទឹមនឹងការរីកចម្រើនផ្នែកធនធានមនុស្ស ក្នុងនោះគេឃើញរបបនៃការដឹកនាំរដ្ឋក៏កាន់តែមានការវិវត្ត។

ជាក់ស្តែកដូចនៅក្នុងប្រទេសកម្ពុជាយើង មានការផ្លាស់ប្តូររបបដឹកនាំរដ្ឋ ជាហូរហែរមកតាំងពីទទួលបានឯករាជ្យពីបារាំង នាឆ្នាំ១៩៦៣មក។ ក្រោមការប្រយុទ្ធដណ្តើមអំណាចគ្នារវាងអ្នកនយោបាយ សង្គមកម្ពុជាចាប់ផ្តើមមានឯកាភាពជាតិ ដោយការរួបរួមគ្នាក្នុងការបង្កើររដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ដែលជាសមិទ្ធិផលនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ នាំទៅដល់ការបោះឆ្នោត នាខែឧសភា ឆ្នាំ១៩៩៣ ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ ដើម្បីបង្កើតសភាធម្មនុញ្ញមួយនៃប្រទេសកម្ពុជា។ ទន្ទឹមនឹងនោះដែរ តាមស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសក៏បានកំណត់យ៉ាងច្បាស់លាស់ផងដែរ នូវបណ្តាគោលការណ៍មួយចំនួនសម្រាប់អនាគតរដ្ឋធម្មនុញ្ញថ្មីរបស់ប្រទេសកម្ពុជា។ ទន្ទឹមនឹងការមានឯកភាពជាតិនៅកម្ពុជាដោយផ្អែកតាមខ្លឹមសារនៃរដ្ឋធម្មនុញ្ញ នៅមានផលវិបាកមួយចំនួក្នុងក្នុងការកំណត់អំពីដែនអំណាចធំៗទាំង៣ដែលបញ្ញត្តិនៅក្នុងច្បាប់កំពូលនេះ។

អាស្រ័យហេតុនេះ ទើបក្រុមយើងខ្ញុំលើកយកប្រធានបទដែលទាក់ទងទៅនឹង "ស្ថាប័នធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា"។ ដោយសារប្រធានបទនេះអាចឲ្យមិត្តនិស្សិត និងមហាជនគ្រប់ស្រទាប់វណ្ណៈ បានយល់កាន់តែច្បាស់អំពីភាពលម្អិតនៃស្ថាប័នធំៗទាំង៣នៃប្រទេសកម្ពុជា។

## ២. ចំណោទបញ្ហា

ដើម្បីឲ្យប្រទេសជាតិមានស្ថេរភាព និងការអភិវឌ្ឍ ស្របតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងធានាបាននូវការអនុវត្តភារកិច្ចរបស់មេដឹកនាំនៃស្ថាប័នធំៗទាំងបី តើមានលក្ខខណ្ឌអ្វីខ្លះក្នុងការបង្កើតស្ថាប័នទាំងនោះ? តើរបៀបរបបធ្វើការរបស់មន្ត្រីទាំងនោះប្រព្រឹត្តទៅយ៉ាងដូចម្តេច? ហើយស្របតាមរដ្ឋធម្មនុញ្ញដែរឬទេ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៅក្នុងការស្រោជ្រានេះ គឺដើម្បីឲ្យការដឹកនាំរដ្ឋប្រកដដោយតម្លាភាព ឯករាជ្យនៃអំណាចទាំង៣ ហើយម្យ៉ាងទៀតចង់ការអន្តរគ្របស់សមាជិករដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភានិងអ្នកវិជ្ជាជីវៈក្នុងការអនុវត្តតួនាទី ដោយផ្តល់ភាពកក់ក្តៅដល់ប្រពលរដ្ឋដែលបានបោះឆ្នោតជូនពួកគាត់ ហើយដាក់

ចិត្តបម្រើរាស្ត្រយ៉ាងពិតប្រាកដ ជាជាងគិតតែរឿងតំណែងបុណ្យស័ក្តិ និងផលប្រយោជន៍ផ្ទាល់ខ្លួន។

ការចូលរួមអនុវត្តពីស្ថាប័នដែលចំណុះឲ្យអំណាចទាំង៣នេះ គឺជាធាតុចាំបាច់បំផុត ដើម្បីឲ្យសង្គមជាតិអភិវឌ្ឍ និងរីកចម្រើនប្រកបដោយចីរភាព។ ដូចនេះការការប្រព្រឹត្តរបស់មន្ត្រីនៃអំណាចទាំងនោះ គឺមានឥទ្ធិពលណាស់សម្រាប់ការធានាដល់សុខមាលភាពក្នុងការរស់នៅរបស់ប្រជាជន និងប្រទេសជាតិមានកិត្តិយសក្នុងនាមជាប្រទេសដែលមានអធិបតេយ្យភាពដែនដី និងការគោរពសិទ្ធិមនុស្សជាសកល។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដោយសារស្ថាប័នធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មានច្រើន ដូចនេះក្រុមយើងខ្ញុំសូមលើកយកស្ថាប័នចំនួនបីតែប៉ុណ្ណោះមកបកស្រាយនៅក្នុងសារណាបទមួយនេះ ដោយចាប់ផ្តើមពីស្ថាប័ននីតិប្បញ្ញត្តិ បន្ទាប់មកទៀតស្ថាប័នរាជរដ្ឋាភិបាល និងចុងក្រោយគឺស្ថាប័នតុលាការ។

រីឯដែនកំណត់នៃការសិក្សាស្ថិតក្រោមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៦ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ២០១៤ ច្បាប់ស្តីពីច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ឆ្នាំ២០១៥ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ២០១៨។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈប្រយោជន៍នៃប្រធានបទនេះ គឺដើម្បីឲ្យមិត្តនិស្សិតបញ្ញវន្តទាំងឡាយ ក៏ដូចជាប្រជាពលរដ្ឋបានយល់ដឹងឲ្យកាន់តែច្បាស់អំពីការដែលអាចបង្កើតបានជារដ្ឋាភិបាល ឬក៏ការដឹកនាំនៅក្នុងដំណើរការនៃអង្គការនីតិប្បញ្ញត្តិដែលមានស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា។ ម្យ៉ាងវិញទៀតក៏បានដឹងអំពីរចនាសម្ព័ន្ធរបស់ស្ថាប័នកំពូលទាំងបី ដែលជាអំណាចធំបំផុតនៅក្នុងប្រទេសកម្ពុជា ហើយអំណាចទាំងនេះគឺជាអំណាចដែលបែងចែកដាច់ពីគ្នា។

ជាងនេះទៅទៀត ការស្រាវជ្រាវរៀបចំក្រងអំពីប្រធានបទនេះឡើង ដើម្បីរួមចំណែកក្នុងពង្រីកការយល់ដឹងទាក់ទងនឹងវិស័យសាធារណៈនៅព្រះរាជាកម្ពុជាកាន់តែប្រសើរឡើង។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ប្រធានបទខាងលើនេះ យើងខ្ញុំបានខិតខំស្រាវជ្រាវ ដើម្បីប្រមូលឯកសារច្បាប់ ក្នុងនោះច្បាប់រដ្ឋធម្មនុញ្ញជាសំខាន់ក្នុងសារណានេះរួមទាំងច្បាប់ពាក់ព័ន្ធមួយចំនួន តាមបណ្តាញអ៊ីនធើណិត និងទទួលបានពីការផ្តល់ឲ្យដោយសាស្ត្រាចារ្យណែនាំ ក៏ដូចជាលោក-លោកស្រីសាស្ត្រាចារ្យជាច្រើន ដើម្បីចងក្រងបង្កើតស្នាដៃនេះ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងប្រធានបទ "ស្ថាប័នធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា" យើងខ្ញុំបានបែងចែកជាបីជំពូក ដូចខាងក្រោម៖

-ជំពូកទី១ ស្ថាប័ននីតិប្បញ្ញត្តិ

-ជំពូកទី២ ស្ថាប័នរាជរដ្ឋាភិបាល

-ជំពូកទី៣ ស្ថាប័នតុលាការ

# ជំពូកទី១ ស្ថាប័ននីតិប្បញ្ញត្តិ

អំណាចនីតិប្បញ្ញត្តិរបស់ប្រទេសកម្ពុជាគឺជាអំណាចទ្វិសភា ដែលរួមមានស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា។ ហើយស្ថាប័នទាំងពីរនេះមានអំណាចផ្ទាល់រៀងៗខ្លួនដែលមានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ។ ដូច្នេះយើងនឹងធ្វើការសិក្សាទៅលើរចនាសម្ព័ន្ធ ក៏ដូចជាដំណើរការប្រព្រឹត្តទៅរបស់ស្ថាប័ននីតិប្បញ្ញត្តិទាំងពីរនេះ។

## ១.១ រចនាសម្ព័ន្ធ និងដំណើរប្រព្រឹត្តិទៅរបស់រដ្ឋសភា

រចនាសម្ព័ន្ធរបស់រដ្ឋសភារួមមាន៖

- ប្រធានរដ្ឋសភា ១រូប
- អនុប្រធានរដ្ឋសភា ២រូប
- សមាជិកតំណាងរាស្ត្រ១២៣រូបមកពីរាជធានី និងខេត្ត
- អគ្គលេខាធិការ១រូប និងអគ្គលេខាធិការរងជាច្រើនរូប
- គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា
- គណៈកម្មការជំនាញរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា។

### ១.១.១ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

#### ១.១.១.១ សមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាមានសភាពដូចខាងក្រោម៖

- ប្រធានរដ្ឋសភា ១ រូប ជាប្រធានគណៈកម្មាធិការ
- អនុប្រធានរដ្ឋសភាទី១ ជាអនុប្រធានទី១គណៈកម្មាធិការ
- អនុប្រធានទី២ ជាអនុប្រធានទី២គណៈកម្មាធិការ
- ប្រធាគណៈកម្មការជំនាញទាំង១០នៃរដ្ឋសភា ជាសមាជិកគណៈកម្មាធិការ។

#### ១.១.១.២ មុខងារ និងសមាសភាព នៃគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា មានតួនាទីសំខាន់ណាស់ ក្នុងការធានា នូវរាល់ដំណើរការប្រព្រឹត្តទៅរបស់រដ្ឋសភា។តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភារួមមាន៖

-ចាត់ចែងការងាររបស់រដ្ឋសភានៅចន្លោះសម័យប្រជុំ។

- កោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ប្រសិនបើមានសំណូមពរ ពីព្រះមហាក្សត្រ ឬមានសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិករដ្ឋសភាចំនួន១ ភាគ៣ យ៉ាងតិច។[1]

[1] មាត្រា៨៣, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

- រាយការណ៍អំពីសកម្មភាពនានារបស់រដ្ឋសភា នូវគ្រប់ចន្លោះសម័យប្រជុំ រដ្ឋសភានៅពេលបើកសម័យប្រជុំនីមួយៗ។

- កំណត់កាលបរិច្ឆេទ និងរបៀបវារៈនៃសម័យប្រជុំនីមួយៗរបស់រដ្ឋសភា។

- គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ជាអ្នករៀបចំរបៀបវារៈ ក្នុងការកំណត់ពេលប្រជុំនីមួយៗ។ មុនផុតពេលប្រជុំនីមួយៗ ប្រធានត្រូវអានរបៀបវារៈ សម្រាប់ពេលប្រជុំបន្តទៅទៀត។ នៅក្នុងរបៀបវារៈនេះ ត្រូវមានសេចក្តីជាលំដាប់មុនក្រោយ ដូចតទៅ៖

១-បញ្ហាទាំងឡាយដែលរដ្ឋសភាបានសម្រេចថាទុកជាការប្រញាប់

២-បញ្ហាទាំងឡាយដែលរាជរដ្ឋាភិបាលជូនមករដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវបញ្ជូនសេចក្តីស្នើសុំទាំងឡាយជូនរដ្ឋាភិបាល ទៅគណៈកម្មការនានា តាមមុខជំនាញឲ្យត្រួតពិនិត្យ។ កាលបើបានពិនិត្យរួចហើយ ប្រធាននៃគណៈកម្មការជំនាញត្រូវនាំយកយោបល់របស់ គណៈកម្មការមកជម្រាបជូនរដ្ឋសភាឲ្យបានជ្រាប។

-គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ជាអ្នកកំណត់នូវសេចក្តីស្នើថវិការបស់រដ្ឋសភាហើយត្រូវបញ្ជូនទៅក្រសួងមានសមត្ថកិច្ច ដើម្បីបញ្ចូលក្នុងគម្រោងថវិកាជាតិ។

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាជាអ្នកពិនិត្យ និងសម្រេចរបាយការណ៍ទូទាត់ចំណាយថវិការបស់រដ្ឋសភានៅរាល់ដំណាច់ឆ្នាំ ហើយត្រូវបញ្ជូនទៅក្រសួងមានសមត្ថកិច្ច ដើម្បីរៀបចំបញ្ចូលក្នុងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ។

- គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាជាអ្នកដាក់ទណ្ឌកម្ម និងវិន័យលើសមាជិករដ្ឋសភាដោយស្វ័យប្រវត្តិ កាលបើបានដឹងច្បាស់ថាមូលហេតុដែលសមាជិករដ្ឋសភាខកខានមកប្រជុំនោះ មិនអាចយកជាការបានឡើយ លែងតែករណីដែល បានទទួលពាក្យតវ៉ា សមហេតុសមផលអំពីសាមីខ្លួន ក្នុងពេលប្រជុំពេញអង្គ។

- គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវរៀបចំរបបប្រាក់បំណាច់ របបធានា រ៉ាប់រងសង្គមរបបបេសកកម្ម និងលក្ខខណ្ឌធ្វើការងាររបស់តំណាងរាស្ត្រ។

- គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ជាអ្នកលើកសំណើជូនអង្គសភា ដើម្បីធ្វើការពិនិត្យ និងសម្រេចលើសេចក្តីស្នើសុំ ចោទប្រកាន់ ការចាប់ខ្លួន ការឃុំខ្លួន សមាជិករដ្ឋសភាណាមួយដើម្បីអនុម័តសម្រេច។

- ដាក់ជូនអង្គសភាដើម្បីពិនិត្យ និងសម្រេចអំពីអភ័យឯកសិទ្ធិតំណាងរាស្ត្រ។

- ការពារផលប្រយោជន៍ និងអភ័យឯកសិទ្ធិតំណាងរាស្ត្រ។

- ធានាក្នុងការផ្តល់គ្រឿងឥស្សរិយយសជូនដល់សមាជិករដ្ឋសភា។

- គណៈកម្មាធិការ អចិន្ត្រៃយ៍រដ្ឋសភា ជាអ្នកបង្កើតគណៈកម្មការ ដើម្បីបម្រើការងារចាំបាច់ឲ្យរដ្ឋសភា។

**១.១.១.៣ តួនាទីប្រធានរដ្ឋសភា**

ប្រធានរដ្ឋសភាមានតួនាទីសំខាន់ៗដូចតទៅ៖

- ដឹកនាំអង្គប្រជុំរបស់រដ្ឋសភា ទទួលអាញ្ញត្តិច្បាប់ និងសេចក្តីសម្រេចចិត្តទាំងឡាយ ដែលរដ្ឋសភាបានអនុម័ត រ៉ាប់រងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។

- ការពារកិត្តិយស និងសិទ្ធិរបស់រដ្ឋសភា។

- ធានាការប្រព្រឹត្តិទៅនៃរដ្ឋសភាឲ្យបានត្រឹមត្រូវស្របតាមរដ្ឋធម្មនុញ្ញ។

- ជាអ្នកចេញសេចក្តីសម្រេចនានាស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃអគ្គលេខាធិការដ្ឋាន។

- ចាត់ចែងការពិភាក្សា ហើយត្រូវចុះហត្ថលេខា លើកំណត់ហេតុនៃការប្រជុំរបស់រដ្ឋសភា។

- ជាអ្នកគ្រប់គ្រងយន្តការនានា និងលើកស្ទួយការងាររបស់រដ្ឋសភា។

- កោះប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដើម្បីប្រជុំពិភាក្សា និងធ្វើការអនុម័តទៅលើបញ្ហាផ្សេងៗ។

- បើក និងលើកពេលប្រជុំនៃរដ្ឋសភា មុនពេលចាប់ផ្តើមប្រជុំ លេខាធិការរដ្ឋសភា ត្រូវជម្រាបជូនអង្គសភាអំពីចំនួនកូរ៉ុម ប្រសិនបើកូរ៉ុមគ្រប់ចំនួន អង្គសភាអាចដំណើរការប្រជុំ ដោយប្រធានរដ្ឋសភាជាអ្នកប្រកាសបើកប្រជុំ។ ករណីចំនួនកូរ៉ុមហើយចំនួនកូរ៉ុមមិនគ្រប់នោះ ប្រធានរដ្ឋសភាត្រូវប្រកាសផ្អាកការប្រជុំ បើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល១៥នាទី បន្ទាប់ពីហួសពេលកំណត់នៃការចាប់ផ្តើមប្រជុំ។[2]

- សម្រេចលើកពេលប្រជុំបាន[3] បើសិនយល់ឃើញថាមានប្រយោជន៍ ឬជាការចាំបាច់ ឬបើមានអ្នកតំណាងរាស្ត្រ១០នាក់យ៉ាងតិច ស្នើសុំដើម្បីឲ្យលើកពេលប្រជុំ។

- តែងតាំងបុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋាន ហើយការតែងតាំងនេះត្រូវស្របទៅតាមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣[4]។

- ជាអ្នកស្នើសុំតែងតាំងអគ្គលេខាធិការធិការរង ក្រោយពីបានពិគ្រោះយោបល់ជាមួយអនុប្រធានទី១ និងអនុប្រធានទី២ នៃរដ្ឋសភា[5]។

- ចុះហត្ថលេខាលើកំណត់ហេតុពិស្តារ នៅពេលចប់សម័យប្រជុំរដ្ឋសភាមួយលើកៗ ដែលមានរយៈពេល៣ខែយ៉ាងតិច។

- ជាអ្នកសម្រេចកិច្ចការទាំងឡាយក្នុង ដំណើរការប្រព្រឹត្តរបស់រដ្ឋភិបាល ដោយផ្អែកលើច្បាប់គោលសំខាន់ៗពីរ គឺ រដ្ឋធម្មនុញ្ញ និងការប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា។

- ការពារមិនឲ្យមានមហន្តរាយខាងក្នុងក្តី ឬមកពីខាងក្រៅក្តី ដែលកើតមានឡើងដល់រដ្ឋសភា ដើម្បីធ្វើឲ្យសម្រេចកិច្ចនេះ ព្រមទាំងអាចប្រើកម្លាំងនគរបាល ឬសុំអន្តរាគមន៍ពីកម្លាំងកងទ័ពបាន។

---

[2] ប្រការ៤៧ថ្មី(បួន), បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[3] ប្រការ៥៤, បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[4] ប្រការ១៧ថ្មី, បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[5] ប្រការ១៦, បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

- មានសិទ្ធិបញ្ជាឲ្យបណ្តេញចេញភ្លាមៗបាន ក្នុងករណីដែលជនណាម្នាក់ធ្វើឲ្យរំខានដល់ការពិភាក្សា នៅពេលប្រជុំរដ្ឋសភា ដើម្បីរក្សាការពារសណ្តាប់ធ្នាប់ក្នុងរដ្ឋសភាឲ្យបានល្អ។

- ជាអ្នកអនុញ្ញាតច្បាប់ជូន ឬមិនអនុញ្ញាតច្បាប់ជូនសមាជិករដ្ឋសភាអាស្រ័យតាមកាលៈទេសៈ។

- តំណាងឲ្យរដ្ឋសភា ក្នុងការធ្វើទំនាក់ទំនងបញ្ហាផ្សេងៗ ជាមួយព្រះមហាក្សត្រ និងអាជ្ញាធរសាធារណៈ។[6]

នៅពេលប្រធានរដ្ឋសភាមានធុរៈមិនអាចបំពេញមុខងារបានដោយហេតុមកពីមានជំងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅបរទេស អនុប្រធានរដ្ឋសភាមួយរូបត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស[7]។ បន្ថែមពីនេះប្រសិនបើករណី ប្រធានរដ្ឋសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធានថ្មី។

#### ១.១.១.៤ តួនាទីអនុប្រធាន

អនុប្រធានទាំងពីរជួយធ្វើការប្រធានទៅតាមការបែងចែកភារកិច្ចពីប្រធាន។ កាលបើប្រធានអវត្តមានដោយមកធ្វើការពុំបាន អនុប្រធានធ្វើការជំនួសប្រធាន ក្នុងឋានៈជាប្រធានស្តីទីតាមរយៈលិខិតផ្ទេរសិទ្ធិ។ក្នុងករណីដែលប្រធានរដ្ឋសភាមានធុរៈមិនអាចបំពេញមុខងារបានហេតុមកពីមានជំងឺ ឬបំពេញមុខងារ ជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជា បំពេញបេសកកម្មនៅបរទេស អនុប្រធានរដ្ឋសភាមួយរូបត្រូវទទួល ចែងការងារជំនួស។ ក្នុងករណីដែល អនុប្រធានរដ្ឋសភាលាលែងពីមុខ រដ្ឋសភារបោះឆ្នោតជ្រើសតាំង អនុប្រធាន ឬជាព្រះរាជានុសិទ្ធិ។ ក្នុងករណីដែលអនុប្រធានរដ្ឋសភា លាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងអនុប្រធានថ្មី។

### ១.១.២ គណៈកម្មការជំនាញរបស់រដ្ឋសភា

ត្រូវរៀបរាប់ប្រាប់គេផង ថាគណៈកម្មការជំនាញមានចំនួន៩ ទេមុនឆ្នាំ ក្រោយមកបន្ថែម១គណៈកម្មការទៀតនៅខែវិច្ឆិកា ឆ្នាំ២០១៤ បន្ទាប់ពីមានការព្រមព្រៀងគ្នារវាងគណៈបក្សប្រជាជន និងគណៈបក្សសង្គ្រោះជាតិ។

#### ១.១.២.១ សមាសភាពកម្មការជំនាញក្នុងរដ្ឋសភា

នៅក្នុងគណៈកម្មការជំនាញត្រូវធ្វើឡើងដោយការបោះឆ្នោត។សមាសភាពទាំងនោះរួមមានៈ

- ប្រធានគណៈកម្មការ ១រូប
- អនុប្រធានគណៈកម្មការ ១រូប
- លេខាធិការ ១រូប
- សមាជិកចំនួន ៦រូប។

#### ១.១.២.២ តួនាទីរបស់គណៈកម្មការជំនាញនានាក្នុងរដ្ឋសភា

បច្ចុប្បន្ននេះ គណៈកម្មការជំនាញរបស់រដ្ឋសភាមានទាំងអស់១០គណៈកម្មការ។

[6] ប្រការ៨ថ្មី, បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[7] មាត្រា៨៧, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

**ក. គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា**

គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភានៃរដ្ឋសភា ហៅកាត់ថា គណៈកម្មការទី១ សរសេរកាត់ថា គ.១ មានភារកិច្ចរួម ដូចតទៅៈ

-នាំយកយោបល់របស់គណៈកម្មការជម្រាបជូនរដ្ឋសភាក្នុងសម័យប្រជុំពេញអង្គ អំពីការពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ចូលរួម និងរៀបចំសិក្ខាសាលា ឬកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈជាមួយ អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ។ល ។

- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយគណៈកម្មការសភា នៃបណ្តាប្រទេស ដើម្បីពង្រឹង និងផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមកផ្នែកនីតិប្បញ្ញត្តិ

- ប្រធាន ឬប្រធានស្តីទីមានភារៈចូលរួមក្នុងការប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា តាមការអញ្ជើញរបស់ប្រធានរដ្ឋសភា។

- សមាជិកគណៈកម្មការមានភារៈចូលរួមក្នុងក្រុមមិត្តភាពសភា ឬអង្គការអន្តរជាតិទៅតាមសេចក្តីសម្រេចរបស់ប្រធានរដ្ឋសភា។

- ពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានប្រគល់ជូន។ ម្យ៉ាងវិញទៀតគណៈកម្មនេះបំពេញការងារផ្សេងៗទៀតដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភានិងប្រធានរដ្ឋសភាប្រគល់ជូន និងរបៀបរបបធ្វើការងារ និងការបែងចែកភារកិច្ចទទួលខុសត្រូវរបស់សមាជិក គណៈកម្មការនីមួយៗ ត្រូវកំណត់ដោយប្រធានគណៈកម្មការ ។ ក្រៅពីភារកិច្ចរួម គណៈកម្មការទី១ មានភារកិច្ចស្នូលសំខាន់ៗដូចខាងក្រោមៈ

១- ពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ពាក់ព័ន្ធនឹងវិស័យសិទ្ធិមនុស្ស ការងារទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ការអង្កេត និងកិច្ចការទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងកិច្ចការផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានប្រគល់ជូន

- ទំនាក់ទំនងជាមួយគណៈកម្មការនានារបស់រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ ដើម្បីស្វែងយល់អំពីគំនិតតាក់តែងសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ និងបញ្ហានានាពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់គណៈកម្មការ

- អញ្ជើញតំណាងរាជរដ្ឋាភិបាល ឬអ្នកស្នើច្បាប់ ដែលជាម្ចាស់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានានាដើម្បីចូលមកបំភ្លឺជូនគណៈកម្មការ។

- សហការក្នុងការពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និសេចក្តីស្នើច្បាប់ជាមួយគណៈកម្មការនានា តាមការប្រគល់ភារកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

- ចូលរួមពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់នានា តាមការអញ្ជើញរបស់គណៈកម្មការ

ជំនាញ និងគណៈកម្មការពិសេសចំពោះកិច្ច។

- ចងក្រងឯកសារដែលពាក់ព័ន្ធនឹងវិស័យទទួលបន្ទុកទាំងឯកសារជាតិ និងឯកសាររបស់បណ្ដាប្រទេសដែលមានការអភិវឌ្ឍកម្រិតប្រហាក់ប្រហែល ឬខ្ពស់ជាង ដើម្បីធ្វើទំនាក់ទំនងផ្លាស់ប្ដូរបទពិសោធន៍ និងជំរុញកិច្ចសហប្រតិបត្តិការជាផលប្រយោជន៍ជាតិ។

២- តាមដាន អង្កេតការគោរពសិទ្ធិមនុស្សនៅកម្ពុជាឲ្យបានសមស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ព្រមទាំងរាល់លិខិតបទដ្ឋានអន្តរជាតិ ដែលពាក់ព័ន្ធ វិស័យសិទ្ធិមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់។

- ចុះបំពេញសកម្មភាពនៅតាមក្រសួង ស្ថាប័ន និងមូលដ្ឋាននានា ដើម្បីសួរសុខទុក្ខប្រជាពលរដ្ឋ និងតាមដានការអនុវត្តច្បាប់ ព្រមទាំងស្វែងយល់ពីការរីកចម្រើនក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល រួចធ្វើរបាយការណ៍ ដាក់ជូនប្រធានរដ្ឋសភា។

- ទទួលពាក្យបណ្ដឹងទូទៅពីប្រជាពលរដ្ឋ អ្នកតំណាងក្រុមការងារ និងសហគមន៍នានា។

- ពិនិត្យពាក្យបណ្ដឹង ធ្វើការសម្របសម្រួល ឬអន្តរាគមន៍ទៅអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយជូនម្ចាស់បណ្ដឹង តាមរយៈប្រធានរដ្ឋសភា។

- ចំពោះពាក្យបណាញតឹងទាំងឡាយណាដែលមានលក្ខណៈមិនត្រឹមត្រូវតាមច្បាប់ ឬអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធបាននិងកំពុងដោះស្រាយនោះ គណៈកម្មការនឹងជូនដំណឹងនេះទៅម្ចាស់បណ្ដឹងវិញ។

៣- ចុះតាមដានលើពាក្យបណ្ដឹងដែលគណៈកម្មការបានអន្តរាគមន៍ និងបញ្ហា ដែលប៉ះពាល់សិទ្ធិប្រជាពលរដ្ឋ ព្រមទាំងសំណូមពររបស់ប្រជាពលរដ្ឋនៅ តាមមូលដ្ឋាននានា រួចធ្វើរបាយការណ៍ជូនប្រធានរដ្ឋសភា ។

- ចូលរួមការពារគាំទ្រ និងជំរុញការលើកស្ទួយសិទ្ធិពលរដ្ឋគ្រប់រូបឲ្យមាន សេចក្ដីថ្លៃថ្នូរ មានសិទ្ធិស្មើៗគ្នា ដើម្បីធានាសិទ្ធិជាមូលដ្ឋានក្នុងជីវភាពរស់ នៅប្រកបដោយសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងសង្គម ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ។

- ពិគ្រោះយោបល់ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងស្ដីពី សិទ្ធិសេរីភាព សេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ យន្តការការពារសិទ្ធិមនុស្ស សន្ធិសញ្ញា អនុសញ្ញា កតិកសញ្ញា និងបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ ស្របតាមសេចក្ដី ប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ព្រមទាំងធ្វើទំនាក់ទំនងជាមួយអង្គការជាតិ អង្គការអន្តរជាតិ និងវិស័យឯកជន ដើម្បីស្វែងយល់ពីបញ្ហានានាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ គណៈកម្មការជាពិសេសពង្រឹង និងពង្រីកទំនាក់ទំនងសហប្រតិបត្តិការអន្តរជាតិជាមួយ ដៃគូអភិវឌ្ឍន៍នានា សភាបណ្ដាប្រទេសនានា។

ចូលរួមក្នុងការអប់រំ ណែនាំ បញ្ជ្រាបការយល់ដឹងពីច្បាប់ពាក់ព័ន្ធសមត្ថកិច្ច នៅតាមមូលដ្ឋាន ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់រូបបានយល់ដឹងកាន់តែប្រសើរ រៀបចំធ្វើសិក្ខាសាលា ឬសហការជាមួយអង្គការសង្គមស៊ីវិល

**ខ.គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម**

គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ហៅកាត់ថា គណៈកម្មការទី២ សរសេរកាត់ថា គ.២ មានភារកិច្ចរួម ដូចតទៅ៖

- នាំយកយោបល់របស់គណៈកម្មការជម្រាបជូនរដ្ឋសភាក្នុងសម័យប្រជុំពេញអង្គអំពីការពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់។

- ចូលរួម និងរៀបចំសិក្ខាសាលា ឬកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈជាមួយអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ព្រមទាំង ពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ដែលគណៈកម្មាធិ-ការអចិន្ត្រៃយ៍រដ្ឋសភាបានប្រគល់ជូន។

- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយគណៈកម្មការសភា នៃបណ្តាប្រទេស ដើម្បីពង្រឹង និងផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមកផ្នែកនីតិប្បញ្ញត្តិ។

- ប្រធាន ឬប្រធានស្តីទីមានភារៈចូលរួមក្នុងការប្រជុំរបស់ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា តាមការអញ្ជើញរបស់ប្រធានរដ្ឋសភា។ ក្រៅពីតួនាទីរួមគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម មានភារកិច្ចស្នូលសំខាន់ៗ ដូចខាងក្រោម ៖

១-ពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម និងលិខិតបទដ្ឋាននានាដែល គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាប្រគល់ជូន

- ធ្វើសេចក្តីរាយការណ៍អំពីយោបល់របស់គណៈកម្មការក្នុងការពិនិត្យសិក្សាសេច ក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងសម័យប្រជុំពេញអង្គរដ្ឋសភា ពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ រួមមាន ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ ច្បាប់ទូទាត់ថវិកា

- ចូលរួមពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់នានា តាមការ អញ្ជើញរបស់គណៈកម្មការជំនាញ ឬ/និងគណៈកម្មការពិសេសចំពោះកិច្ច តាមដាន ត្រួតពិនិត្យលើការអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យតាមដានការអនុវត្តច្បាប់ពាក់ព័ន្ធ នឹងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ជូនប្រធានរដ្ឋសភា

- ចូលរួមក្នុងវេទិកាថ្នាក់ជាតិ និងវេទិកាអន្តរជាតិ ដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

- រៀបចំសិក្ខាសាលា និងវេទិកាពិគ្រោះយោបល់ពាក់ព័ន្ធនឹងការកសាងគោលនយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

២- ពិនិត្យ ស្រាវជ្រាវ លើរបាយការណ៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ និងរៀបចំជាអនុសាសន៍ជូន

ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងអគ្គសវនករ ស្តីពីការកែលទ្ធភាពមិនប្រក្រតី

- ចូលរួមពិនិត្យ ពិភាក្សាលើគម្រោងថវិការដ្ឋសភាប្រចាំឆ្នាំ ដើម្បីដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដើម្បីពិនិត្យ និងសម្រេច

- កសាងគោលការណ៍ បទដ្ឋាន នីតិវិធីប្រតិបត្តិការថវិកា និងសវនកម្ម និងត្រួតពិនិត្យកិច្ចប្រតិបត្តិការថវិការដ្ឋសភា ដើម្បីដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ពិនិត្យនិងសម្រេច

៣- អញ្ជើញរដ្ឋមន្ត្រី ឬរជនណាមួយមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ អន្តរជាតិ សង្គមស៊ីវិល និងវិស័យឯកជន ដែលពាក់ព័ន្ធនិងសមត្ថកិច្ចរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និង សវនកម្ម។

- ចងក្រងឯកសារដែលពាក់ព័ន្ធនឹងវិស័យទទួលបន្ទុកទាំងឯកសារជាតិ និងឯក សាររបស់បណ្តាប្រទេសដែលមានការអភិវឌ្ឍកម្រិតប្រហាក់ប្រហែលឬខ្ពស់ ជាង ដើម្បីធ្វើទំនាក់ទំនងផ្លាស់ប្តូរបទពិសោធន៍ និងជំរុញកិច្ចសហប្រតិបត្តិ ការជាផលប្រយោជន៍ជាតិ។

- រួមចំណែកពង្រឹង និងពង្រីកការផ្សព្វផ្សាយច្បាប់ ការគោរពប្រតិបត្តិច្បាប់ និងលើកកំពស់ការយល់ដឹងអំពីច្បាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ គណៈកម្មការ។

- លើកទឹកចិត្តឲ្យមានការចូលរួមដោយសកម្មពីសំណាក់សាធារណជន ក្នុងវេទិកានានា សំដៅដល់ការឆ្លើយតបទៅនឹងសំណូមពរ ព្រមទាំងផលប្រយោជន៍ស្រប ច្បាប់របស់ប្រជាពលរដ្ឋ ។

- ទទួលពិនិត្យ សេចក្តីស្នើទាំងឡាយ និងសំណូមពរផ្សេងៗរបស់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គណៈកម្មការ ដើម្បីលើកសំណើ តាមរយៈប្រធានរដ្ឋសភា ជូនក្រសួងពាក់ព័ន្ធពិចារណា និងដោះស្រាយ ។

**គ. គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក**

គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក ហៅកាត់ថា គណៈកម្មការទី៣ សរសេរកាត់ថា គ.៣ មានភារកិច្ចរួម ដូចតទៅ៖

- ពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ដែលគណៈកម្មាធិការអចិន្ត្រៃយ រដ្ឋសភាបានប្រគល់ជូន និងនាំយកយោបល់របស់គណៈកម្មការជម្រាបជូន រដ្ឋសភាក្នុងសម័យប្រជុំពេញអង្គអំពីការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ។

- ចូលរួម និងរៀបចំសិក្ខាសាលា ឬកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈជាមួយអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ។ល ។

- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយគណៈកម្មការសភា នៃបណ្តាប្រទេស។

ក្រៅពីតួនាទីរួមគណៈ-កម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក មានភារកិច្ចស្នូលសំខាន់ៗ ដូចខាងក្រោម ៖

១- ពិនិត្យ សិក្សា ស្រាវជ្រាវ ផ្តល់មតិយោបល់លើសេចក្តីស្នើច្បាប់ សេចក្តីព្រាង ច្បាប់ ពាក់ព័ន្ធនឹងវិស័យ ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រគល់ជូន

- ចូលរួមពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់នានា តាមការ អញ្ជើញរបស់គណៈកម្មការជំនាញ និងគណៈកម្មការពិសេសចំពោះកិច្ច។

- ធ្វើទំនាក់ទំនងជាមួយគណៈកម្មការនានារបស់រដ្ឋសភា រាជរដ្ឋាភិបាល និង ស្ថាប័ននានា ដើម្បីស្វែងយល់ជាមុននូវរាល់គំនិតផ្តួចផ្តើម និងការសម្រេចលើសេចក្តីស្នើច្បាប់ សេចក្តីព្រាងច្បាប់ ឬលិខិតបទដ្ឋាននានា ពាក់ព័ន្ធនឹងភារកិច្ច របស់គណៈកម្មការ។

- រួមចំណែកពង្រឹង និងពង្រីក ការផ្សព្វផ្សាយច្បាប់ ការគោរពប្រតិបត្តិច្បាប់

២- លើកកំពស់ការយល់ដឹងអំពីច្បាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គណៈកម្មការ ពិនិត្យតាមដានលើការអនុវត្តច្បាប់ពាក់ព័ន្ធវិស័យ ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក។

- លើកទឹកចិត្តឲ្យមានការចូលរួមដោយសកម្មពីសំណាក់សាធារណជនក្នុង វេទិកានានា សំដៅឆ្លើយតបទៅនឹងសំណូមពរ ព្រមទាំងផលប្រយោជន៍ស្រប ច្បាប់របស់ប្រជាពលរដ្ឋ។

- ទទួលពិនិត្យ សេចក្តីស្នើទាំងឡាយ និងសំណូមពរផ្សេងៗរបស់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គណៈកម្មការ ដើម្បីលើកសំណើតាម រយៈប្រធានរដ្ឋសភា ជូនក្រសួងពាក់ព័ន្ធពិចារណា និងដោះស្រាយ អញ្ជើញតំណាងរាជរដ្ឋាភិបាល មកបំភ្លឺបញ្ហាអ្វីមួយពាក់ព័ន្ធនឹងសមត្ថកិច្ច

- គណៈកម្មការ ដែលមានបំណងស្វែងយល់ និងធ្វើលិខិតទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដើម្បីសុំឲ្យផ្តល់ឯកសារសំខាន់ៗ ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ។

៣- ចុះបំពេញបេសកកម្មអង្កេតរាល់បញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងគណៈកម្មការ ហើយធ្វើរបាយការណ៍ជូនប្រធានរដ្ឋសភា ទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ លើវិស័យឯកជន និងវិស័យផ្សេងៗ

- ស្វែងយល់ពីបញ្ហានានាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការពង្រឹងនិងពង្រីកសហប្រតិបត្តិការអន្តរជាតិជាមួយដៃគូអភិវឌ្ឍន៍នានា សភាបណ្តាប្រទេសនានាក្នុងតំបន់ និងសកលលោក តាមរយៈទស្សនកិច្ចសិក្សា ផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក។

- ចងក្រងឯកសារដែលពាក់ព័ន្ធនឹងវិស័យទទួលបន្ទុកទាំងឯកសារជាតិ និងអន្តរជាតិ

- ជាតិ ដើម្បីធ្វើទំនាក់ទំនងផ្លាស់ប្តូរបទពិសោធន៍ និងជំរុញកិច្ចសហប្រតិបត្តិការ ជាផលប្រយោជន៍ជាតិ។

**ឃ. គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ**

គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ ហៅកាត់ថា គណៈកម្មការទី៤ សរសេរកាត់ថា គ.៤ មានភារកិច្ចរួម ដូចតទៅ៖

- ពិនិត្យ និងសិក្សាសេចក្ដីព្រាងច្បាប់ និងសេចក្ដីស្នើច្បាប់ ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានប្រគល់ជូន និងនាំយកយោបល់របស់គណៈកម្មការជម្រាបជូនរដ្ឋសភា ក្នុងសម័យប្រជុំពេញអង្គអំពីការពិនិត្យសិក្សាសេចក្ដីព្រាងច្បាប់ និងសេចក្ដីស្នើច្បាប់។

- ចូលរួម និងរៀបចំសិក្ខាសាលា ឬកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ ជាមួយអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ។ល។

- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយគណៈកម្មការសភានៃបណ្ដាប្រទេសនានាដើម្បីពង្រឹង និងផ្លាស់ប្ដូរបទពិសោធន៍ពីគ្នាទៅវិញទៅមកផ្នែកនីតិប្បញ្ញត្តិ។

- ប្រធាន ឬប្រធានស្ដីទី មានការៈចូលរួមក្នុងការប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាតាមការអញ្ជើញរបស់ប្រធានរដ្ឋសភា។

- សមាជិកា សមាជិកគណៈកម្មការ មានភារៈចូលរួមក្នុងក្រុមមិត្តភាពសភា ឬអង្គការអន្តរសភា ទៅតាមសេចក្ដីសម្រេចរបស់ប្រធានរដ្ឋសភា។បំពេញការងារផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងប្រធានរដ្ឋសភា ប្រគល់ជូន។ ក្រៅពីភារកិច្ចរួមគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ មានភារកិច្ចស្នូលសំខាន់ដូចខាងក្រោម ៖

១- ពិនិត្យសិក្សាស្រាវជ្រាវជជែកពិភាក្សា រៀបចំកិច្ចពិគ្រោះយោបល់ និងសិក្ខាសាលា ព្រមទាំងឲ្យយោបល់លើសេចក្ដីព្រាងច្បាប់ សេចក្ដីស្នើច្បាប់ និងកិច្ចការងារផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាប្រគល់ជូន

- ផ្ដួចផ្ដើមគំនិតធ្វើសេចក្ដីស្នើច្បាប់ ឬស្នើសុំធ្វើវិសោធនកម្មច្បាប់ ជាពិសេសពាក់ព័ន្ធនឹងវិស័យការពារជាតិ សន្តិសុខជាតិ និងមុខងារសាធារណៈ។

- រៀបចំកិច្ចពិគ្រោះយោបល់ សិក្ខាសាលា និងសម្របសម្រួលជាមួយ ស្ថាប័នពាក់ព័ន្ធ ក្នុងការស្វែងរកដំណោះស្រាយរាល់បញ្ហាទាំងពួង ដែលពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ។

- ទំនាក់ទំនងជាមួយគណៈកម្មការជំនាញនានារបស់រដ្ឋសភា ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដើម្បីស្វែងយល់ពីព័ត៌មានជាមុននូវរាល់គំនិតផ្ដួចផ្ដើម និងការសម្រេចលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ និងកិច្ចការងារទាំងឡាយ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់គណៈកម្មការ

- អញ្ជើញតំណាងរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ អ្នកជំនាញការ តំណាងសង្គមស៊ីវិល ម្ចាស់ស្នើច្បាប់ ឬម្ចាស់សំណើសុំកែសម្រួលសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ឬស្នើសុំធ្វើវិសោធនកម្មច្បាប់ និងរាល់បញ្ហាទាំងពួងដែលទាក់ទងនឹងសមត្ថកិច្ចទទួលខុសត្រូវរបស់គណៈកម្មការ មកបំភ្លឺ និងប្រឹក្សាយោបល់ជាមួយគណៈកម្មការ

- ចូលរួមពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់នានា តាមការអញ្ជើញរបស់គណៈកម្មការជំនាញ និងគណៈកម្មការពិសេសចំពោះកិច្ច។

- ចងក្រងឯកសារដែលពាក់ព័ន្ធនឹងវិស័យទទួលបន្ទុក ទាំងឯកសារជាតិ និងឯកសាររបស់បណ្តាប្រទេស

- ដែលមានការអភិវឌ្ឍន៍កម្រិតប្រហាក់ប្រហែល ឬខ្ពស់ជាង ដើម្បីធ្វើទំនាក់ទំនង ផ្លាស់ប្តូរបទពិសោធន៍និងជំរុញ កិច្ចសហប្រតិបត្តិការជាផលប្រយោជន៍ជាតិ ។

២-តាមដានការរៀបចំថវិកាជាតិប្រចាំឆ្នាំ និងគោលនយោបាយពាក់ព័ន្ធនឹងវិស័យការពារជាតិ សន្តិសុខជាតិ និងមុខងារសាធារណៈព្រមទាំងមានសិទ្ធិ(ប្រធានគណៈកម្មការ) ទទួលបាននូវព័ត៌មានទាក់ទងក្នុងវិស័យទាំងបីខាងលើ។

-បំពេញមុខងារតាមវិស័យជាសមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន ដោយធ្វើការឃ្លាំមើល ស្រាវជ្រាវ និងប្រមូលព័ត៌មានទាំងឡាយ តាមរយៈរបាយការណ៍ ការប្រាស្រ័យការងារផ្ទាល់នៅតាមក្រសួងស្ថាប័ន ឬមូលដ្ឋាននានា ដែលទាក់ទងនឹងកិច្ចការគណៈកម្មការ។

- ស្វែងយល់ពីតម្រូវការភាពសកម្ម ភាពអសកម្ម រួមនឹងបញ្ហាប្រឈមនានាចំពោះច្បាប់ដែលបានប្រកាសដាក់ឲ្យអនុវត្ត ហើយពិនិត្យពិចារណា វាយតម្លៃលើកិច្ចការទាំង នោះ រួចរាយការណ៍ជូនប្រធានរដ្ឋសភា

- ជំរុញទៅស្ថាប័នពាក់ព័ន្ធឲ្យរកដំណោះស្រាយសមស្របតាមច្បាប់ ព្រមទាំងពិនិត្យលទ្ធភាពធ្វើវិសោធនកម្មច្បាប់ខ្លះ ឲ្យស្របតាមស្ថានភាពសេដ្ឋកិច្ច និងការអភិវឌ្ឍន៍សង្គម

-ប្រាស្រ័យការងារជាមួយម្ចាស់ឆ្នោតនៅតាមមូលដ្ឋាននានា ដោយក្តាប់យកនូវព័ត៌មានឲ្យបានច្បាស់ពីតម្រូវការ និងបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ ភាពអសកម្មក៏ដូចជាផែនការអភិវឌ្ឍន៍នានារបស់អាជ្ញាធរជាសមាសធាតុ និងជាវិធានការដ៏សំខាន់ក្នុងការទប់ស្កាត់

- និងជំរុញស្ថាប័នពាក់ព័ន្ធឲ្យរកដំណោះស្រាយចំពោះ ទំនាស់ដែលបានកើត កំពុងកើត ព្រមទាំងជាការរួមចំណែក ធ្វើឲ្យប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈរបស់រាជ រដ្ឋាភិបាល ដំណើរការដោះស្រាយបញ្ហា និងការអភិវឌ្ឍន៍សង្គមប្រកបដោយតម្លាភាព និងយុត្តិធម៌។

-អញ្ជើញរដ្ឋមន្ត្រី ឥស្សរជន ឬតំណាងស្ថាប័នពាក់ព័ន្ធ មកបំភ្លឺអំពីបញ្ហាអ្វីមួយដែលទាក់ទងនឹងវិស័យទទួលខុសត្រូវរបស់គណៈកម្មការ ។

៣-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយបណ្តាសភានៃប្រទេសក្នុងតំបន់ សកលលោក និងដៃគូរអភិវឌ្ឍន៍អន្តរជាតិនានា តាមរយៈសិក្ខាសាលា វេទិកាតំបន់ បទបង្ហាញ និងតាមរយៈទស្សនៈកិច្ចផ្លាស់ប្តូរបទពិសោធន៍ ដែលទាក់ទងនឹងវិស័យទទួលខុសត្រូវរបស់គណៈកម្មការ តួនាទីសភា អភិបាលកិច្ច និងការកៀងគរជំនួយសម្រាប់អភិវឌ្ឍន៍ធនធានមនុស្ស ។

**ខ. គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន**

គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ហៅកាត់ថា គណៈកម្មការទី៥ សរសេរកាត់ថា គ.៥ មានភារកិច្ចរួម ដូចតទៅៈ

- ពិនិត្យសិក្សាសេចក្តីព្រាងច្បាប់និងសេចក្តីស្នើច្បាប់ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបានប្រគល់ជូន

- នាំយកយោបល់របស់គណៈកម្មការជម្រាបជូនរដ្ឋសភាក្នុងសម័យប្រជុំពេញអង្គ អំពីការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ចូលរួម និងរៀបចំសិក្ខាសាលា ឬកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈជាមួយអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ។ល។

- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយគណៈកម្មការសភានៃបណ្តាប្រទេសដើម្បីពង្រឹង និងផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមកផ្នែកនីតិប្បញ្ញត្តិ។

- ប្រធាន ឬប្រធានស្តីទីមានភារៈចូលរួមក្នុងការប្រជុំរបស់ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា តាមការអញ្ជើញរបស់ប្រធានរដ្ឋសភាសមាជិកគណៈកម្មការមានភារៈចូលរួមក្នុងក្រុមមិត្តភាពសភា ឬអង្គការអន្តរសភាទៅតាមសេចក្តីសម្រេចរបស់ប្រធានរដ្ឋសភា បំពេញការងារផ្សេងៗទៀតដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភានិងប្រធានរដ្ឋសភាប្រគល់ជូន។ ក្រៅពីភារកិច្ចរួមគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មានមានភារកិច្ចស្នូលសំខាន់ៗ ដូចតទៅៈ

១- ពិនិត្យ ស្រាវជ្រាវផ្តល់មតិយោបល់លើរាល់សេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងលិខិតបទដ្ឋាននានាបញ្ជូនមកពីគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មការ នានានៃរដ្ឋសភា ឬអគ្គលេខាធិការដ្ឋានរដ្ឋសភា

- សម្របសម្រួល សិក្សាស្រាវជ្រាវ ប្រមូលព័ត៌មានក្នុង និងក្រៅប្រទេស និងជូន ព័ត៌មាន ឬលើកមតិយោបល់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍

ចូលរួមពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់នានា តាមការ អញ្ជើញរបស់គណៈកម្មការជំនាញ និងគណៈកម្មការពិសេសចំពោះកិច្ច

- ជាសេនាធិការរបស់រដ្ឋសភាក្នុងការពិនិត្យតាមដានមើលការអនុវត្តលើវិស័យ ការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ដែលច្បាប់បានបញ្ញត្តិ និងជូនមតិយោបល់ក្នុងករណីចាំបាច់

- ស្នើសុំធ្វើវិសោធនកម្មច្បាប់ និងរាល់បញ្ហាដែលទាក់ទងនឹង សមត្ថកិច្ចទទួលខុសត្រូវរបស់គណៈកម្មការ មកបំភ្លឺ និងប្រឹក្សាយោបល់ជាមួយ គណៈកម្មការ។

- ដើម្បីលើកកម្ពស់គុណភាព ការងារលើវិស័យនេះ ទាក់ទងជាមួយគណៈកម្មការនានានៃរដ្ឋសភា រាជរដ្ឋាភិបាល និងស្ថាប័ននានា ដើម្បីស្វែងយល់ជាមុននូវរាល់គំនិតផ្តើម និងការសម្រេចលើសេចក្តីព្រាងច្បាប់។

- សេចក្តីស្នើច្បាប់ នយោបាយការបរទេសកិច្ចការទំនាក់ទំនងព័ត៌មានសាធារណៈ និងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងភារកិច្ចរបស់គណៈកម្មការ អញ្ជើញតំណាងរាជរដ្ឋាភិបាលដែលពាក់ព័ន្ធអ្នកជំនាញការ និងតំណាងសង្គម ស៊ីវិល ម្ចាស់ស្នើច្បាប់ ឬម្ចាស់សំណើសុំកែសម្រួលសេចក្តីព្រាងច្បាប់ សេចក្តី ស្នើច្បាប់

២- ធ្វើលិខិតទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដើម្បីសុំឲ្យផ្តល់ឯកសារសំខាន់ៗ ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ បំពេញមុខងារតាមវិស័យជាសមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន ដោយធ្វើការឃ្លាំមើលស្រាវជ្រាវ និងប្រមូលព័ត៌មានទាំងឡាយ តាមរយៈរបាយការណ៍ ការ ប្រាស្រ័យការងារផ្ទាល់នៅតាមក្រសួងស្ថាប័ន ឬមូលដ្ឋាននានា ដែលទាក់ទង នឹងកិច្ចការគណៈកម្មការ

- ដើម្បីស្វែងយល់ពីតម្រូវការ ភាពសកម្ម ភាពអសកម្ម រួមនឹងបញ្ហាប្រឈមនានា ចំពោះច្បាប់ដែលបានប្រកាសដាក់ឲ្យអនុវត្ត ហើយពិនិត្យពិចារណា វាយតម្លៃលើកិច្ចការទាំងនោះ រួចរាយការណ៍ជូនប្រធាន រដ្ឋសភា និងជំរុញទៅស្ថាប័នពាក់ព័ន្ធឲ្យរកដំណោះស្រាយសមស្របតាមច្បាប់។

- សហការជាមួយអគ្គលេខាធិការដ្ឋានរដ្ឋសភា រៀបចំប្រព័ន្ធព័ត៌មាននៃរដ្ឋសភា ដោយពិភាក្សាយោបល់ជាមួយគណៈកម្មការជំនាញនានានៃរដ្ឋសភា ហើយលើក ជាយោបល់ និងស្ន៉ើជូនប្រធានរដ្ឋសភាសម្រេច

៣-ទទួលពិនិត្យ សេចក្តីស្នើទាំងឡាយ និងសំណូមពរផ្សេងៗរបស់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គណៈកម្មការ

- លើកសំណើតាមរយៈប្រធានរដ្ឋសភាជូន ក្រសួងពាក់ព័ន្ធពិចារណា និងដោះស្រាយប្រាស្រ័យការងារជាមួយម្ចាស់ឆ្នោតនៅតាមមូលដ្ឋាននានា ដោយយកព័ត៌មាន ឲ្យបានច្បាស់ពីតម្រូវការ បញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ ភាពអសកម្ម ក៏ដូចជាផែនការអភិវឌ្ឍន៍នានារបស់អាជ្ញាធរ ជាសមាសធាតុ និងជាវិធានការដ៏សំខាន់ ក្នុងការទប់ស្កាត់ និងការជំរុញស្ថាប័នពាក់ព័ន្ធឲ្យរកដំណោះស្រាយចំពោះទំនាស់ ដែលបានកើត ឬកំពុងកើតព្រម-ទាំងជាការរួមចំណែកធ្វើឲ្យប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល ដំណើរការដោះស្រាយបញ្ហា និងការអភិវឌ្ឍន៍សង្គមប្រកបដោយតម្លាភាព និងយុត្តិធម៌។

- ពង្រឹង និងពង្រីកសហប្រតិបត្តិការអន្តរជាតិជាមួយដៃគូអភិវឌ្ឍន៍នានា សភាបណ្តាប្រទេសនានាក្នុងតំបន់ និងសកលលោក តាមរយៈទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទ ពិសោធន៍គ្នាទៅវិញទៅមក។

- រៀបចំសិក្ខាសាលា និងវេទិកាពិគ្រោះយោបល់ពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់គណៈកម្មការ

-អញ្ជើញរដ្ឋមន្ត្រី ឥស្សរជន ឬតំណាងស្ថាប័នពាក់ព័ន្ធ មកបំភ្លឺអំពីបញ្ហាអ្វីមួយដែល ទាក់ទងនឹងវិស័យទទួលខុសត្រូវរបស់គណៈកម្មការ

- ជំរុញការផ្សព្វផ្សាយច្បាប់ កិច្ចព្រមព្រៀង អនុសញ្ញា សន្ធិសញ្ញា និងពិធីសារ រួមទាំងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីដល់សាធារណជន ជាតិ និងអន្តរជាតិឲ្យបានទូលំទូលាយ

- រៀបចំលើកយោបល់ស្នើជូនប្រធានរដ្ឋសភា រាល់សមាសភាពគណៈប្រតិភូ ដែលជាសមាជិករដ្ឋសភាចេញបំពេញបេសកកម្មក្រៅប្រទេស ដោយសហការ ជាមួយគណៈកម្មការពាក់ព័ន្ធ

- រៀបចំកម្មវិធីទស្សនកិច្ចជាមួយ អគ្គលេខាធិការដ្ឋានរដ្ឋសភា សម្របសម្រួល និងស្វែងយល់អំពីគណៈប្រតិភូអន្តរជាតិ ដែលអញ្ជើញមកធ្វើ ទស្សនកិច្ចនៅរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដោយសហការរៀបចំកម្មវិធី ទស្សនកិច្ចជាមួយអគ្គលេខាធិការដ្ឋានរដ្ឋសភា។

- រៀបចំលើកយោបល់ស្នើជូនប្រធានរដ្ឋសភា អំពីសមាសភាពក្រុមសភាជាតិ និងក្រុមមិត្តភាពសភាកម្ពុជា ក្នុងការងារទំនាក់ទំនងជាទ្វេភាគី និងពហុភាគី រវាង រដ្ឋសភាកម្ពុជា និងសភាលើសកលលោក ដោយសហការជាមួយ គណៈកម្មការពាក់ព័ន្ធ និងអគ្គលេខាធិការដ្ឋានរដ្ឋសភា។

-ចងក្រងឯកសារដែលពាក់ព័ន្ធនឹងវិស័យទទួលបន្ទុកទាំងឯកសារជាតិ និងឯកសាររបស់បណ្តាប្រទេសដែលមានការអភិវឌ្ឍកម្រិតប្រហាក់ប្រហែល ឬខ្ពស់ជាងដើម្បីធ្វើទំនាក់ទំនងផ្លាស់ប្តូរបទពិសោធន៍ និងជំរុញកិច្ចសហប្រតិបត្តិការ ជាផលប្រយោជន៍ជាតិ ។

**ច. គណៈកម្មការនីតិកម្ម និងយុត្តិធម៌**

គណៈកម្មការនីតិកម្ម និងយុត្តធម៌ ហៅកាត់ថា គណៈកម្មការទី៦ សរសេរកាត់ថា គ.៦ មានភារកិច្ចរួមដូចតទៅ៖

- ពិនិត្យសិក្សា សេចក្តីព្រាងច្បាប់និងសេចក្តីស្នើច្បាប់ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបានប្រគល់ជូន និងនាំយកយោបល់របស់គណៈកម្មការជម្រាបជូនរដ្ឋសភាក្នុងសម័យប្រជុំពេញអង្គ អំពីការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់។

- ចូលរួម និងរៀបចំសិក្ខាសាលា ឬកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈជាមួយអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ។ល ។

- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយគណៈកម្មការសភានៃបណ្តាប្រទេសដើម្បីពង្រឹង និងផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមកផ្នែកនីតិប្បញ្ញត្តិប្រធានឬប្រធានស្តីទីមានភារៈចូលរួមក្នុងការប្រជុំរបស់គណៈកម្មា-ធិការអចិន្ត្រៃយ៍រដ្ឋសភា តាមការអញ្ជើញរបស់ប្រធានរដ្ឋសភា។ ក្រៅពីភារកិច្ចរួម គណៈកម្មការនីតិកម្ម និងយុត្តិធម៌ មានភារកិច្ចស្នូលសំខាន់ៗ ដូចខាងក្រោម ៖

១- ពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានប្រគល់ជូន ជាអាទិ៍ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ធម្មនុញ្ញសម្រាប់ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីសមាជរដ្ឋសភានិងព្រឹទ្ធសភា

- វិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ពាក់ព័ន្ធនឹងវិស័យយុត្តិធម៌តុលាការ អយ្យការ និងពន្ធនាគារ ព្រមទាំងវិស័យប្រឆាំងអំពើពុករលួយ។

- សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់រៀបចំអង្គការ និងច្បាប់ពិសេសដែល មានចរិតជាច្បាប់រៀបចំអង្គការ ។

- សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ពាក់ព័ន្ធនឹងការបោះឆ្នោត សេចក្តីព្រាងច្បាប់ស្តីពីការកំណត់ចំនួនអាសនៈរដ្ឋសភា

- សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ស្តីពីការអនុម័តយល់ព្រមលើ អនុសញ្ញា សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ ពាក់ព័ន្ធនឹងសមត្ថកិច្ច របស់គណៈកម្មការ ។

- សហការក្នុងការពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ជាមួយ គណៈកម្មការនានា តាមការប្រគល់ភារកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ រដ្ឋសភា

- ចូលរួមពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់នានា តាមការអញ្ជើញរបស់គណៈកម្មការជំនាញ និងគណៈកម្មការពិសេសចំពោះកិច្ច

- ទំនាក់ទំនងជាមួយព្រឹទ្ធសភា ស្ថាប័នធម្មនុញ្ញ ក្រសួងពាក់ព័ន្ធ និងអាជ្ញាធរសាធារណៈតាមរយៈប្រធានរដ្ឋសភា ដើម្បីបំពេញភារកិច្ចទទួលខុសត្រូវដូចមាន កំណត់ក្នុងចំណុចខាងលើ ហើយដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ។

- ចងក្រងឯកសារដែលពាក់ព័ន្ធនឹងវិស័យទទួលបន្ទុកទាំងឯកសារជាតិ និងឯកសារ របស់បណ្តាប្រទេសដែលមានការអភិវឌ្ឍកម្រិតប្រហាក់ប្រហែល ឬខ្ពស់ជាង ដើម្បីធ្វើទំនាក់ទំនងផ្លាស់ប្តូរបទពិសោធន៍ និងជំរុញកិច្ចសហប្រតិបត្តិការជា ផលប្រយោជន៍ជាតិ ។

២-ត្រួតពិនិត្យការអនុវត្តច្បាប់ក្នុងវិស័យពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការផ្អែកតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន និងស្របតាមកម្មវិធីនយោបាយរបស់ រាជរដ្ឋាភិបាល ។

- អញ្ជើញរដ្ឋមន្ត្រី ឬវរជនមកបំភ្លឺអំពីបញ្ហាអ្វីមួយ ពាក់ព័ន្ធនឹងវិស័យដែលខ្លួនទទួលខុសត្រូវ

- ចុះបំពេញបេសកកម្មតាមរាជធានី និងបណ្តាខេត្ត ព្រមទាំងស្ថាប័នពាក់ព័ន្ធ ជាអាទិ៍ ៖ ក្រសួងយុត្តិធម៌ តុលាការអយ្យការ ពន្ធនាគារ រួមទាំងស្ថាប័នអប់រំ វិជ្ជាជីវៈតុលាការ និងវិស័យប្រឆាំងអំពើពុករលួយ

- ជំរុញស្ថាប័នពាក់ព័ន្ធឲ្យកសាងផែនការច្បាស់លាស់ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់

- ពិនិត្យ និងលើកសំណើវិសោធនកម្មច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត ដែលមិនសមស្របនឹងស្ថានភាពជាក់ស្តែង សំដៅធ្វើឲ្យមានសុខដុមនីយកម្មជាមួយច្បាប់ជាតិ តំបន់ និងអន្តរជាតិ ។

៣ - រួមចំណែកពង្រឹងការគោរព ប្រតិបត្តិច្បាប់ ទន្ទឹមនឹងពង្រីកការផ្សព្វផ្សាយព័ត៌មានច្បាប់ និងលើកកំពស់ការយល់ដឹងលើវិស័យច្បាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គណៈកម្មការ។

- លើកទឹកចិត្តឲ្យមានការចូលរួមដោយសកម្មពីសំណាក់សាធារណជន ក្នុងវេទិកានានាសំដៅឆ្លើយតបទៅនឹងសំណូមពរ ព្រមទាំងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ

- ទទួលពិនិត្យ និងលើកសំណើដោះស្រាយឲ្យបានហ្មត់ចត់នូវសេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គណៈកម្មការ

- ទទួលនិងពិនិត្យពាក្យបណ្តឹង និងសំណូមពរផ្សេងៗរបស់ប្រជាពលរដ្ឋ តាម វិស័យទទួលខុសត្រូវរបស់គណៈកម្មការ និងលើកសំណើតាមរយៈប្រធាន រដ្ឋសភា ជូនក្រសួងពាក់ព័ន្ធពិចារណា និងដោះស្រាយ

- រួមចំណែកក្នុងការពង្រឹង និងពង្រីកសហប្រតិបត្តិការមានផលប្រយោជន៍ទៅ វិញទៅមកជាមួយដៃគូអភិវឌ្ឍន៍ ។

**ឆ. គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍**

គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍ ហៅកាត់ថា គណៈកម្មការទី៧ សរសេរកាត់ថា គ.៧ មានភារកិច្ចរួម ដូចតទៅ៖

- ពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានប្រគល់ជូន ព្រមទាំងនាំយកយោបល់របស់គណៈកម្មការជម្រាបជូនរដ្ឋសភាក្នុងសម័យប្រជុំពេញអង្គអំពីការពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់

- ចូលរួម និងរៀបចំសិក្ខាសាលា ឬកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈជាមួយអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ។ល ។

- ធ្វើទំនាក់ទំនង សហប្រតិបត្តិការជាមួយគណៈកម្មការសភា នៃបណ្តាប្រទេសដើម្បីពង្រឹង និងផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមកផ្នែកនីតិប្បញ្ញត្តិ

- ប្រធាន ឬប្រធានស្តីទីមានភារៈចូលរួមក្នុងការប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា តាមការអញ្ជើញរបស់ប្រធានរដ្ឋសភា សមាជិកគណៈកម្មការមានភារៈចូលរួមក្នុងក្រុមមិត្តភាពសភា ឬអង្គការអន្តរសភា ទៅតាមសេចក្តីសម្រេចរបស់ប្រធានរដ្ឋសភា

- បំពេញការងារផ្សេងៗទៀតដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងប្រធានរដ្ឋសភា ប្រគល់ជូន ។ របៀបរបបធ្វើការងារ និងការបែងចែកភារកិច្ច ទទួលខុសត្រូវរបស់សមាជិក គណៈកម្មការនីមួយៗ ត្រូវកំណត់ដោយប្រធានគណៈកម្មការ ។ក្រៅពីភារកិច្ចរួម គ.៧ មានភារកិច្ចស្នូលសំខាន់ៗ ដូចខាងក្រោម ៖

១-តាមដានត្រួតពិនិត្យ សកម្មភាពការងាររបស់ក្រសួងទទួលបន្ទុកដោយផ្អែកលើរដ្ឋធម្មនុញ្ញកម្មវិធីនយោបាយ និងច្បាប់ផ្សេងៗដែលពាក់ព័ន្ធធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តួចផ្តើមធ្វើសេចក្តីស្នើច្បាប់តាមការចាំបាច់ពាក់ព័ន្ធនឹងវិស័យដែលគណៈកម្មការទទួលបន្ទុក និងសិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ដែលគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាប្រគល់ជូន។

- ការពារសេចក្តីព្រាង ឬស្នើច្បាប់ទាំងនោះក្នុងសម័យប្រជុំពេញអង្គនៃរដ្ឋសភា ចូលរួមពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និង

- សេចក្តីស្នើច្បាប់នានាតាមការអញ្ជើញរបស់គណៈកម្មការជំនាញ និងគណៈកម្មការពិសេសចំពោះកិច្ចចងក្រងឯកសារដែលពាក់ព័ន្ធនឹងវិស័យទទួលបន្ទុកទាំងឯកសារជាតិ និងឯកសាររបស់បណ្តាប្រទេសដែលមានការអភិវឌ្ឍកម្រិតប្រហាក់ប្រហែល ឬខ្ពស់ជាង ដើម្បីធ្វើទំនាក់ទំនងផ្លាស់ប្តូរបទពិសោធន៍ និងជំរុញកិច្ចសហប្រតិបត្តិការជាផលប្រយោជន៍ជាតិបំពេញបេសកកម្មតាមបណ្តាខេត្តរាជធានី។

២- ស្វែងយល់ពីសភាពការណ៍ការអនុវត្តកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាលពិសេសការអនុវត្តការងាររបស់បណ្តាវិស័យជំនាញ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការអញ្ជើញរដ្ឋមន្ត្រី ឬតស្សរជនជាថ្នាក់ដឹកនាំសំខាន់ៗ របស់បណ្តាស្ថាប័នពាក់ព័ន្ធមកបកស្រាយបំភ្លឺរាល់បញ្ហាប្រឈម និងវិធានការដោះស្រាយ ។

- ចូលរួមសិក្ខាសាលា ឬសន្និសីទជាតិ អន្តរជាតិដែលពាក់ព័ន្ធរៀបចំរបៀបរបប ការងាររវាងគណៈកម្មការជាមួយ ក្រសួងជំនាញក្នុងក្របខណ្ឌសមត្ថកិច្ចទទួលបន្ទុករបស់គណៈកម្មការ ដើម្បីសម្រួលដល់ការទាក់ទងផ្តល់របាយការណ៍ និងព័ត៌មាន ផ្សេងៗដែលជាមូលដ្ឋានក្នុងការតាមដាន និងជំរុញដោះស្រាយបញ្ហាប្រឈមឲ្យមានប្រសិទ្ធភាពបំពេញការងារតាមមណ្ឌល។

៣-រួមចំណែកពង្រឹងការគោរពច្បាប់ដោយពង្រីកការផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងលើវិស័យច្បាប់ពិសេសច្បាប់ពាក់ព័ន្ធនឹងវិស័យដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការ និងចូលរួមដោះស្រាយបញ្ហាសង្គមតាមលទ្ធភាពជាក់ស្តែង។

**៨. គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី**

គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី ហៅកាត់ថា គណៈកម្មការទី៨ សរសេរកាត់ថា គ.៨ មានភារកិច្ចរួម ដូចតទៅៈ

- ពិនិត្យសិក្សាសេចក្តីព្រាងច្បាប់និងសេចក្តីស្នើច្បាប់ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបានប្រគល់ជូន ព្រមទាំងនាំយកយោបល់របស់គណៈកម្មការជម្រាបជូនរដ្ឋសភាក្នុងសម័យប្រជុំពេញអង្គអំពីការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់

- ចូលរួម និងរៀបចំសិក្ខាសាលា ឬកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈជាមួយអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ។ល។

- បំពេញការងារផ្សេងៗទៀតដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងប្រធានរដ្ឋសភាប្រគល់ជូន ។

- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយគណៈកម្មការរដ្ឋសភា នៃបណ្តាប្រទេសដើម្បីពង្រឹង និងផ្លាស់ប្តូរ បទពិសោធន៍ពីគ្នាទៅវិញទៅមកផ្នែកនីតិប្បញ្ញត្តិ

- ប្រធាន ឬប្រធានស្តីទីមានភារៈចូលរួមក្នុងការប្រជុំរបស់ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា តាមការអញ្ជើញរបស់ប្រធានរដ្ឋសភាសមាជិកគណៈកម្មការមានភារៈចូលរួមក្នុងក្រុមមិត្តភាពសភា ឬអង្គការអន្តរសភាទៅតាមសេចក្តីសម្រេចរបស់ប្រធានរដ្ឋសភា។

**ឈ. គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហៅកាត់ថា គណៈកម្មការទី៩ សរសេរកាត់ថា គ.៩ មានភារកិច្ចរួម ដូចតទៅ៖

- ពិនិត្យសិក្សា ស្រាវជ្រាវសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ប្រគល់ភារកិច្ចជូន

- នាំយកយោបល់របស់គណៈកម្មការជម្រាបជូនរដ្ឋសភាក្នុងសម័យប្រជុំពេញអង្គ អំពីការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់

- ចូលរួម និងរៀបចំសិក្ខាសាលា ឬកិច្ចប្រជុំពិគ្រោះយបល់ជាសាធារណៈជាមួយ អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ។ល។

- បំពេញភារកិច្ចផ្សេងៗទៀតដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ឬប្រធានរដ្ឋសភាប្រគល់ជូន។ របៀបរបបធ្វើការងារ និងការបែងចែកភារកិច្ចទទួលខុសត្រូវរបស់សមាជិកគណៈកម្មការត្រូវកំណត់ដោយប្រធានគណៈកម្មការ។

**ញ. គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ**

គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ ហៅកាត់ថា គណៈកម្មការទី១០ សរសេរកាត់ថា គ.១០ មានភារកិច្ចរួម ដូចតទៅ៖

- ពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបានប្រគល់ជូន ព្រមទាំងនាំយកយោបល់របស់គណៈកម្មការជម្រាបជូនរដ្ឋសភាក្នុងសម័យប្រជុំពេញអង្គ អំពីការ

ពិនិត្យ សិក្សាសេចក្ដីព្រាងច្បាប់ និងសេចក្ដីស្នើច្បាប់ ចូលរួម និងរៀបចំសិក្ខាសាលា ឬកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈជាមួយអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ។ល។

- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយគណៈកម្មការសភានៃបណ្ដាប្រទេសដើម្បីពង្រឹង និងផ្លាស់ប្ដូរបទពិសោធន៍ពីគ្នាទៅវិញទៅមកផ្នែកនីតិប្បញ្ញត្តិ ប្រធាន ឬប្រធានស្ដីទីមានភារៈ ចូលរួមក្នុងការប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា តាមការអញ្ជើញរបស់ប្រធានរដ្ឋសភា សមាជិកគណៈកម្មការមានភារៈចូលរួមក្នុងក្រុមមិត្តភាពសភា ឬអង្គការអន្តរសភា ទៅតាមសេចក្ដីសម្រេចរបស់ប្រធានរដ្ឋសភា បំពេញការងារផ្សេងៗទៀតដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងប្រធានរដ្ឋសភា ប្រគល់ជូន។

### ១.១.៣ លក្ខខណ្ឌនៃការឈរឈ្មោះ និងមិនអាចឈរឈ្មោះជាតំណាងរាស្ត្រ

#### ១.១.៣.១ លក្ខខណ្ឌនៃការឈរឈ្មោះ

តំណាងរាស្ត្រ ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។ តំណាងរាស្ត្រ អាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានអាយុយ៉ាងតិច ២៥ឆ្នាំ។
- មានសញ្ជាតិជាខ្មែរតាំងពីកំណើត គឺសំដៅជាជនជាតិខ្មែរ និងសញ្ជាតិខ្មែរ។
- មានសិទ្ធិបោះឆ្នោត និងមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត។
- មានការតែងតាំង ពីគណបក្សនយោបាយណាមួយ ដែលបានចុះនៅក្នុងបញ្ជីបោះឆ្នោតហើយ[៥]។

#### ១.១.៣.២ លក្ខខណ្ឌនៃការមិនអាចឈរឈ្មោះ

តាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានហាមមិនឲ្យ ឈ្មោះចំពោះបុគ្គលដូចខាងក្រោម៖

- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ ឬកងយោធពលខេមរភូមិន្ទក្នុងមុខតំណែង និងបុព្វជិតសាសនា។

- ជនដែលត្រូវបានតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារ ពីបទល្មើសព្រហ្មទណ្ឌមាន(បទឧក្រិដ្ឋ ឬបទមជ្ឈិម) ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ។

- ជនដែលត្រូវបានផ្ដន្ទាទោសដកសិទ្ធិបោះឆ្នោត។

- ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាល ដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច។

- ជនដែលត្រូវដកហូតជាបណ្ដោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវ បានលុបឈ្មោះចេញពីបញ្ជី

[៥] មាត្រា៣៣ថ្មី, ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ, ឆ្នាំ២០១៥។

បោះឆ្នោតដោយគណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

- សមាជិកគណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ
- សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។
- សមាជិកព្រឹទ្ធសភា។
- សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ[9]។

### ១.១.៤ នីតិវិធីនៃការចូលកាន់ដំណែងរបស់សមាជិករដ្ឋសភា

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។ មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវ ប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។[10]

នៅពេលបើកសម័យប្រជុំលើកទី១នៃនីតិកាលនីមួយៗរដ្ឋសភា ត្រូវចាប់ដំណើរការក្រោមអធិបតីភាពប្រធានបណ្តោះអាសន្នមួយរូប ដែលជាបេក្ខជនជាប់ឆ្នោត មានអាយុច្រើនជាងគេដែលមានវត្តមាន ហើយមានសមាជិកប្រាំ រូប ដែលជាបេក្ខជនជាប់ឆ្នោតមានអាយុតិចជាងគេដែលមានវត្តមាន ជាលេខាធិការដើម្បីជួយប្រធានក្នុងការងារ។ ការបើកសម័យប្រជុំនេះអាចធ្វើក្នុងស្ថានភាពធម្មតា ឬអាចក្នុងស្ថានភាពនយោបាយតម្រូវឲ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ។

#### ១.១.៤.១ ករណីធម្មតា

ក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិករដ្ឋសភា ប្រសិនបើមានកូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល រដ្ឋសភាត្រូវចាប់ផ្តើមធ្វើការតាមរបៀបវារៈដូចតទៅៈ

- សម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ
- បោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន និងអនុប្រធានទាំងពីររបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករសដ្ឋភាទាំងមូល។

#### ១.១.៤.២ ករណីពិសេស

ករណីដែលស្ថានភាពនយោបាយតម្រូវឲ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិករដ្ឋសភា ប្រសិនបើមានកូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល រដ្ឋសភាត្រូវចាប់ផ្តើមធ្វើការតាមរបៀបវារៈដូចតទៅៈ

-សម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ

[9] មាត្រា៣៣ថ្មី, ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ, ២០១៥។

[10] មាត្រា៨២ថ្មី, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

-បោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំងប្រធាន អនុប្រធាន ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាលនៅដើមនីតិកាលនីមួយៗ ដោយវិធីលើកដៃ និងដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

ចំពោះការបើកសម័យប្រជុំទាំងពីរករណីខាងលើគឺ សមាជិករដ្ឋសភាមិនអាចជជែកពិភាក្សាអ្វីឡើយនៅក្រោមអធិបតីភាពរបស់ព្រឹទ្ធសមាជិក។ លើសពីនេះ តំណាងរាស្ត្រទាំងអស់ត្រូវតែធ្វើសច្ចាប្រណិធានមុនពេលចូលកាន់មុខតំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥នៃរដ្ឋធម្មនុញ្ញ។[11]

### ១.១.៥ សុពលភាពអ្នកតំណាងរាស្ត្រ

នៅពេលបើកសម័យប្រជុំដំបូងនៃនីតិកាលនីមួយៗ ព្រឹទ្ធសមាជិករដ្ឋសភាត្រូវតែប្រកាសជូនអង្គសភាបានជ្រាបៈ

- ឈ្មោះបេក្ខជនជាប់ឆ្នោតជាស្ថាពរ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបញ្ជូនមក។

- ឈ្មោះបេក្ខជនជាប់ឆ្នោត ដែលត្រូវបានគេប្តឹងតវ៉ា ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានបដិសេធបណ្តឹងទាំងនោះ។

ឈ្មោះតំណាងរាស្ត្រពេញសិទ្ធិទាំងអស់ ដែលបានសម្រេចសុពលភាពរួចត្រូវបានបិតផ្សាយនៅក្នុងរដ្ឋសភា និងផ្សព្វផ្សាយជាសាធារណៈ។[12] មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវ ប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ។[13]

### ១.១.៦ តួនាទីអ្នកតំណាងរាស្ត្រ និងការបាត់បង់សមាជិកភាពសភា

#### ១.១.៦.១ តួនាទីអ្នកតំណាងរាស្ត្រ

អ្នកតំណាងរាស្ត្រមានតួនាទីជាអ្នកអ្នកផ្តួចផ្តើមច្បាប់ និងតាមដានការអនុវត្តរបស់រដ្ឋាភិបាល។ តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលបានទេ បើសិនវិសោធនកម្មច្បាប់សំដៅដល់ការកាត់-បន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ។[14]

[11] ប្រការ២ថ្មី(ពីរ), បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[12] ប្រការ៣ថ្មី(ពីរ), បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[13] មាត្រា៨២ថ្មី, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[14] មាត្រា៩១ថ្មី, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

អ្នកតំណាងរាស្ត្រ គ្រប់រូបអាចស្នើសុំធ្វើវិសោធនកម្ម ទៅលើសេចក្ដីព្រាងសេចក្ដីស្នើច្បាប់បាន។ ពាក្យសុំធ្វើវិសោធនកម្មនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរជូនទៅគណៈកម្មការជំនាញក៏បាន ឬជូនទៅរដ្ឋសភាក្នុងពេល ប្រជុំពេញអង្គក៏បាន[15]។ តំណាងរាស្ត្រ គឺមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល សំណួរទាំងអស់នេះត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូបអាស្រ័យដោយបញ្ហា ដែលបានចោទឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាលនាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន។ ចម្លើយរបស់រដ្ឋមន្ត្រី របស់នាយករដ្ឋមន្ត្រីអាចធ្វើដោយផ្ទាល់មាត់ ឬសរសេរលាយលក្ខណ៍អក្សរ។ ចម្លើយខាងលើនេះត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃបន្ទាប់ពីបានទទួលសំណួរហើយ។

បើមានការបើកឲ្យជជែកដេញដោល ម្ចាស់សំណួរ វាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធ ឬនាយករដ្ឋមន្ត្រីអាចជជែកផ្លាស់ប្ដូរយោបល់ ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្ដាហ៍ សម្រាប់ធ្វើការឆ្លើយសំណួរ។ ទោះបីយ៉ាងណាក៏ដោយសម័យប្រជុំសម្រាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឲ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ។ តំណាងរាស្ត្រដែលបានតាំងសំណួរចំពោះរដ្ឋមន្ត្រីណាមួយ អាចសុំដកលិខិតតាំងជាសំណួររបស់ខ្លួនចេញបាន។

#### ១.១.៦.២ ការបាត់បង់សមាជិកភាពសភា

អាសនៈរបស់តំណាងរាស្ត្រដែលនៅទំនេរ ដោយការលាលែង ដោយបោះបង់ចោលការងារចំនួនបីខែគ្មានការអនុញ្ញាត ដោយទទួលមរណភាព ដោយប្រាសចាកសមាជិកភាពរដ្ឋសភា ឬដោយប្រាសចាកសមាជិកភាពពីគណៈបក្សជាប់ឆ្នោតត្រូវបំពេញជំនួសវិញ ដោយតំណាងរាស្ត្រថ្មីលំដាប់លេខរៀងបន្ទាប់ ដែលជ្រើសរើសក្នុងបញ្ជីបេក្ខជនឈរឈ្មោះតំណាងគណបក្សក្នុងមណ្ឌលជាមួយគ្នា។[16]

### ១.១.៧ អភ័យឯកសិទ្ធិសភា

តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ បន្ថែមពីនេះ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃរដ្ឋសភា នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្ដែង។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្ដីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ ដើម្បីសម្រេច។

---

[15] ប្រការ២៦, បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[16] ប្រការ៨៣ថ្មី, បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។ ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួនការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឲ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល។[17]

### ១.១.៨ អំពីវិសមិតភាព

អាណត្តិនៃសមាជិករដ្ឋសភា មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈ ជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល។ ក្នុងករណីនេះសមាជិករដ្ឋសភារូបនោះមានឋានៈជាសមាជិករដ្ឋសភាធម្មតា ហើយមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភា។[18]

### ១.១.៩ ការប្រជុំនៅក្នុងរដ្ឋសភា

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ។ រដ្ឋសភាអាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី។ ការប្រជុំរបស់រដ្ឋសភាអាចប្រព្រឹត្តទៅដោយសាមញ្ញ វិសាមញ្ញ និងរាល់ថ្ងៃ។

#### ១.១.៩.១ ការប្រជុំជាសាមញ្ញ

ការប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ។ សម័យប្រជុំនីមួយៗមានថិរៈវេលាយ៉ាងតិចបីខែ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិករដ្ឋសភាចំនួនមួយភាគបីយ៉ាងតិចគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា កោះប្រជុំរដ្ឋសភាជាវិសាមញ្ញ។ ក្នុងករណីនេះ របៀបវារៈជាក់លាក់នៃសម័យប្រជុំជាវិសាមញ្ញត្រូវផ្សាយដល់ប្រជារាស្ត្រ ជាមួយនឹងថ្ងៃកំណត់ប្រជុំត្រូវធ្វើជាសាធារណៈ។

#### ១.១.៩.២ ការប្រជុំវិសាមញ្ញ

ការប្រជុំវិសាមញ្ញ គឺជាការប្រជុំមួយនៅចន្លោះសម័ប្រជុំជាសាមញ្ញ ដែលការប្រជុំនេះអាចធ្វើបានក្នុងករណីមានការចាំបាច់ និងជាការបន្ទាន់ណាមួយដែលទាក់ទងនឹងបញ្ហាសំខាន់ៗរបស់សភាជាតិ។ រដ្ឋសភាអាចកោះហៅប្រជុំវិសាមញ្ញបាន ប្រសិនបើមានសំណូមពរពីព្រះមហាក្សត្រ ឬតាមសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬមានការស្នើពីសមាជិករដ្ឋសភាចំនួនមួយភាគបីយ៉ាងតិច។[19]

#### ១.១.៩.៣ ការប្រជុំរាល់ថ្ងៃ

ការប្រជុំរាល់ថ្ងៃជាប្រចាំ គឺធ្វើឡើងនៅពេលប្រទេសជាតិស្ថិតក្នុងភាពចាំបាច់ ឬកាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រដ្ឋសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ។ រដ្ឋសភាមានសិទ្ធិសម្រេចបញ្ចប់កាលៈ

[17] មាត្រា៨០, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[18] មាត្រា៧៩, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[19] មាត្រា៨៣, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

ទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត។ នៅពេលដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រដ្ឋសភាមិនអាចត្រូវរំលាយបានឡើយ។[20]

**១.៩.៤ កូរ៉ុមនៃការប្រជុំ**

ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមាន៖

**ក**- កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឲ្យយកមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

**ខ**- កូរ៉ុមលើសពីពាក់កណ្តាល នៃចំនួនសមាជិករដ្ឋសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឲ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។[21]

សមាជិករដ្ឋសភាដែលអវត្តមានត្រូវបានចុះក្នុងបញ្ជីអវត្តមានហើយបញ្ជីនេះ ត្រូវបានប្រកាសតាមរយៈប្រធានរដ្ឋសភាដោយបញ្ជាក់អំពីមូលហេតុផង។ ប្រធានរដ្ឋសភាត្រូវផ្អាកការប្រជុំ ប្រសិនបើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល១៥នាទី បន្ទាប់ពីហួសពេលកំណត់នៃការចាប់ផ្តើមប្រជុំ។

**១.១.១០ ការអនុម័តច្បាប់**

ការអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ត្រូវចាប់ផ្តើមពិភាក្សាក្នុងនាមសមាជិកសភា ដែលការពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវធ្វើឡើងដោយបោះឆ្នោត ដោយអង្គសភាអាចលើកយកមកពិភាក្សា និងអនុម័ត៖

- ទៅលើខ្លឹមសារទាំងមូល ថាតើគួរទទួលពិចារណាឬទេ?
- ទៅលើមួយមាត្រាម្តងៗក៏បាន។
- ទៅលើមួយជំពូកម្តងៗក៏បាន។

បន្ថែមលើសពីនេះទៅទៀត អង្គសភាអាចប្រើនីតិវិធីពិភាក្សាជាសង្ខេបបាន ដោយពិភាក្សាតែមាត្រាណាមួយ ឬជំពូកណាមួយ ដែលមានសំណើធ្វើវិសោធនកម្មជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ។

ករណីដែលនឹងត្រូវប្រើនីតិវិធីណាមួយខាងលើ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវជូនព័ត៌មានដល់អ្នកតំណាងរាស្ត្រជាមុនសិន។ អង្គសភាអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងមូល។ រដ្ឋសភាអាចអនុម័តទាក់ទងបញ្ហាផ្សេងៗ ទៅតាមនីតិវិធីបីយ៉ាងគឺ៖ ការអនុម័តបោះឆ្នោតដោយវិធីលើកដៃ ការអនុម័តបោះឆ្នោតជាចំហ និងការអនុម័តបោះឆ្នោតដោយសម្ងាត់។

**១.១.១០.១ ការអនុម័តដោយវិធីលើកដៃ**

---

[20] មាត្រា៨៦, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[21] មាត្រា៨៨-៣ថ្មី(ពីរ), រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

អនុម័តនេះគឺប្រធាន និងលេខាទាំងឡាយជាអ្នករាប់ចំនួនសមាជិកដែលអនុម័ត។ បើប្រធាន និងលេខាយល់ឃើញថា ការលើកដៃអនុម័តនេះ មិនមានភាពច្បាស់លាស់ទេនោះ ត្រូវធ្វើទៅតាមនីតិវិធីដដែល សារជាថ្មីម្តងទៀត។ ប្រសិនបើការលើកដៃអនុម័តពីរដងហើយ នៅតែមិនទទួលបានលទ្ធផលច្បាស់លាស់ទេនោះ គឺគេត្រូវអនុវត្តដោយការអនុម័តបោះឆ្នោតជាចំហវិញ។

**១.១.១០.២ ការអនុម័តដោយចំហ**

ការអនុម័តបោះឆ្នោតជាចំហ គឺជាការបោះឆ្នោត ដែលមានអាជ្ញាសភាជាអ្នកកាន់ហិបឆ្នោតដើរប្រមូលយកសន្លឹកឆ្នោតពីសមាជិករដ្ឋសភា។ សមាជិករដ្ឋសភាត្រូវតែសរសេរឈ្មោះរបស់ខ្លួននៅលើសន្លឹកឆ្នោតដែលសន្លឹកឆ្នោតមានសណ្ឋានបីពណ៌ គឺមានពណ៌ខៀវ គឺមានន័យថា មិនយល់ព្រម រីឯពណ៌ស គឺមានន័យថា យល់ព្រម និងពណ៌សឆ្នូតខៀវ គឺមានន័យថា អនុប្បវាទ ។

ក្រោយពីបានបោះឆ្នោតរួចស្រេច លេខាធិការរាប់សន្លឹកឆ្នោតហើយ ប្រធានរដ្ឋសភាជាអ្នកប្រកាសជូនអង្គសភាទាំងមូលបានជ្រាប។ ការអនុម័តបោះឆ្នោតជាចំហនៅលើវេទិការ គឺជាការបោះឆ្នោតអនុម័តមួយប្រភេទដែលសមាជិករដ្ឋសភាម្នាក់ៗ ត្រូវដើរទៅយកសន្លឹកឆ្នោតមកបោះក្នុងហិបឆ្នោត ដែលបានដាក់នៅលើវេទិការការអនុម័តបោះឆ្នោតជាចំហនៅលើវេទិការនេះ អាចធ្វើទៅបានលុះត្រាតែមានសមាជិករដ្ឋសភាចំនួនដប់រូបយ៉ាងតិចស្នើសុំ។[22]

**១.១.១០.៣ ការអនុម័តដោយសម្ងាត់**

ការអនុម័តបោះឆ្នោតដោយសម្ងាត់ គឺជាការបោះឆ្នោតមួយប្រភេទ អ្នកតំណាងរាស្ត្រមិនសរសេរឈ្មោះរបស់ខ្លួននៅលើសន្លឹកឆ្នោតនោះទេ។ វិធីបោះឆ្នោតដោយសម្ងាត់នេះ ត្រូវបានគេយកមកប្រើក្នុងការអនុម័តបោះ-ឆ្នោតលើករណីមួយចំនួនដូចជា៖

- ផ្តល់សេចក្តីទុកចិត្តបង្កើតរាជរដ្ឋាភិបាល
- អនុម័តក្នុងការបង្កើត និងជ្រើសតាំងសមាជិកព្រឹទ្ធសភា២រូប
- អនុម័តច្បាប់ និងអនុម័តច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញ
- អនុម័តញត្តិបន្ទោស
- អនុម័តកិច្ចការទាំងឡាយរបស់ប្រទេសជាតិជាច្រើនទៀត។

ការអនុម័តទាំងឡាយ ត្រូវបានអនុម័តតាមមតិភាគច្រើនដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ។ ក្រៅពីនេះមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ត្រូវចាត់ទុកថាជាបានការ បើចំនួនមតិយល់ព្រមនិងចំនួនមតិមិនយល់ព្រមស្មើគ្នានោះ ការបោះឆ្នោតត្រូវធ្វើម្តងទៀត។ បើលទ្ធផលនៃការបោះឆ្នោតលើកទី២ នៅមានសម្លេងស្មើគ្នា ត្រូវចាត់ទុកថារដ្ឋសភាមិនយល់ព្រម។

[22] ប្រការ៣៩, បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

### ១.១.១១ អាណត្តិរបស់រដ្ឋសភា

នីតិកាលរបស់រដ្ឋសភាមានកំណត់៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈពេល១២ខែ។ ក្នុងករណីនេះ ព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា។ ការបោះឆ្នោតដើម្បីជ្រើសរើសរដ្ឋសភាថ្មី នឹងប្រព្រឹត្តទៅក្នុងរយៈពេល៦០ថ្ងៃយ៉ាងយូរ ចាប់តាំងពីថ្ងៃរំលាយរដ្ឋសភាមក។ ក្នុងរយៈកាលនេះរាជរដ្ឋាភិបាលមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ។ ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ។ ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសម្រេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិករដ្ឋសភាទាំងមូល[23]។

អាណត្តិនៃសមាជិករដ្ឋសភា មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល។ ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះមានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភា[24]។

### ១.១.១២ ការគ្រប់គ្រងអគ្គលេខាធិការដ្ឋានរដ្ឋសភា

ត្រូវបានរៀបចំ និងប្រព្រឹត្តទៅស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រមនីតិប្បញ្ញត្តិ ហើយមានតួនាទីជាសេនាធិការផ្ទាល់របស់រដ្ឋសភា ដែលផ្តល់សេវាទ្រទ្រង់លើការងារទូទៅដើម្បីធានាឲ្យមាននិរន្តរភាពនៃកិច្ចការនានារបស់រដ្ឋសភាស្របតាមរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ព្រមទាំងច្បាប់ពាក់ព័ន្ធជាធរមាន[25]។

#### ១.១.១២.១ រចនាសម្ព័ន្ធដឹកនាំ

អគ្គលេខាធិការដ្ឋានរដ្ឋសភាត្រូវបានដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួន និងមានទីប្រឹក្សាអមអគ្គលេខាធិការដ្ឋានមួយចំនួនតាមការចាំបាច់។ អគ្គលេខាធិការរដ្ឋសភាត្រូវទទួលបន្ទុកជាអគ្គលេខាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា។ គ្រប់អង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋានរដ្ឋសភា មានភារកិច្ចជួយអគ្គលេខាធិការរដ្ឋសភា ក្នុងការអនុវត្តរាល់កិច្ចការគាំទ្រដល់សមាជរដ្ឋសភា និង

[23] មាត្រា៧៨, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[24] មាត្រា៧៩, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[25] ប្រការ១៥ថ្មី(ពីរ), បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

ព្រឹទ្ធសភា ដូចមានចែងក្នុងច្បាប់ និងបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា។ អគ្គលេខាធិការដ្ឋានរដ្ឋសភាមានអង្គភាពចំណុះមួយចំនួនដូចខាងក្រោមៈ

១-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

២-អគ្គនាយកដ្ឋាននីតិកម្ម និងស្រាវជ្រាវ

៣-អគ្គនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ពិធីការ និងព័ត៌មាន

៤-អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍

៥-អគ្គាធិការដ្ឋាន

៦-អង្គភាពលទ្ធកម្ម

៧-នាយកដ្ឋានសវនកម្មផ្ទៃក្នុង

៨-នាយកដ្ឋានសន្តិសុខ

៩-ការិយាល័យលេខាធិការ។

**១.១.១២.២ តួនាទីភារកិច្ចរបស់អគ្គលេខាធិការរដ្ឋសភា**

អគ្គលេខាធិការដ្ឋាននៃរដ្ឋសភាមានតួនាទីភារកិច្ចដូចតទៅៈ

- ជាអ្នកលើកសំណើទៅប្រធានរដ្ឋសភា ដើម្បីចេញសេចក្តីសម្រេចបង្កើតគណៈកម្មការនានារបស់រដ្ឋសភា យោងតាមការចាំបាច់ដែលមានសមាសភាពតិច ឬច្រើនអាស្រ័យទៅតាមទំហំនៃការងារ។ គណៈកម្មការនេះនឹងរលាយទៅវិញនៅពេលដែលគណៈកម្មការបានបំពេញការងារចប់ជាស្ថាពរ។

- ជាអ្នករៀបចំគ្រប់គ្រងការងាររដ្ឋបាល និងសេវានានាជូនរដ្ឋសភា ព្រមទាំងគណៈកម្មការជំនាញទាំងអស់ក្នុងរដ្ឋសភា។

- ជាអ្នករៀបចំកំណត់ហេតុនានា គ្រប់ការប្រជុំរបស់រដ្ឋសភា និងគណៈកម្មនានាក្នុងរដ្ឋសភា[26]។

- ជាអ្នកលើកសំណើរជូន ប្រធានរដ្ឋសភា អំពីការតែងតាំងតែងតាំងមន្ត្រីបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋានរដ្ឋសភាស្របតាមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

- ជាអ្នកធ្វើបញ្ជីឈ្មោះចំពោះមន្ត្រីបុគ្គលិកនៅតាមការិយាល័យនានា ដែលមានស្នាដៃនិងគុណបំណាច់ខ្ពស់ក្នុងកាបំពេញភារកិច្ចជូនអគ្គលេខាធធិការដ្ឋានទៅគណៈកម្មការវាយតម្លៃ និងស្នើសុំប្រធានរដ្ឋសភាធ្វើការបំពាក់គ្រឿងឥស្សរិយយសជូនមន្ត្រិ បុគ្គលិកដែលមានស្នាដៃល្អ។

- ជាអ្នកគ្រប់គ្រងបុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។

- ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋសភា។

[26] ប្រកា១៤ថ្មី(ពីរ), បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

- ជាអ្នករៀបចំសណ្តាប់ធ្នាប់ សន្តិសុខ អនាម័យនៅក្នុងរដ្ឋសភាទាំងមូល។

- ជាអ្នកគ្រប់គ្រង និងបញ្ជាផ្ទាល់ទៅលើការចំណាយផ្សេងៗរបស់អគ្គលេខាធិកាដ្ឋានរដ្ឋសភា ដោយមានការសហការជាមួយអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។

## ១.២. រចនាសម្ព័ន្ធ និងដំណើរប្រព្រឹត្តិទៅរបស់ព្រឹទ្ធសភា

### ១.២.១ លក្ខខណ្ឌ និងកិច្ចដំណើរការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

ការរៀបចំបែបបទ និងការប្រព្រឹត្តទៅនៃការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត ត្រូវកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើង៦ឆ្នាំម្តង នៅថ្ងៃអាទិត្យសប្តាហ៍ទី៨មុនដំណាច់ឆ្នាំទី៦ នៃនីតិកាលព្រឹទ្ធសភា លើកលែងតែក្នុងករណីដែលមានចែងក្នុងបទប្បញ្ញត្តិមាត្រា១០២ថ្មី នៃរដ្ឋធម្មនុញ្ញ។កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។នីតិកាលព្រឹទ្ធសភា ត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។ ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើន ស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ សមាជិកព្រឹទ្ធសភាត្រូវបានកើតឡើងដោយ៖

- សមាជិកព្រឹទ្ធសភា ចំនួនពីររូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ។

- សមាជិកព្រឹទ្ធសភា ចំនួនពីររូប ត្រូវបានរដ្ឋសភាជ្រើសតាំង តាមមតិភាគច្រើនដោយប្រៀប។

- រីឯសមាជិកព្រឹទ្ធសភាឯទៀត ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកល មិនចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។

ការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមប្រព័ន្ធ សមាមាត្រ និងការបែងចែកអាសនៈតាមមណ្ឌល ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត។ [27]មណ្ឌលបោះឆ្នោតរបស់សមាជិកព្រឹទ្ធសភា មានចំនួន ៨ភូមិភាគ។ សមាជិកព្រឹទ្ធសភាក្នុងព្រឹទ្ធសភា គឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងឲ្យភូមិភាគរបស់ខ្លួននោះទេ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា។ ក្នុងនីតិកាលរបស់ព្រឹទ្ធសភា អាសនៈរបស់សមាជិកព្រឹទ្ធសភា ត្រូវប្រកាសថានៅទំនេរ ក្នុងករណីលាលែង បោះបង់ចោលការងារមកពីវិសមិតភាព ប្រាសចាកសមាជិកភាព ឬទទួលអនិច្ចកម្ម។ អាសនៈរបស់

[27] មាត្រា១៣៥, ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ, ឆ្នាំ២០១៥។

សមាជិកព្រឹទ្ធសភា ដែលនៅទំនេរយ៉ាងតិច៦ខែ មុនចប់នីតិកាលត្រូវបំពេញជំនួសដោយសមាជិកថ្មី ចេញពីប្រភពដើម ដែលមានអាសនៈទំនេរនោះ ដោយមិនចាំបាច់បោះឆ្នោតសារឡើងវិញទេ។

**១.២.១.១ លក្ខខណ្ឌនៃការឈរឈ្មោះ**

ចំពោះបេក្ខជនសមាជិកព្រឹទ្ធសភា ប៉ុន្តែបេក្ខជន នោះត្រូវមានអាយុយ៉ាងតិច ៤០ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត ហើយជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនសមាជិកព្រឹទ្ធសភា។ បេក្ខជិកព្រឹទ្ធសភា ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមនេះ៖

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុ៤០ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត
- មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- មានការតែងតាំងពីគណបក្សនយោបាយណាមួយ ដែលបានចុះក្នុងបញ្ជីឈរឈ្មោះបោះឆ្នោត។

**១.២.១ .២ លក្ខខណ្ឌមិនអាចឈរឈ្មោះ**

លក្ខខណ្ឌដែលមិនអាចឈរឈ្មោះជាបេក្ខជនបោះឆ្នោត ដើម្បីជ្រើសរើសសមាជិកព្រឹទ្ធសភារួមមាន៖

- មន្ត្រីរាជការស៊ីវិល មន្ត្រីរាជការ កងងម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ ក្នុងមុខតំណែង និងបុព្វជិតសាសនា។
- ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ពីបទល្មើសឧក្រិដ្ឋ ឬបទបជ្ជិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត
- ជនដែលវិកលចរិត ឬជនដែលស្ថិតក្រោមអាណាព្យាបាល ដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច
- ជនដែលត្រូវបានដកហូតជាបណ្តោះអាសន្ននៅសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះ ពីបញ្ជីបោះឆ្នោត ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- សមាជិកនៃគណៈកម្មធិការជាតិ ឬគណៈកម្មធិការរៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ
- សមាជិកនៃឧត្តមក្រុមព្រឹក្សានៃអង្គចៅក្រម
- សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។

**១.២.១ .៣ លក្ខខណ្ឌឈរឈ្មោះចំពោះអ្នកច្បាប់ហាម**

ការឈរឈ្មោះជាបេក្ខជនសមាជិកព្រឹទ្ធសភា ដែលអ្នកទាំងនោះជាមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមព្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមព្រឹក្សានៃអង្គ

ចៅក្រម និងបុព្វជិតសាសនា ដែលមានបំណងឈរឈ្មោះបោះឆ្នោត ជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ត្រូវដាក់ពាក្យសុំច្បាប់ ឈប់សម្រាកជាពិសេស ឬក៏លាចាកសិក្ខាបទ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោត នៃការបោះឆ្នោតជាស្ថាពរ ជាស្ថាពរយ៉ាងតិចប្រាំពីរថ្ងៃ។

ប្រសិនបើសាមីខ្លួនបានជាប់ឆ្នោតហើយ សាមីខ្លួនត្រូវធ្វើពាក្យសុំលាតាមឋានានុក្រមទៅសាមីក្រសួងឬសាមីអង្គភាព ដើម្បីទៅបម្រើការងារក្រៅក្របខ័ណ្ឌដើមក្នុងរយៈពេលអាណត្តិរបស់ខ្លួន។

ក្នុងរយៈពេលដែលស្ថិតនៅក្រៅក្របខ័ណ្ឌដើម សាមីខ្លួនត្រូវមានសិទ្ធិឡើងឋានន្តរសក្តិ និងឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាពការងារ សម្រាប់ទទួលសោធននិវត្តន៍។

នៅពេលចប់អាណត្តិជាសមាជិកព្រឹទ្ធសភា សាមីខ្លួនអាចសុំត្រឡប់មកបម្រើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារ និងតួនាទី គឺអាស្រ័យដោយសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសម្រេច។

### ១.២.២ បុព្វសិទ្ធិសមាជិកភាព និងអភ័យឯកសិទ្ធិសភា

#### ១.២.២.១ បុព្វសិទ្ធិសមាជិកភាព

សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា។ សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងដោយព្រះមហាក្សត្រ ជ្រើសតាំងដោយរដ្ឋសភា និងគណបក្សនយោបាយដែលមានអាសនៈតិចជាងដប់ អាចជ្រើសរើសចូលជាមួយក្រុមណាមួយតាមការពេញចិត្តរបស់ខ្លួន។ បញ្ជីរាយនាមរបស់ក្រុមសមាជិកព្រឹទ្ធសភាត្រូវផ្ញើជូនប្រធានព្រឹទ្ធសភា ។

#### ១.២.២.២ អភ័យឯកសិទ្ធិសភា

អភ័យឯកសិទ្ធិសភា ត្រូវបានចែកចេញជាពីរផ្នែកគឺ អភ័យឯកសិទ្ធិដាច់ខាត និងអភ័យឯកសិទ្ធិដោយប្រៀប។

**ក. អភ័យឯកសិទ្ធិដាច់ខាត**

អភ័យឯកសិទ្ធិដាច់ខាត ជាការធានាក្នុងការបញ្ចេញយោបល់ ឬការបញ្ចេញមតិក្នុងការអនុម័តទាំងឡាយរបស់សមាជិកព្រឹទ្ធសភា នៅក្នុងក្របខ័ណ្ឌនៃការបំពេញតួនាទីជាសមាជិកព្រឹទ្ធសភា។

**ខ. អភ័យឯកសិទ្ធិដោយប្រៀប**

អភ័យឯកសិទ្ធិដោយប្រៀបជាការធានាមិនឲ្យមានការចោទប្រកាន់ ការចាប់ខ្លួន ឬការឃុំខ្លួនសមាជិកព្រឹទ្ធសភាណាមួយ។ សមាជិកព្រឹទ្ធសភាមិនអាចឆ្លៀតប្រើអភ័យឯកសិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។ ប្រសិនបើបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ គឺអាចអនុញ្ញាតធ្វើការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនតាមច្បាប់ និងនីតិវិធីបាន លុះត្រាតែមានការលើកអភ័យឯកសិទ្ធិសភាជាមុនសិន។ ការស្នើសុំលើកអភ័យឯកសិទ្ធិសភារបស់សមាជិកព្រឹទ្ធសភារូបណាមួយ ត្រូវធ្វើឡើងដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផង ផ្ញើជូនប្រធានព្រឹទ្ធសភា។

ការលើកអភ័យឯកសិទ្ធិសភាក្នុងរយៈពេលសម័យប្រជុំព្រឹទ្ធសភាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

-ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់តាមការស្នើសុំពីប្រធាន ឬពីសមាជិកព្រឹទ្ធសភា ចំនួនមួយភាគដប់យ៉ាងតិចពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា។

-កូរ៉ុមប្រជុំលើសពីពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល។

-ការអនុម័តតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។[28]

ការលើកអភ័យឯកសិទ្ធិសភាក្នុងចន្លោះសម័យប្រជុំព្រឹទ្ធសភា គឺគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវប្រជុំ និងអនុម័តស្របតាមបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា។ សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធ-សភា ត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធ-សភាទាំងមូល។ ក្នុងករណីសមាជិកព្រឹទ្ធសភាណា បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ក្រសួងមានសមត្ថកិច្ចអាចចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនបាន ហើយត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំព្រឹទ្ធសភាជាបន្ទាន់ដើម្បីសម្រេច។

### ១.២.៣ តួនាទីសមាជិកព្រឹទ្ធសភា

ព្រឹទ្ធសភាមានសមាជិកទាំងអស់យ៉ាងច្រើនស្មើពាក់កណ្តាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល។[29] ពហុនិយមខាងនយោបាយ ត្រូវអនុវត្តដោយថ្លៃថ្នូរ មានគុណធម៌ និងសុជីវធម៌ ក្នុងក្របខ័ណ្ឌនៃក្រមសីលធម៌សមាជិកព្រឹទ្ធសភាគ្មានការរំលោភបំពាន និងគ្មានការរើសអើងសក្តិសមទៅនឹងលក្ខន្តិកៈទូទៅ របស់សមាជិកព្រឹទ្ធសភា ដែលជាតំណាងឲ្យភូមិភាគ និងប្រជាជាតិខ្មែរទាំងមូល។

ក្រុមសមាជិកព្រឹទ្ធសភាបំពេញតួនាទី ដើម្បីប្រមូលផ្តុំបញ្ញាញាណនយោបាយរបស់ព្រឹទ្ធសភាសំដៅបម្រើឲ្យការបញ្ចេញយោបល់របស់តំណាងក្រុមនៅក្នុងសម័យប្រជុំព្រឹទ្ធសភា។ ក្រុមសមាជិកព្រឹទ្ធសភាមានភារ-កិច្ចដូចខាងក្រោម ៖

- រួមគ្នាពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដើម្បីរៀបចំតំណាងក្រុម យោបល់ក្នុងនាមក្រុមនៅក្នុងសម័យប្រជុំព្រឹទ្ធសភា និងប្រកាន់ជំហររួមរបស់ក្រុមក្នុងការអនុម័ត។
- រួមគ្នាផ្តួចផ្តើមគំនិត ស្នើច្បាប់ ឬស្នើវិសោធនកម្មច្បាប់
- រួមគ្នាប្រជុំ ដើម្បីចែករំលែកព័ត៌មាន ពិគ្រោះគ្នាកំណត់គោលជំហររបស់ក្រុមទៅលើបញ្ហាបច្ចុប្បន្នភាពណាមួយ ដែលក្រុមត្រូវយកចិត្តទុកដាក់ក្នុងការថ្លែង ឬប្រកាសជំហរជាសាធារណៈ ។

ជាគោលការណ៍ រយៈពេលបញ្ចេញយោបល់សម្រាប់ក្រុមសមាជិកព្រឹទ្ធសភានីមួយៗត្រូវបានកំណត់។ សមាជិកព្រឹទ្ធសភាតំណាងក្រុមនីមួយៗ ដែលបានសុំចុះឈ្មោះបញ្ចេញយោបល់ អាចនិយាយបាន ២០នាទីយ៉ាងយូរ ចំណែកសមាជិកព្រឹទ្ធសភាតំណាងក្រុមនីមួយៗ ដែលគ្រាន់តែសុំឆ្លើយតប និយាយបានត្រឹមតែ៥នាទី

---

[28] មាត្រា១១១ថ្មី(ពីរ), រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[29] មាត្រា២, ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា, ២០០៥។

ប៉ុណ្ណោះ។ បើប្រធានព្រឹទ្ធសភាយល់ថាជាការចាំបាច់ ឬជាការមានប្រយោជន៍ក្នុងការពិភាក្សា នោះប្រធានអាចអនុញ្ញាត បន្ថែមពេលឲ្យនិយាយបាន១០នាទីទៀត ហើយការបន្ថែមនេះ អាចឲ្យបន្តបានពីរដង ក្នុងប្រធានបទតែមួយ។ សមាជិកក្នុងក្រុមជាមួយ មានសិទ្ធិសុំបញ្ចេញមតិ បន្ថែមក្នុងប្រធានបទដដែល និងក្នុងរយៈពេលដែលនៅសល់ពីការកំណត់ខាងលើ ។

សូមបញ្ជាក់ជូនថា បទប្បញ្ញត្តិអំពីការសុំចុះឈ្មោះបញ្ចេញយោបល់ និងការកំណត់រយៈពេលបញ្ចេញយោបល់ខាងលើ ប្រើសម្រាប់តែសមាជិកព្រឹទ្ធសភាតែប៉ុណ្ណោះ មិនយកមកប្រើសម្រាប់តំណាងរាជរដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬម្ចាស់សេចក្តីស្នើច្បាប់ ឬអ្នកជំនាញការពារសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបក្ខពួកទាំងពួងនោះទេ ។

### ១.២.៤ វិសមិតភាពនៃសមាជិកព្រឹទ្ធសភា

ក្នុងនីតិកាលរបស់ព្រឹទ្ធសភា អាសនៈរបស់សមាជិកព្រឹទ្ធសភាត្រូវប្រកាសថានៅទំនេរ ក្នុងករណីលាលែង បោះបង់ចោលការងារ មកពីវិសមិតភាព ប្រាសចាកសមាជិកភាព ឬទទួលអនិច្ចកម្ម។ អាសនៈរបស់សមាជិកព្រឹទ្ធសភាដែលនៅទំនេរយ៉ាងតិច៦ខែមុនចប់នីតិកាល ត្រូវបំពេញជំនួសដោយសមាជិកថ្មី ចេញពីប្រភពដើមដែលមានអាសនៈទំនេរនោះដោយមិនចាំបាច់បោះឆ្នោតសាឡើងវិញ។ មុខងារជាសមាជិកព្រឹទ្ធសភាមានវិសមិតភាពជាមួយមុខងារសមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងការបំពេញមុខងារសាធារណៈជាសកម្ម រួមទាំងការប្រកបការងារក្នុងវិជ្ជាជីវៈសេរីផងដែរ ។

### ១.២.៥ ការបាត់បង់សមាជិកភាពព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយដូចខាងក្រោមៈ

- សាមីខ្លួនទទួលមរណភាព
- ខានបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នរដ្ឋដែលមានសមត្ថកិច្ច។
- សាមីខ្លួនសុំលាឈប់ពីសមាជិកព្រឹទ្ធសភា ដោយមានលាយលក្ខណ៍អក្សរ។
- សាមីខ្លួនត្រូវបានតុលាការផ្តន្ទាទោស ដាក់ពន្ធនាគារ ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។
- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន។

នៅក្នុងនីតិកាលនីមួយៗរបស់ព្រឹទ្ធសភា អាសនៈរបស់សមាជិកព្រឹទ្ធសភា ត្រូវប្រកាសថានៅមានទំនេរ អាសនៈសមាជិកព្រឹទ្ធសភាដែលទំនេរនោះ ដោយរួមកពីការសំលាលែង ឬដោយសារការបោះបង់ចោលការងាររបស់ខ្លួនចំនួនបីខែ ដោយគ្មានការអនុញ្ញាត ឬដោយសារមកពីការទទួលមរណភាព ឬប្រាសចាកជាសមា-ជិកភាពរបស់ព្រឹទ្ធសភា ដោយសមាជិកភាពបានចេញពីគណបក្សនយោបាយរបស់ខ្លួនដែលបានជាប់ឆ្នោត។ អាសនៈនៃសមាជិកព្រឹទ្ធសភា ដែលនៅទំនេរនោះត្រូវមានរយៈពេលច្រើនជាង៦ខែមុនចប់នីតិកាលរបស់ខ្លួន។ អាសនៈទំនេរនោះត្រូវធ្វើការជ្រើសរើសបំពេញជំនួសវិញដោយ សមាជិកព្រឹទ្ធសភាថ្មីតាមលំដាប់លេខរៀងជាបន្តបន្ទាប់ ដែលបានជ្រើសរើសនៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលតំណាងគណបក្សនយោបាយ

មណ្ឌលជាមួយគ្នា ឬជ្រើសតាំងសមាជិកព្រឹទ្ធសភាថ្មីចេញពីប្រភពដើមដែលមានអាសនៈទំនេរៗ។ ប្រសិនបើអាសនៈ ដែលនៅទំនេររបស់សមាជិកព្រឹទ្ធសភាមានរយៈពេលតិចជាង៦ខែ នោះអាសនៈរបស់សមាជិកព្រឹទ្ធ-សភាដែលនៅទំនេរ មិនចាំបាច់ធ្វើការជ្រើសរើសសមាជិកព្រឹទ្ធសភាថ្មីមកជំនួសទេ។

### ១.២.៦ គណៈកម្មការអចិន្ត្រៃយ៍ព្រឹទ្ធសភា

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តយល់ព្រមដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

#### ១.២.៦.១ សមាសភាពគណៈកម្មការអចិន្ត្រៃយ៍ព្រឹទ្ធសភា

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាមានសភាពដូចខាងក្រោម៖

- ប្រធានរដ្ឋសភា ១ រូប ជាប្រធានគណៈកម្មាធិការ
- អនុប្រធានរដ្ឋសភាទី១ ជាអនុប្រធានទី១គណៈកម្មាធិការ
- អនុប្រធានទី២ ជាអនុប្រធានទី២គណៈកម្មាធិការ
- ប្រធាគណៈកម្មការជំនាញទាំង ១០នៃព្រឹទ្ធសភា ជាសមាជិកគណៈកម្មាធិការ។

#### ១.២.៦.២ តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភារួមមាន៖

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាទទួលភារកិច្ច ចាត់ចែងការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំ។

-កោះប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ប្រសិនបើមានសំណូមពរពីព្រះមហាក្សត្រឬមានសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបី យ៉ាងតិច។

-រាយការណ៍អំពីសកម្មភាពនានារបស់ព្រឹទ្ធសភា នូវរាល់គ្រប់ចន្លោះសម័យប្រជុំព្រឹទ្ធសភានៅពេលបើកសម័យប្រជុំនីមួយៗ។

-កំណត់កាលបរិច្ឆេទ និងរបៀបវារៈនៃសម័យប្រជុំនីមួយៗរបស់ព្រឹទ្ធសភា។

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នករៀបចំរបៀបវារៈក្នុងការកំណត់ពេលប្រជុំទីមួយៗ។ មុនផុតពេលប្រជុំនីមួយៗ ប្រធានត្រូវអានរបៀបវារៈ សម្រាប់ពេលប្រជុំបន្តទៅទៀតៗ។

នៅក្នុងរបៀបវារៈនេះ ត្រូវមានសេចក្តីជាលំដាប់មុនក្រោយដូចតទៅនេះ៖

+បញ្ហាទាំងឡាយដែលព្រឹទ្ធសភាបានសម្រេចថាទុកជាការប្រញាប់

+បញ្ហាទាំងឡាយដែលរដ្ឋសភាជូនមកព្រឹទ្ធសភា

+បញ្ហាទាំងឡាយដែលរាជរដ្ឋាភិបាលជូនមកព្រឹទ្ធសភា

+បញ្ហាទាំងឡាយដែលគណៈកម្មការនានាជូនមកព្រឹទ្ធសភា

+បញ្ហាទាំងឡាយដែលសមាជិកព្រឹទ្ធសភាជូនមកព្រឹទ្ធសភា។

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាជាអ្នកពិនិត្យនិងសម្រេចរបាយការណ៍ ទូទាត់ការចំណាយថវិការបស់ព្រឹទ្ធសភា នៅរាល់ដំណាច់ឆ្នាំ ហើយត្រូវបញ្ជូនទៅ ក្រសួងមានសមត្ថកិច្ច ដើម្បីរៀបចំបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ។

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាជាអ្នកកំណត់នូវសេចក្តីស្នើថវិការបស់ព្រឹទ្ធសភា ដែលព្រឹទ្ធសភាត្រូវមានថវិកាស្វយ័តមួយសម្រាប់ដំណើរការហើយ ត្រូវបញ្ជូនទៅក្រសួងមានសមត្ថកិច្ច ដើម្បីបញ្ចូលក្នុងគម្រោងថវិកាជាតិ។

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាជាអ្នកសម្រេចដាក់ទណ្ឌកម្ម និងលើសមាជិកព្រឹទ្ធសភាដោយស្វ័យប្រវត្តិ កាលបើបានដឹងច្បាស់ថាមូលហេតុ ដែល សមាជិកព្រឹទ្ធសភាខកខានមិនបានមកប្រជុំនោះ។

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នកទទួលបន្ទុករៀបចំពិធីបុណ្យសព និងផ្តល់ប្រាក់បំណាច់ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់បែបយ៉ាង ដល់ក្រុមគ្រួសារសពរយៈពេលមួយឆ្នាំទៀតគិតពីថ្ងៃទទួលមរណភាព។

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នកសម្រេចឲ្យសមាជិកព្រឹទ្ធសភា។

### ១.២.៧ ការបង្កើតគណៈកម្មការជំនាញព្រឹទ្ធសភា

ក្នុងករណីធម្មតាព្រឹទ្ធសភា ត្រូវធ្វើការបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវសមាជិកគណៈកម្មការនានានៃព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាត។ ព្រឹទ្ធសភាអាចបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ការរៀបចំ និងការប្រព្រឹត្តិទៅនៃព្រឹទ្ធសភា ការកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភាត្រូវអនុម័តយល់ព្រមដោយសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។ កូរ៉ុមសម្រាប់ប្រជុំរបស់គណៈកម្មការជំនាញនានាត្រូវមានចំនួនលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ក្នុងករណីចាំបាច់ព្រឹទ្ធសភាក៏អាចអនុម័តដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ដើម្បីសម្រេចក្នុងការបង្កើតគណៈកម្មការ មានសមាសភាពសសមាជិកច្រើន ឬតិចទៅតាមតម្រូវការពិសេស។ ក្នុងករណី ប្រធានគណៈកម្មការអវត្តមាន ដោយមូលហេតុណាមួយ អនុប្រធាន ឬលេខាធិការគណៈកម្មការនោះ មានសិទ្ធិចូលរួមប្រជុំ នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ជំនួសបាន ប៉ុន្តែពុំមានសិទ្ធិសម្រេចការងារផ្សេងៗ ក្នុងនាមប្រធានបានឡើយ គណៈកម្មការត្រូវបំពេញការងារជំនួសប្រធានតាមរយៈលិខិតផ្ទេរសិទ្ធិ។

ការបង្កើតគណៈកម្មការពិសេសនានា គឺស្ថិតក្នុងករណីដូចខាងក្រោម៖

- ករណីបង្កើតគណៈកម្មការ តាមការស្នើសុំរបស់ប្រធានព្រឹទ្ធសភាបំពេញការងារចាំបាច់ណាមួយ។

- ករណីបង្កើតគណៈកម្មការតាមការស្នើសុំរបស់គណៈកម្មការ ដើម្បីធ្វើការពិនិត្យ ឬសិក្សាទៅលើអត្ថបទច្បាប់ណាមួយ ឬការ កម្មណាមួយ ដែលមានលក្ខណៈជាពិសេស។

- ករណីបង្កើតគណៈកម្មការតាមសំណើរបស់ប្រធានគណៈកម្មកាជំនាញ ដើម្បីដោះស្រាយ បញ្ហាសំខាន់ចាំបាច់ណាមួយ ករណីបង្កើត អត្ថបទច្បាប់ទៅគណៈកម្មការជំនាញនោះ ទាំងមូល ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាជាមុនសិន។

- គណៈកម្មការ ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបាន ច្បាប់ទៅគណៈកម្មការណាមួយ ដើម្បីធ្វើការពិនិត្យ និងទាញនោះ បានប្រកាសថាខ្លួនពុំមានសមត្ថកិច្ច ក្នុងការពិនិត្យហើយ កម្មការជំនាញផ្សេងទៀតអាចទទួលយកអត្ថបទច្បាប់នោះមកពិនិត្យសិន។

ក្នុងការបង្កើតគណៈកម្មការពិសេសនានា ជាទូទៅត្រូវគោរពទៅតាមគោល ណ៍សមាមាត្រ ដោយយកសម្លេងភាគច្រើនដាច់ខាត៥០បូក១ ហើយការរៀបចំសមាសភាពរបស់គណៈកម្មការពិសេសនេះ ត្រូវពិគ្រោះយោបល់នៅក្នុងគណៈកម្មការ គឺការអចិន្ត្រៃយ៍ព្រឹទ្ធសភា ហើយចាំបាច់ដាក់ឲ្យគណៈកម្មាធិការអចិន្ត្រៃយ៍ ព្រឹទ្ធសភា ឬព្រឹទ្ធសភាពេញអង្គជាអ្នកធ្វើការអនុម័ត និងសម្រេច។

**១.២.៧.១ សមាសភាពគណៈកម្មការជំនាញព្រឹទ្ធសភា**

គណៈកម្មការនីមួយៗត្រូវធ្វើការជ្រើសតាំងដោយវិធីបោះឆ្នោត។ នៅក្នុងគណៈកម្មការជំនាញនីមួយៗរបស់ព្រឹទ្ធសភាជារួមមាន៖

- ប្រធានគណៈកម្មការ១រូប
- អនុប្រធានគណៈកម្មការ១រូប
- លេខាធិការ
- សមាជិកសរុបនៃគណៈកម្មការនីមួយៗមានចំនួន៥រូប។

កូរ៉ុមសម្រាប់ប្រជុំរបស់គណៈកម្មការជំនាញនានា ត្រូវមានចំនួនលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។ គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភាមាន១០គឺ៖

- គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត។
- គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម។
- គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន។
- គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ។
- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន។
- គណៈកម្មការនីតិកម្ម និងយុត្តិធម៌។

- គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍។

- គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី។

- គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

- គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ។

**១.២.៧.២ តួនាទីគណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា**

គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភាមានតួនាទីមួយចំនួនដូចខាងក្រោម៖

- គណៈកម្មការនីមួយៗ ត្រូវកំណត់តួនាទីសមត្ថកិច្ច និងភារកិច្ចរបស់ខ្លួនឲ្យសមស្របទៅនឹងរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងច្បាប់ជាធរមានរបស់រដ្ឋ រួចដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យ និងសម្រេច។

- គណៈកម្មការនីមួយៗ អាចស្នើសុំប្រធានព្រឹទ្ធសភាចាត់តាំងអ្នកជំនាញ ដែលមិនមែនជាសមាជិកព្រឹទ្ធសភាឲ្យចូលរួមធ្វើការបាន ប៉ុន្តែអ្នកជំនាញមិនមានសិទ្ធិសម្រេចនៅក្នុងគណៈកម្មការនានានេះទេ ពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល។

- គណៈកម្មការនានារបស់ព្រឹទ្ធសភាអាចកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីអ្វីមួយ ដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួនបានការអញ្ជើញមកសាកសួរ គឺដើម្បីផ្តល់ព័ត៌មានផ្សេងៗពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់គណៈកម្មការជំនាញតែប៉ុណ្ណោះ គឺពុំមែនជាការសាកសួរ ឬដេញដោលដើម្បីប្រឆាំងឬគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ឬការដកតំណែងសមាជិកគណៈរដ្ឋមន្ត្រីណាម្នាក់ដូចរដ្ឋសភាទេ។

- គណៈកម្មការតាមជំនាញនីមួយៗ ជាអ្នកទទួលសេចក្តីព្រាងច្បាប់ពីគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ហើយត្រូវធ្វើការពិភាក្សា និងពិនិត្យឲ្យបានត្រឹមត្រូវ កាលបើពិនិត្យរួចហើយ ប្រធាននៃគណៈកម្មការទាំងនោះត្រូវនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនព្រឹទ្ធសភា។

- គណៈកម្មការនានា អាចអនុញ្ញាតឲ្យអ្នករៀបចំ និងតាក់តែងសេចក្តីស្នើច្បាប់ចូលរាយការណ៍ជម្រាបជូនគណៈកម្មការជំនាញ ដែលពិនិត្យសេចក្តីស្នើច្បាប់នោះ។

- គណៈកម្មការជំនាញមានសិទ្ធិសូមឲ្យព្រឹទ្ធសភា លើកចោលពុំពិចារណាបាននូវកិច្ចការទាំងឡាយ ដែលគណៈកម្មការជំនាញយល់ឃើញថាជាការចាំបាច់ ។

- គណៈកម្មការជំនាញមានសិទ្ធិ ក្នុងការផ្តល់យោបល់លើសេចក្តីស្នើច្បាប់ ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានដាក់ឲ្យពិនិត្យ។

- គណៈកម្មការជំនាញ មានសិទ្ធិសូមឲ្យព្រឹទ្ធសភាបញ្ចេញមតិជាមុនសិន ថាតើគួរទទួលយកមកពិចារណាឬទេ?

### ១.២.៨ ការអនុវត្តអំណាចរបស់ព្រឹទ្ធសភា

#### ១.២.៨.១ ការផ្តើមធ្វើច្បាប់

នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានផ្តល់អំណាចមកឲ្យព្រឹទ្ធសភា នៅការផ្តួចផ្តើមធ្វើច្បាប់ និងសេចក្តីស្នើរច្បាប់។ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និង នាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់។ តំណាងរាស្ត្រ មានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ។

សេចក្តីស្នើរច្បាប់ដែលសមាជិកព្រឹទ្ធសភា ជាអ្នកធ្វើ ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយត្រូវចែងជាមាត្រាដោយមានភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផង។

សេចក្តីស្នើរច្បាប់ជាទូទៅ ត្រូវបញ្ជូនទៅរដ្ឋសភាតាមរយៈគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ក្រោយពីបានដាក់ឲ្យគណៈកម្មការជំនាយរបស់ព្រឹទ្ធសភាផ្តល់យោបល់។

អ្នកតែងសេចក្តីស្នើរច្បាប់មានសិទ្ធចូលរាយការណ៍ និងការពារចំពោះគណៈកម្មការដែលពិនិត្យសេចក្តីស្នើរនោះ។

អ្នកតែងសេចក្តីស្នើរច្បាប់ អ្នកលើកបញ្ហានានា អាចដកសេចក្តីស្នើរច្បាប់ ឬបញ្ហានានានោះចេញបាន ទោះបីជាព្រឹទ្ធសភា ចាប់ផ្តើមពិភាក្សាហើយក៏ដោយ។

ចំពោះសេចក្តីស្នើរច្បាប់ ឬបញ្ហានានាដែលបានដកចេញមិនឲ្យពិភាក្សានោះក៏ដោយ ក៏សមាជិក ផ្សេងៗទៀតអាចសុំឲ្យព្រឹទ្ធសភាពិភាក្សាឡើយវិញ។ សមាជិកព្រឹទ្ធសភាគ្រប់រូបអាចស្នើរសុំធ្វើការកែសម្រួលលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើរច្បាប់ជាលាយលក្ខណ៍អក្សរ ដើម្បីជូនទៅគណៈកម្មការជំនាញក៏បាន ឬជូនទៅព្រឹទ្ធសភាក្នុងសម័យប្រជុំពេញអង្គក៏បាន។ ព្រឹទ្ធសភា អាចសម្រេចយល់ព្រម ឬមិនយល់ព្រមយកពាក្យស្នើសុំនោះមកពិភាក្សាបាន។

#### ១.២.៨.២ ការត្រួតពិនិត្យច្បាប់

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើរច្បាប់ដែលរដ្ឋសភាអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងបញ្ហានានា ដែលរដ្ឋសភាបានដាក់ឲ្យពិនិត្យ ត្រូវបញ្ជូនមកគណៈកម្មធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើរច្បាប់ ឬបញ្ហានានានោះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរហើយចែកជូនសមាជិកព្រឹទ្ធសភានិមួយៗទាំងអស់ ដោយភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផង។ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើរច្បាប់ ឬបញ្ហានានាទៅឲ្យគណៈកម្មការជំនាញដើម្បីធ្វើការពិនិត្យ។ កាលបើគណៈកម្មការជំនាញត្រួតពិនិត្យរួចហើយ ប្រធានគណៈកម្មការនោះ ត្រូវនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនព្រឹទ្ធសភាបានជ្រាប។ អង្គប្រជុំព្រឹទ្ធសភាអាចប្រើនីតិវិធី ដោយពិភាក្សាសង្ខេបបាន ដោយធ្វើការពិភាក្សាតែលើ

មាត្រាណា ឬជំពូកណាដែលមានសំណើធ្វើការកែសម្រួលជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងប្រការទាំងឡាយខាងលើ។ ក្នុងករណីដែលត្រូវប្រើនីតិវិធីណាមួយខាងលើគណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវជូនព័ត៌មានដល់គ្រប់សមាជិកព្រឹទ្ធសភាទាំងអស់។

ព្រឹទ្ធសភាអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីថ្លែងច្បាប់ទាំងមូលនោះបាន ជារួម ព្រឹទ្ធសភាត្រូវពិនិត្យហើយឲ្យយោបល់ ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីថ្លែងច្បាប់ដែលរដ្ឋសភាអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើកបញ្ហាទាំងឡាយទាំងពួង ដែលរដ្ឋសភាបានដាក់ឲ្យពិនិត្យ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកត្រឹម ៧ថ្ងៃ។ បើព្រឹទ្ធសភាបានឲ្យយោបល់យល់ព្រម ឬពុំបានឲ្យយោបល់សោះ ក្នុងរយៈពេលដែលបានកំណត់ទុកហើយនោះទេ ច្បាប់ដែររដ្ឋសភាបានអនុម័តយល់ព្រមហើយនោះនឹងត្រូវយកទៅប្រកាសឲ្យប្រើ។ បើព្រឹទ្ធសភាសុំកែសម្រួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើរច្បាប់នោះ រដ្ឋសភាត្រូវយកមកត្រួតពិនិត្យ ពិចារណាភ្លាមជាលើកទី២។ រដ្ឋសភាត្រូវត្រួតពិនិត្យ និងសម្រេចត្រង់បទបញ្ញត្តិណា ឬចំណុចណាដែលព្រឹទ្ធសភាបានសុំឲ្យកែសម្រួលដោយបដិសេធចោលទាំងមូល ឬ ទុកជាបានការខ្លះ។

ការបង្វិលទៅបង្វិលមក រវាងព្រឹទ្ធសភានិងរដ្ឋសភាត្រូវធ្វើឡើយក្នុងរយៈពេលមួយខែប៉ុណ្ណោះ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមតែ១០ថ្ងៃ បើត្រូវពិនិត្យសម្រេចពីថវិការជាតិ និងហិរញ្ញវត្ថុ ឲ្យមកត្រឹមតែពីថ្ងៃ បើសិនជាការប្រញាប់។ បើរដ្ឋសភាទុកឲ្យហួសពេលកំណត់ ឬពន្យាពេល ដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភាត្រួតពិនិត្យ និងព្រឹទ្ធសភាត្រួតពិនិត្យត្រូវបន្ថែមរយៈពេលឲ្យស្មើរគ្នាផងដែរ ។ បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើរច្បាប់នោះ ជាអសារបង នោះរដ្ឋសភា នឹងមិនអាចយកសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើរច្បាប់នោះ មកពិចារណាជាលើកទី២ បានមុនរយៈពេលមួយខែទេ។ រយៈពេលនេះត្រូវបន្ថយមកត្រឹម ១៥ថ្ងៃ ប្រសិនបើពិនិត្យអំពីថវិការជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែ៤ថ្ងៃ បើជាការប្រញាប់។ ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើរច្បាប់ជាលើកទី២នេះ រដ្ឋសភាត្រូវអនុម័ត ដោយវិធីបោះឆ្នោតចំហនិងយកតាមមតិភាគច្រើនដាក់ខាត ៥០ បូក ១។សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើរច្បាប់ណា ដែលបានសម្រេចដូចខាងលើនេះហើយនោះ នឹងត្រូវយកទៅប្រកាស់ឲ្យប្រើ។

**១.២.៨.៣ ការអនុម័តរបស់ព្រឹទ្ធសភា**

ការពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវធ្វើដូចតទៅ៖

- អង្គប្រជុំព្រឹទ្ធសភាពិភាក្សានឹងអនុម័តលើខ្លឹមសារទាំងមូល គឺបញ្ចេញមតិថា តើគួរពិចារណាឬទេ។
- អង្គប្រជុំព្រឹទ្ធសភានឹងធ្វើការអនុម័តទៅលើមាត្រា មួយមាត្រាម្តងៗក៏បាន ឬលើជំពូកដោយអនុម័តមួយជំពូកម្តងៗក៏បាន។

ព្រឹទ្ធសភាអាចអនុម័តទៅលើបញ្ហាទាំងឡាយ គ្រប់បែបយ៉ាងរបស់ប្រទេសជាតិ ក្នុងករណីច្បាប់ និងបញ្ហានានាដែលរដ្ឋសភាបានធ្វើការអនុម័តរួចហើយ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ គឺព្រះមហាក្សត្រ

ឡាយព្រះហស្តលាខា និងចេញព្រះរាជក្រមប្រកាសឲ្យប្រើ។ ព្រឹទ្ធសភាអាចអនុម័តទៅលើបញ្ហាទាំងឡាយដូចជាៈ

- ព្រឹទ្ធសភាអនុម័តថវិការជាតិ ផែនការរដ្ឋ ឬការឲ្យរដ្ឋគេខ្ចីប្រាក់ពីប្រទេសយើង ឬការឲ្យយើងខ្ចីប្រាក់ពីប្រទេសគេ ឬការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត ការកែប្រែ ឬការលុបចោលពន្ធដារជាដើម។
- ព្រឹទ្ធសភា ឲ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល។
- ព្រឹទ្ធសភា អនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ។
- ព្រឹទ្ធសភា អនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។
- ព្រឹទ្ធសភា អនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម។

ព្រឹទ្ធសភា បោះឆ្នោតអនុម័តបញ្ហានានាខាងលើនេះ អាចប្រព្រឹត្តិទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល។

ព្រឹទ្ធសភាអាចអនុម័ត ដោយអនុម័តតាមមតិភាគច្រើន២ភាគ៣ នៃចំនួនព្រឹទ្ធសភាទាំងមូល។ ព្រឹទ្ធសភាអនុម័តទៅលើករណីឃុំខ្លួន ការចាប់ខ្លួន ការចោទប្រកាន់នៃសមាជិកព្រឹទ្ធសភារូបណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិឲ្យផ្អាកតាមមតិភាគច្រើន៣ភាគ៤ នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភាត្រូវអនុម័តយល់ព្រមដោយសំលេងភាគច្រើនដាច់ខាតនៃចំនួសមាជិកព្រឹទ្ធសភាទាំងមូល។

### ១.២.៩ ការប្រជុំ

#### ១.២.៩.១ ការប្រជុំសាមញ្ញ

ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ។ សម័យប្រជុំនីមួយៗ មានថិរវេលាយ៉ាងតិចបីខែ។ បើមានសំណូមពរ ពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិចព្រឹទ្ធសភាអាចកោះប្រជុំជាវិសាមញ្ញ។ រាល់ការប្រជុំរបស់ព្រឹទ្ធសភាអាចប្រព្រឹត្តទៅបាន លុះត្រាមានប្រធានដឹកនាំ ហើយត្រូវមានកូរ៉ុមគ្រប់ចំនួន ទាំងនៅពេលបើកការប្រជុំ និងនៅពេលអនុម័ត ។

#### ១.២.៩.២ ការប្រជុំវិសាមញ្ញ

ការប្រជុំវិសាមញ្ញ គឺជាការប្រជុំមួយនៅចន្លោះសម័យប្រជុំជាសាមញ្ញដែលការប្រជុំនេះ អាចធ្វើបានក្នុងករណីមានការចាំបាច់ និងជាការបន្ទាន់ណាមួយដែលទាក់ទងនឹងបញ្ហាសំខាន់ៗរបស់សភាជាតិ។ ព្រឹទ្ធអាចកោះប្រជុំវិសាញ្ញមបាន ប្រសិនបើមានសំណូមពរពីព្រះមហាក្សត្រ ឬ តាមតាមសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬមានមានការស្នើពីសមាជិករដ្ឋសភាដែលមានចំនួនសមាជិករដ្ឋសភាទាំងមូល[30]។

#### ១.២.៩.៣ ការប្រជុំរាល់ថ្ងៃ

[30] មាត្រា៨៣, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នករៀបចំរបៀបវារៈក្នុងសម័យប្រជុំនីមួយៗ ។ ការកំណត់ថ្ងៃប្រជុំត្រូវធ្វើជាលិខិតផ្ញើទៅជូនសមាជិកព្រឹទ្ធសភា។ បើមានការកំណត់ផ្ទាល់មាត់ក្នុងពេលប្រជុំ ការកំណត់នេះត្រូវធ្វើជាលិខិតផ្ញើទៅសមាជិកព្រឹទ្ធសភាដែលមិនបានមកប្រជុំ។ តាមធម្មតាត្រូវកំណត់២ថ្ងៃ មុនពេលប្រជុំដោយមានភ្ជាប់ទៅជាមួយនូវរបៀបវារៈប្រជុំ វៀរលែងតែក្នុងករណីប្រញាប់។

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ និងត្រូវផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ជាតិ។ កំណត់ហេតុនៃការប្រជុំព្រឹទ្ធសភាមានកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារ។ កំណត់ហេតុទាំងអស់ត្រូវតម្កល់ទុកក្នុងបណ្ណសារដ្ឋានព្រឹទ្ធសភា។

ព្រឹទ្ធសភាអាចកោះប្រជុំជាសម្ងាត់បាន តាមសំណើសុំពីប្រធានព្រឹទ្ធសភា ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគដប់យ៉ាងតិច ឬពីព្រះមហាក្សត្រ ឬពីប្រធានរដ្ឋសភា ឬពីនាយករដ្ឋមន្ត្រី ។

**១.២.១០ នីតិវិធីនៃការអនុម័ត**

ព្រឹទ្ធសភាអាចអនុម័តទាក់ទងបញ្ហាផ្សេងៗតាមនីតិវិធីបីយ៉ាងគឺៈ

- អនុម័តបោះឆ្នោតដោយការលើកដៃ
- អនុម័តបោះឆ្នោតដោយការបោះឆ្នោតចំហ
- អនុម័តបោះឆ្នោតដោយការបោះឆ្នោតសម្ងាត់។

**១.២.១០.១ ការអនុម័តដោយវិធីលើកដៃ**

ការអនុម័តដោយវិធីលើកដៃ គឺប្រធាន និងលេខាធិការទាំងឡាយជាអ្នករាប់ចំនួនសមាជិកព្រឹទ្ធសភាដែលត្រូវបានលើកដៃធ្វើការអនុម័ត។

បើប្រធាន និងលេខាធិការយល់ឃើញថា ការលើកដៃអនុម័តនេះមិនបានច្បាស់លាស់ទេនោះ គេត្រូវធ្វើទៅតាមនីតិវិធីដដែលសារជាថ្មីម្តងទៀត។ កាលបើការលើកដៃអនុម័តបានរហូតទៅដល់ពីរដងហើយ ប៉ុន្តែនៅតែមិនទទួលបានលទ្ធផលច្បាស់លាស់ទេនោះ គឺគេត្រូវអនុវត្តការអនុម័តបោះឆ្នោតជាចំហវិញ។

**១.២.១០.២ ការអនុម័តដោយបោះឆ្នោតចំហ**

អនុម័តបោះឆ្នោតជាចំហ គឺជាការបោះឆ្នោត ដែលមានគណៈកម្មការបោះឆ្នោតជាអ្នកកាន់ហិបឆ្នោតដើរប្រមូលយកសន្លឹកឆ្នោតពីសមាជិកព្រឹទ្ធសភា។

សមាជិកព្រឹទ្ធសភាត្រូវតែសរសេរឈ្មោះរបស់ខ្លួននៅលើសន្លឹកឆ្នោត ដែលសន្លឹកឆ្នោតមានសណ្ឋានបីពណ៌ ដែលមានពណ៌ខៀវ គឺមានន័យថាមិនព្រម ពណ៌សគឺមានន័យថាយល់ព្រម និងពណ៌សឆ្នូតខៀវគឺមានន័យថាអនុប្បវាទ។

ក្រោយពីបានបោះឆ្នោតរួចស្រេចហើយ លេខាធិការនៃព្រឹទ្ធសភាជាអ្នករាប់សន្លឹកឆ្នោត ហើយប្រធាន

ព្រឹទ្ធសភាជាអ្នកប្រកាសជូនអង្គប្រជុំទាំងមូលបានជ្រាប។

**១.២.១០.៣ ការអនុម័តដោយសម្ងាត់**

វីធីបោះឆ្នោតដោយសម្ងាត់នេះ ត្រូវបានគេយកមកប្រើក្នុងការអនុម័តមួយចំនួនដូចជា៖

- ការអនុម័តច្បាប់នានា និងអនុម័តច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញ
- ការអនុម័តកិច្ចការទាំងឡាយរបស់ប្រទេសជាតិជាច្រើនទៀត
- ការអនុម័តទាំងឡាយត្រូវបានអនុម័តតាមមតិភាគច្រើន ដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្រៅពីនេះមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលត្រូវចាត់ទុកថាជាបានការ។ បើចំនួនមតិយល់ព្រម និងចំនួនមតិមិនយល់ព្រមមានចំនួនស្មើគ្នានោះ ការបោះឆ្នោតត្រូវធ្វើឡើងជាថ្មីម្តងទៀត បើលទ្ធផលនៃការបោះឆ្នោតលើកទី២នេះនៅតែមានសម្លេងស្មើគ្នា នោះព្រឹទ្ធសភាត្រូវចាត់ទុកថាការអនុម័តនេះមិនយល់ព្រម។

ក្រោយបានលទ្ធផលនៃការបញ្ចេញមតិរួចហើយ ប្រធានព្រឹទ្ធសភាត្រូវប្រកាសថា ព្រឹទ្ធសភាបានអនុម័តយល់ព្រមហើយ ឬព្រឹទ្ធសភាមិនបានអនុម័តយល់ព្រម។

**១.២.១១ អគ្គនាយកដ្ឋានព្រឹទ្ធសភា**

**១.២.១១.១ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានតួនាទីជាសេនាធិការរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងការផ្តល់សេវាផ្គត់ផ្គង់ មធ្យោបាយធនធាន ថវិកា សម្ភារៈ ជាសុកភាព បរិស្ថានការងារ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ផលប្រយោជន៍ផ្សេងៗ គ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សឲ្យមានវិជ្ជាជីវៈច្បាស់លាស់ និងឈានទៅដល់កម្រិតឯកទេស គ្រប់គ្រងរដ្ឋបាលទំនើប ប្រព័ន្ធសន្តិសុខទំនើប ព្រមទាំងកសាងផែនការសរុប ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

**១.២.១១.២ អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ**

អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ មានតួនាទីផ្តល់សេវាគាំទ្រលើកកម្ពស់ប្រសិទ្ធភាពមុខងារព្រឹទ្ធសភា ផ្តល់សេវាការគ្រប់គ្រង ផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងសាធារណៈរបស់ព្រឹទ្ធសភាឲ្យសាធារណជនស្គាល់ ហើយយល់អំពីសកម្មភាព និងកិត្យានុភាពរបស់ព្រឹទ្ធសភា និងមានទំនាក់ទំនងជាមួយនឹងព្រឹទ្ធសភា។

**១.២.១១.៣ អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី**

អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដីមានតួនាទីផ្តល់សេវាបច្ចេកទេស នីតិវិធីកំណត់ហេតុប្រជុំ សេវាឯកសារគតិយុត្ត ទិន្នន័យច្បាប់ និងសេវាទ្រទ្រង់សកម្មភាពរបស់គណៈកម្មការ និងក្រុមនានារបស់ព្រឹទ្ធសភា ដើម្បីឲ្យព្រឹទ្ធសភាបំពេញបាននូវមុខងារស្នូលទាំងបី គឺមុខងារនីតិកម្ម មុខងារតាមដានការអនុវត្ត

ច្បាប់ និងមុខងារតំណាង ។

**១.២.១១.៤ អគ្គនាយកដ្ឋានស្រាវជ្រាវ**

អគ្គនាយកដ្ឋានស្រាវជ្រាវ ជាអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។ អគ្គនាយកដ្ឋាននេះចែកជា ៤នាយកដ្ឋាន គឺនាយកដ្ឋានស្រាវជ្រាវច្បាប់ នាយកដ្ឋានស្រាវជ្រាវកិច្ចការសភា នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសង្គម និងនាយកដ្ឋានស្រាវជ្រាវថវិកា។ អគ្គនាយកដ្ឋានស្រាវជ្រាវដឹកនាំដោយអគ្គនាយក១រូប និងមានអគ្គនាយករងជាជំនួយការ។អគ្គនាយកដ្ឋានស្រាវជ្រាវ មានតួនាទីផ្តល់សេវាសិក្សាស្រាវជ្រាវ និងព័ត៌មានផ្នែកច្បាប់ កិច្ចការទូទៅតាមវិស័យថវិកា និងកិច្ចការសភា ដើម្បីគាំទ្រដល់ការប្រតិបត្តិមុខងារស្នួលទាំង៣របស់ព្រឹទ្ធសភា។

**១.២.១១.៥ អគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ**

អគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិទទួលបន្ទុកស្រាវជ្រាវកិច្ចការអន្តរជាតិ ផ្តល់សេវាការងារអន្តរជាតិក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ជំរុញកិច្ចសហប្រតិបត្តិការ ជាមួយបណ្តាអង្គការអន្តរសភាតំបន់ អន្តរជាតិ និងកិច្ចសហប្រតិបត្តិការទ្វេភាគី ជាមួយសភា នៃប្រទេសនានាជុំវិញសកលលោក អង្គទូត អង្គការជាតិ អន្តរជាតិ និងអង្គការសង្គមស៊ីវិល ដែលពាក់ព័ន្ធ ក្នុងគោលបំណងលើកកម្ពស់កិត្យានុភាពវិស័យការទូតសភា តាមរយៈធ្វើ សមាហរណកម្មព្រឹទ្ធសភាឲ្យកាន់តែទូលំទូលាយក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ និងទទួល បន្ទុកការងារពិធីការជាតិ-អន្តរជាតិ ប្រពៃណី និងពិធីសាសនា។

**១.២.១២ អគ្គាធិការដ្ឋាន**

អគ្គាធិការដ្ឋានជាសេនាធិការរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងការត្រួតពិនិត្យវាយតម្លៃ និងផ្តល់យោបល់ ដើម្បីកែលំអរសកម្មភាពអនុវត្តការងាររបស់អង្គភាពទាំងអស់ចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឲ្យត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុង តាមគោលការណ៍ តាមច្បាប់ និងលិខិតបទដ្ឋាននានា និងមានប្រសិទ្ធភាព។

# ជំពូកទី២ ស្ថាប័នរាជរដ្ឋាភិបាល

## ២.១ ការរៀបចំ និងការប្រព្រឹត្តទៅនៃដំណើរការដឹកនាំរដ្ឋរបស់ស្ថាប័នរាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា តំណាងឲ្យអង្គនីតិប្រតិបត្តិនៃរដ្ឋាភិបាល។ ស្ថាប័ននេះទទួលខុសត្រូវអនុវត្តច្បាប់ដែលបានអនុម័តយល់ព្រមដោយរដ្ឋសភា និងព្រឹទ្ធសភា និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ស្របតាមកម្មវិធីនយោបាយរបស់ខ្លួន។ គណៈរដ្ឋមន្ត្រី គឺជាស្ថាប័នគោលនៅក្នុងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ សមាជិកនៃគណៈរដ្ឋមន្ត្រី គឺបណ្តាមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ដែលមានឋានៈស្មើនឹងរដ្ឋលេខាធិការ ឬខ្ពស់ជាងនេះ ដូចជា រដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងនាយករដ្ឋមន្ត្រី ជាដើម។ សមាជិកនៃគណៈរដ្ឋមន្ត្រី និងនាយករដ្ឋមន្ត្រី ទទួលខុសត្រូវរួមគ្នានៅចំពោះមុខរដ្ឋសភា អំពីគោលនយោបាយទូទៅ និងការបំពេញកិច្ចការរដ្ឋរបស់រាជរដ្ឋាភិបាល។ តាមរយៈលិខិតជាលាយលក្ខណ៍អក្សរប្រធាន សមាជិក ឬគណៈកម្មការពិសេសនៃរដ្ឋសភា អាចចោទជាសំណួរទៅកាន់សមាជិកនៃគណៈរដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រី។

## ២.២ ការប្រជុំរបស់គណៈរដ្ឋមន្ត្រី

គណៈរដ្ឋមន្ត្រី មានភារកិច្ចប្រជុំសំខាន់ៗបីសម្រាប់ការអនុម័តសេចក្តីព្រាងច្បាប់ សេចក្តីព្រាងអនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀត ក៏ដូចជាកម្មវិធីនយោបាយជាតិ ផែនការជាតិ ឬគោលនយោបាយជាតិមួយចំនួនរបស់រាជរដ្ឋាភិបាល។

### ២.២.១ ការប្រជុំលើកទី១

កិច្ចប្រជុំលើកទី១នេះ ជាកិច្ចប្រជុំសំខាន់មួយដែលធ្វើឡើងរវាងក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមប្រឹក្សា សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) រួមជាមួយតំណាង មកពីក្រសួងសាមី។ រាល់សេចក្តីព្រាងច្បាប់ សេចក្តីព្រាងអនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយមួយចំនួនរបស់រាជរដ្ឋាភិបាល ដែលបញ្ជូនមកពីក្រសួងនានា មុនដាក់ជូនទៅគណៈរដ្ឋមន្ត្រីអនុម័ត ត្រូវឆ្លងកាត់កិច្ចប្រជុំលើកទី១នេះសិន។

កិច្ចប្រជុំនេះគឺពិនិត្យ និងកែសម្រួលទៅលើទិដ្ឋភាពទាំងស្រុង និងគតិច្បាប់ ក៏ដូចជាពិនិត្យឲ្យយោបល់លើផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ទៅលើអត្ថបទច្បាប់ និងគោលនយោបាលនានារបស់រាជរដ្ឋាភិបាល។ កិច្ចប្រជុំនេះដឹកនាំដោយសហប្រធាន ដែលមួយរូបមកពីក្រុមប្រឹក្សាអ្នកច្បាប់ និងមួយរូបមកពីក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC)។

### ២.២.២ កិច្ចប្រជុំអន្តរក្រសួង

សេចក្តីព្រាងច្បាប់ សេចក្តីព្រាងអនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា រួមទាំងគោលនយោបាយ ឬកម្មវិធីនយោបាយមួយចំនួនរបស់រាជរដ្ឋាភិបាល ក្រោយពីឆ្លងកាត់កិច្ចប្រជុំលើកទីមួយហើយ គឺត្រូវដាក់បន្តទៅឆ្លងកិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យកែសម្រួល និងផ្តល់យោបល់លើលិខិតបទដ្ឋានគតិយុត្តនោះបន្តទៀត។

កិច្ចប្រជុំអន្តរក្រសួងអាចដឹកនាំអង្គប្រជុំដោយនាយករដ្ឋមន្ត្រីផ្ទាល់ ឬនាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនសមាជិករដ្ឋាភិបាលណាម្នាក់កោះប្រជុំ និងធ្វើជាអធិបតីនៃអង្គប្រជុំអន្តរក្រសួង ប៉ុន្តែអង្គប្រជុំនេះគ្មានសិទ្ធិសម្រេចកិច្ចការតាងនាមរាជរដ្ឋាភិបាលឡើយ។[31] ហើយសព្វថ្ងៃ ភាគច្រើនគេប្រគល់តួនាទីទៅរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ឬអគ្គលេខាធិការរាជរដ្ឋាភិបាលដឹកនាំអង្គប្រជុំ។

កិច្ចប្រជុំអន្តរក្រសួងនេះ មានការចូលរួមពីក្រសួងសាមី ក្រសួងពាក់ព័ន្ធ តំណាងក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នាយកដ្ឋានជំនាញរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ តែកិច្ចប្រជុំលើកទីមួយបានធ្វើការងារស្ទើរតែទាំងអស់ហើយ ដោយសារកិច្ចប្រជុំលើកទីមួយជាកិច្ចប្រជុំអ្នកជំនាញ។ ក្រោយពីកិច្ចប្រជុំអន្តរក្រសួងពិនិត្យកែសម្រួល និងផ្តល់យោបល់រួចហើយ ទើបដាក់ចូលទៅក្នុងកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី។

### ២.២.៣ កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

ក្រោយពីកិច្ចប្រជុំអន្តរក្រសួងពិនិត្យចប់សព្វគ្រប់ហើយ ត្រូវដាក់ចូលក្នុងសម័យប្រជុំពេញអង្គគណៈ រដ្ឋមន្ត្រីពិនិត្យ និងសម្រេចជាចុងក្រោយក្នុងនាមរាជរដ្ឋាភិបាល។ កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រីផ្ទាល់។ កិច្ចប្រជុំនេះធ្វើឡើងរៀងរាល់សប្តាហ៍ ហើយក្នុងមួយសប្តាហ៍ប្រជុំម្តង គឺនៅរៀងរាល់ថ្ងៃសុក្រនៅទីស្តីការគណៈរដ្ឋមន្ត្រី។ កិច្ចប្រជុំនេះមានការចូលរួមទាំងអស់ចាប់ពីថ្នាក់រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ដែលជាប្រធានស្ថាប័នឡើងទៅដល់ទេសរដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងប្រតិភូអមនាយករដ្ឋមន្ត្រី។

ក្រោយពេលកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេចហើយ លិខិតបទដ្ឋានទាំងឡាយណាដែលត្រូវបញ្ចប់ត្រឹមកិច្ចប្រជុំពេញអង្គនេះ គឺបញ្ចប់ត្រឹមនេះ និងយកទៅអនុវត្តតែម្តង ក្រោយពីនាយករដ្ឋមន្ត្រីចុះហត្ថលេខាហើយ តែបើលិខិតបទដ្ឋានណាដែលត្រូវដាក់ជូនទៅរដ្ឋសភា ព្រឹទ្ធសភា និងព្រះមហាក្សត្រទៀត គឺត្រូវបន្តធ្វើតាមនីតិវិធីទៅលើជាបន្តទៀត។

## ២.៣ តួនាទីគណៈរដ្ឋមន្ត្រី

ទីស្តីការគណៈរដ្ឋមន្ត្រីមានបេសកកម្មដឹកនាំ គ្រប់គ្រង និងសម្របសម្រួលកិច្ចការប្រចាំថ្ងៃរបស់គណៈរដ្ឋមន្ត្រី ក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី។[32]

### ២.៣.១ តួនាទីសម្របសម្រួលការងារប្រចាំថ្ងៃរបស់គណៈរដ្ឋមន្ត្រី

គណៈរដ្ឋមន្ត្រីមានតួនាទីសម្របសម្រួលការងារប្រចាំថ្ងៃរបស់រាជរដ្ឋាភិបាលតាមរយៈ៖

- ការសិក្សាស្រាវជ្រាវបូកសរុបរបាយការណ៍ទូទៅ និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ដើម្បីរាយ

[31] មាត្រា១៦, ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ២០១៨។

[32] មាត្រា៣៤, ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ២០១៨។

ការណ៍ថ្វាយព្រះមហាក្សត្រ និងចម្លងជូនប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា។

- ការផ្សព្វផ្សាយ និងចាត់ចែងអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត សេចក្តីសម្រេចបទបញ្ជា គោលការណ៍ណែនាំ និងលិខិតរដ្ឋបាលនានារបស់រាជរដ្ឋាភិបាល។

- ការតាមដាន ពិនិត្យក្រើនរំលឹកក្រសួងស្ថាប័ននានាចំណុះរាជរដ្ឋាភិបាល ក្នុងការអនុវត្តកម្មវិធីនយោបាយ លិខិតបទដ្ឋានគតិយុត្ត សេចក្តីសម្រេច បទបញ្ជា និងគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល។

- ការផ្តល់យោបល់លើទិដ្ឋភាពទម្រង់ និងទិដ្ឋភាពច្បាប់លើការងារតាក់តែងសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងឯកសារផ្សេងៗទៀត។

- ការត្រួតពិនិត្យលើលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមិនស្របនឹងលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល

- ការតាមដាន ពិនិត្យ និងពិចារណាលើគ្រប់សំណើរបស់ក្រសួងស្ថប័ន និងលើកយោបល់តាមកម្មវិធីនយោបាយ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលតាមទិដ្ឋភាពច្បាប់ សេដ្ឋកិច្ចសង្គម និងវប្បធម៌ ជូននាយករដ្ឋមន្ត្រីដើម្បីពិនិត្យ និងសម្រេច

- ការរៀបចំកម្មវិធីការងាររបស់រាជរដ្ឋាភិបាល និងធ្វើរបាយការណ៍ប្រចាំសប្តាហ៍ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ការរៀបចំអង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី អង្គប្រជុំអន្តរក្រសួង កិច្ចប្រជុំជំនាញបច្ចេកទេស និងអង្គប្រជុំផ្សេងៗទៀត

- ការអនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

### ២.៣.២ តួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាល

គណៈរដ្ឋមន្ត្រីបំពេញតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលចំពោះការ៖

- សិក្សា និងវិភាគអំពីទិដ្ឋភាពច្បាប់ និងសភាពការណ៍សេដ្ឋកិច្ច សង្គម និងវប្បធម៌

- ជួយលើកិច្ចការនយោបាយ សិទ្ធិមនុស្ស ការពង្រឹង និងពង្រីកទំនាក់ទំនងជាមួយសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល។

- ពង្រឹងការអភិវឌ្ឍប្រទេសជាតិ កិច្ចការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ការពារជាតិ និងអភិបាលកិច្ចល្អ តាមរយៈយន្តការគណៈកម្មាធិការក្រុមប្រឹក្សា និងអាជ្ញាធរ។

- តម្កល់ និងថែរក្សាសំណៅដើមព្រះរាជក្រម ព្រះរាជក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត រៀបចំសំណៅដែលមានតម្លៃជាការចែកផ្សាយព្រះរាជក្រម និងព្រះរាជក្រឹត្យ។

- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

### ២.៣.៣ តួនាទីគ្រប់គ្រង និងចាត់ចែងការងាររបស់ទីស្តីការគណៈរដ្ឋមន្ត្រី

ចំពោះការគ្រប់គ្រង និងចាត់ចែងការងាររបស់ទីស្តីការគណៈរដ្ឋមន្ត្រីគឺ៖

- សិក្សាស្រាវជ្រាវ តាមដាន ពិនិត្យពិចារណា និងផ្តួចផ្តើមលើកយោបល់ជូននាយករដ្ឋមន្ត្រីលើគ្រប់វិស័យ

- សិក្សាស្រាវជ្រាវដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន ដើម្បីលើកគម្រោងកសាងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

- ទំនាក់ទំនង សម្របសម្រួល និងផ្តល់យោបល់ដល់ក្រសួងស្ថាប័នពាក់ព័ន្ធនឹងការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតឲ្យស្របតាមអាទិភាពនៃកម្មវិធីនយោបាយ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- សិក្សា និងតាមដានអត្ថបទច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលត្រូវបានប្រកាសឲ្យប្រើហើយ តែលែងសមស្របនឹងសភាពការណ៍ជាក់ស្តែង ដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាលក្នុងការពិនិត្យ និងសម្រេចស្នើសុំធ្វើវិសោធនកម្ម ឬធ្វើការកែសម្រួល

- រក្សាការពារកិត្យានុភាពរបស់រាជរដ្ឋាភិបាល ដោយធ្វើការស្រាយបំភ្លឺតាមរយៈការធ្វើប្រតិកម្មរហ័ស ការធ្វើសន្និសីទកាសែត សិក្ខាសាលា ឬបណ្តាញព័ត៌មានសង្គមផ្សេងៗ

- តាមដាន ពិនិត្យ និងជំរុញការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល

- គ្រប់គ្រង និងសម្របសម្រួលការងាររបស់ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី

- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងមន្ត្រីរាជការរបស់ទីស្តីការគណៈរដ្ឋមន្ត្រី

- គ្រប់គ្រង និងដោះស្រាយថវិកា មធ្យោបាយសម្ភារៈ ដើម្បីបម្រើសកម្មភាពនានារបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងនាយករដ្ឋមន្ត្រី

- គ្រប់គ្រងការងាររាជកិច្ច

- គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យារបស់ទីស្តីការគណៈរដ្ឋមន្ត្រី

- គ្រប់គ្រង និងថែរក្សាឯកសាររបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងឯកសាររបស់ជាតិ

- ពិនិត្យ និងរៀបចំគ្រឿងឥស្សរិយយស សញ្ញាសក្តិ និងឯកសណ្ឋាន

- ទទួលបន្ទុករ៉ាប់រងការងារពិធីការសម្រាប់នាយករដ្ឋមន្ត្រី និងថ្នាក់ដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រី

- ការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈនៅបរិវេណទីស្តីការគណៈរដ្ឋមន្ត្រី

- គ្រប់គ្រង និងសម្របសម្រួលការងាររបស់រាជបណ្ឌិត្យសភាកម្ពុជា

- គ្រប់គ្រង និងសម្របសម្រួលការងារមេធាវីរាជរដ្ឋាភិបាល

- ចាត់ចែងបញ្ជូនសេចក្តីព្រាងច្បាប់ទៅស្ថាប័ននីតិប្បញ្ញត្តិដើម្បីសុំការពិនិត្យ និងអនុម័ត ព្រមទាំងសម្របសម្រួលសហការជាមួយក្រសួង ស្ថាប័ន ដើម្បីរៀបចំតំណាងរាជរដ្ឋាភិបាលទៅការពារសេចក្តីព្រាងច្បាប់នៅស្ថាប័ននីតិប្បញ្ញត្តិ។

- រៀបចំបែបបទថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឲ្យប្រើច្បាប់

- សម្របសម្រួលការងារសំណួរ ចម្លើយសភា

- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

## ២.៤ សមត្ថកិច្ចរបស់នាយករដ្ឋមន្ត្រី និងសមាជិករដ្ឋាភិបាល

### ២.៤.១ នាយករដ្ឋមន្ត្រី

នាយករដ្ឋមន្ត្រីដឹកនាំគ្រប់កិច្ចការទាំងអស់របស់គណៈរដ្ឋមន្ត្រី និងបញ្ជាចាត់ចែងរាល់សកម្មភាពរបស់គណៈរដ្ឋមន្ត្រីលើគ្រប់វិស័យ។ លើកលែងតែប្រធានស្ថាប័នរដ្ឋ ជាធម្មតាសមាជិកនៃគណៈរដ្ឋមន្ត្រី ត្រូវបានប្រគល់ភារកិច្ច និងការទទួលខុសត្រូវ ដោយសេចក្តីសម្រេចរបស់នាយករដ្ឋមន្ត្រី។ តួនាទី និងភារកិច្ចនាយករដ្ឋមន្ត្រីមានដូចតទៅ៖

១.នាយករដ្ឋមន្ត្រី ជាប្រមុខរដ្ឋាភិបាលមានភារកិច្ចទទួលខុសត្រូវរួមជាមួយសមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល ចំពោះមុខសភា អំពីនយោបាយទូទៅ និងសកម្មភាពរបស់រាជរដ្ឋាភិបាល។

២.នាយករដ្ឋមន្ត្រី ដឹកនាំការងាររបស់គណៈរដ្ឋមន្ត្រី ចាត់ចែង បញ្ជារាល់សកម្មភាពរបស់រដ្ឋាភិបាលលើគ្រប់វិស័យ។

៣.នាយករដ្ឋមន្ត្រី ជាអ្នកកោះប្រជុំ និងជាអធិបតីអង្គប្រជុំ។ អង្គប្រជុំពេញអង្គរបស់គណរដ្ឋមន្ត្រី សម្រេចដោះស្រាយរាល់ភារកិច្ចទូទៅរបស់រដ្ឋាភិបាល។

៤.នាយករដ្ឋមន្ត្រី អាចប្រគល់សិទ្ធិជូនសមាជិករាជរដ្ឋាភិបាលណាម្នាក់ កោះប្រជុំ និងធ្វើជាអធិបតីអង្គប្រជុំអន្តរក្រសួង ប៉ុន្តែអង្គប្រជុំនេះគ្មានសិទ្ធិសម្រេចលើការងារតាងនាមរាជរដ្ឋាភិបាលឡើយ។

៥.នាយករដ្ឋមន្ត្រី ដឹកនាំការចរចារ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្របច្ចេកទេស និងការពារប្រទេស។ នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិឲ្យសមាជិកណាម្នាក់ជាអ្នកចរចា និងជាអ្នកចុះហត្ថលេខា។

៦.នាយករដ្ឋមន្ត្រី ចុះហត្ថលេខាលើអនុក្រឹត្យ សេចក្តីសម្រេច និងសារាចររបស់គណៈរដ្ឋមន្ត្រី។

៧.នាយករដ្ឋមន្ត្រី លើកសំណើដល់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ឲ្យកោះប្រជុំ រដ្ឋសភាជាវិសាមញ្ញ លើកសំណើស្តីពីសេចក្តីព្រាងច្បាប់ និងសំណើតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចសមាជិករដ្ឋាភិបាល ជូនរដ្ឋសភាដើម្បីអនុម័ត។[33]

៨.នាយករដ្ឋមន្ត្រី លើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យ (ដោយមិនបាច់ឆ្លងកាត់សភាអនុម័ត) នូវមុខតំណែងមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិដូចតទៅៈ

- ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង ឬមុខតំណែងប្រហាក់ប្រហែល
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ឯកអគ្គរាជទូត ឬមុខតំណែងប្រហាក់ប្រហែល
- ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព
- អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរង និងនាយសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ
- អគ្គស្នងការនគរបាលជាតិ

មុខតំណែង និងក្របខណ្ឌមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយុទ្ធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិចាប់ពីថ្នាក់ឧត្តមសេនីយ៍ឡើង ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ស្របតាមបទប្បញ្ញត្តិជាធរមាន។[34]

៩.នាយករដ្ឋមន្ត្រីតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបានជាតិ។ [35]

១០.ក្នុងករណីពិសេស ឬប្រធានសក្តិ នាយករដ្ឋមន្ត្រីមានសិទ្ធិបញ្ជាចំណាយក្រៅពីការកំណត់ក្នុងថវិកាជាតិ ដើម្បីដោះស្រាយកិច្ចការចាំបាច់ និងបន្ទាន់ រួចរាយការណ៍ជូនរដ្ឋសភាភ្លាម។

១១.នាយករដ្ឋមន្ត្រី ដឹកនាំការងាររបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

១២.នាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតសើរើ ឬធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ។[36]

១៣.នាយករដ្ឋមន្ត្រីអាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ ទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពីធម្មនុញ្ញភាពរបស់ច្បាប់ទាំងមុន និងក្រោយព្រះមហាក្សត្រប្រកាសឲ្យប្រើ។

[33] មាត្រា១៩, ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ២០១៨។

[34] មាត្រា២៣, ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ២០១៨។

[35] មាត្រា២៣, ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ២០១៨។

[36] មាត្រា ១៥៣ថ្មី(ពីរ), រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា, ១៩៩៣

១៤.នាយករដ្ឋមន្ត្រីត្រួតពិនិត្យការងារ សកម្មភាព អំពើប្រព្រឹត្ត និងការទទួលខុសត្រូវរបស់សមាជិករដ្ឋាភិបាល ហើយមានសិទ្ធិដក និងដាក់ជំនួសសមាជិករដ្ឋាភិបាលតាមបែបបទ និងនីតិវិធីជាធរមាន។

១៥.នាយករដ្ឋមន្ត្រី ជាសមាជិកក្រុមប្រឹក្សារាជសម្បត្តិ[37]។

១៦.នាយករដ្ឋមន្ត្រីកោះអញ្ជើញប្រជុំសមាជជាតិ[38]។

១៧.នាយករដ្ឋមន្ត្រី ដឹកនាំគណៈរដ្ឋមន្ត្រីចូលគាល់ និងរាយការណ៍ពីសភាពការណ៍ប្រទេសជាតិថ្វាយព្រះមហាក្សត្រ១ខែ ២ដង[39]។

## ២.៤.២ តួនាទី និងភារកិច្ចឧបនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី ជាសមាជិករាជរដ្ឋាភិបាលដែលមានអសនាក្រម(អំណាច)លើ សមាជិកដទៃទៀតតែក្រោមនាយករដ្ឋមន្ត្រី[40] ។ ឧបនាយករដ្ឋមន្ត្រីមានភារកិច្ចដូចតទៅ៖

១.នៅពេលនាយករដ្ឋមន្ត្រីអវត្តមាន ឧបនាយករដ្ឋមន្ត្រីទទួលការងារជំនួសតាមការប្រគល់សិទ្ធិចំពោះមុខនាយករដ្ឋមន្ត្រី។

២.ឧបនាយករដ្ឋមន្ត្រីជួយការងារនាយករដ្ឋមន្ត្រីតាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី។

៣.កិច្ចការដែលទាក់ទងការដឹកនាំរបស់រាជរដ្ឋាភិបាល បើគ្មានការយល់ព្រមពីនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីគ្មានសិទ្ធិសម្រេចឡើយ។

## ២.៤.៣ តួនាទី និងភារកិច្ចទេសរដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រីមួយចំនួនដឹកនាំក្រសួង ចំណែកទេសរដ្ឋមន្ត្រីមួយចំនួនទៀតដែលមិនដឹកនាំក្រសួង ត្រូវទទួលបន្ទុកបេសកកម្មពិសេសតាមការប្រគល់ភារកិច្ចពីនាយករដ្ឋមន្ត្រី។

## ២.៤.៤ តួនាទី និងភារកិច្ចរដ្ឋមន្ត្រី

សមាជិកទាំងឡាយនៃរដ្ឋាភិបាលដែលដឹកនាំក្រសួងហៅថា រដ្ឋមន្ត្រី។[41] រដ្ឋមន្ត្រីមានតួនាទី និងភារកិច្ចសំខាន់ៗដូចខាងក្រោម៖

១.រដ្ឋមន្ត្រីដែលដឹកនាំក្រសួងហៅថា ប្រធានស្ថាប័ន។ ប្រធានស្ថាប័នដឹកនាំការងារក្នុងស្ថាប័ន និងអង្គភាពចំណុះតាមវិស័យទទួលខុសត្រូវរបស់ខ្លួន។

---

[37] មាត្រា១៣ថ្មី, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[38] មាត្រា១៤៨ថ្មី, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[39] មាត្រា២០, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[40] មាត្រា២៩, ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ២០១៨។

[41] [41] មាត្រា២៩, ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ២០១៨។

២.គ្រប់គ្រងបុគ្គលិកមន្ត្រីរាជការដែលជាភ្នាក់ងាររដ្ឋបាលកណ្ដាល និងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្រោមឱវាទ។

៣.ទទួលខុសត្រូវរៀងៗខ្លួនចំពោះនាយករដ្ឋមន្ត្រី និងរដ្ឋសភា ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។

៤.ប្រធានស្ថាប័ន មានសិទ្ធិលើកសំណើតែងតាំង ផ្លាស់ប្ដូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមានចាប់ពីថ្នាក់ប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ និងថ្នាក់វរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ជូននាយករដ្ឋមន្ត្រីដើម្បីចេញជា "អនុក្រឹត្យ"។

៥.ប្រធានស្ថាប័ន មានសិទ្ធិតែងតាំង ផ្លាស់ប្ដូរ និងបញ្ចប់ភារកិច្ចមន្ត្រីក្រោមឱវាទតាមបែបបទនីតិវិធីជាធរមានដោយ "ប្រកាស" ចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល និងថ្នាក់ក្រោមវរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ។

៦.ប្រធានស្ថាប័ន មានសិទ្ធិចេញ ប្រកាស សេចក្ដីសម្រេច សារាចរ និងសេចក្ដីណែនាំ ។

៧.ប្រធានស្ថាប័នចេញ ប្រកាសស្ដីពីការរៀបចំរចនាសម្ព័ន្ធក្រសួង និងរដ្ឋលេខាធិការដ្ឋានចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ។

### ២.៤.៥ តួនាទី និងភារកិច្ចរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទើបតែបង្កើតឡើងក្នុងរាជរដ្ឋាភិបាលអាណត្តិទី៤នេះ។ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនេះភាគច្រើនជារដ្ឋលេខាធិការនៅតាមក្រសួងនានា។[42] ប៉ុន្តែរដ្ឋមន្ត្រីប្រតិភូនេះ ត្រូវទទួលការងារពិសេសផ្ទាល់ពីនាយករដ្ឋមន្ត្រី បន្ថែមពីលើមុខងារបច្ចុប្បន្នផងដែរ។ នៅក្នុងរាជរដ្ឋាភិបាលអាណត្តិទី៤នេះ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីមានតែ៨រូបប៉ុណ្ណោះ ហើយជាមនុស្សពិសេសរបស់នាយករដ្ឋមន្ត្រី ដើម្បីធ្វើការងារចាំបាច់ និងសំខាន់ៗមួយចំនួនរបស់នាយករដ្ឋមន្ត្រីដែលបានប្រគល់ជូន។

### ២.៤.៦ តួនាទី និងភារកិច្ចរដ្ឋលេខាធិការ

រដ្ឋលេខាធិការមាន២យ៉ាងគឺ៖

ទី១៖ រដ្ឋលេខាធិការ ដែលដឹកនាំរដ្ឋលេខាធិការដ្ឋានហៅថា ប្រធានស្ថាប័ន ហើយមានតួនាទីដូចរដ្ឋមន្ត្រីដែរ។

ទី២៖ រដ្ឋលេខាធិការ ដែលមិនមែនជាប្រធានស្ថាប័ន ឬដែលដឹកនាំដោយរដ្ឋមន្ត្រី។ រដ្ឋលេខាធិការទាំងនោះហៅថា អនុប្រធានស្ថាប័នដែលមានភារកិច្ចអនុវត្តការងារផ្សេងៗតាមការប្រគល់ជូនពីរដ្ឋមន្ត្រីជាដើម។

### ២.៤.៧ តួនាទី និងភារកិច្ចអនុរដ្ឋលេខាធិការ

អនុរដ្ឋលេខាធិការ ជួយការងារក្នុងក្រសួង ឬរដ្ឋលេខាធិការដ្ឋានតាមការប្រគល់ភារកិច្ចពីប្រធានស្ថាប័ន។

[42] 42 មាត្រា៤៥, ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ២០១៨។

## ២.៥ ការរំលាយរាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលអាចត្រូវបានរំលាយដោយមូលហេតុមួយចំនួនដូចខាងក្រោម៖

១.នៅពេលរដ្ឋសភាចប់អាណត្តិ ៥ឆ្នាំ រដ្ឋាភិបាលក៏អស់អាណត្តិដែរ។

២.ក្នុងករណីដែលរដ្ឋសភាអនុម័តញត្តិបន្ទោសដើម្បីទម្លាក់រដ្ឋាភិបាល តាមសម្លេងឆ្នោតភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល តាមមាត្រា៩៨ថ្មីនៃរដ្ឋធម្មនុញ្ញ។

៣.ការរំលាយរដ្ឋាភិបាលតាមមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញដែលចែងថា "តំណែងនាយករដ្ឋមន្ត្រីនៅ ទំនេរជាស្ថាពរនេះ" គឺតំណែងនេះអាចទំនេរជាស្ថាពរដោយមូលហេតុដូចខាងក្រោម៖

- ដោយនាយករដ្ឋមន្ត្រីលាឈប់
- ដោយនាយករដ្ឋមន្ត្រីស្លាប់
- ដោយនាយករដ្ឋមន្ត្រីប្រកាសចូលនិវត្តន៍
- នាយករដ្ឋមន្ត្រីត្រូវទម្លាក់ដោយរដ្ឋសភា។

៤.ការរំលាយរដ្ឋាភិបាលតាមមាត្រា១២៦ថ្មី នេះបើនាយករដ្ឋមន្ត្រីមានទោសលើបទមជ្ឈិម ឬបទឧក្រិដ្ឋដូចជាការសម្លាប់មនុស្ស សកម្មភាពឧក្រិដ្ឋផ្សេងៗទៀត...ដូចចែងក្នុងក្រមព្រហ្មទណ្ឌ រដ្ឋាភិបាលក៏ត្រូវរំលាយផងដែរ។ នាយករដ្ឋមន្ត្រីក៏អាច "ធ្វើខុសធ្ងន់" ក្នុងការបំពេញការងាររបស់ខ្លួនដូចជាពុករលួយ បក្សពួកនិយម ឬគ្រួសារនិយម ឬបានធ្វើផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញធ្ងន់ធ្ងរ ការកឹបកេងបំបាត់ពន្ធ បំបាត់ចំណូលរដ្ឋជាដើម។

៥.ការរំលាយរដ្ឋាភិបាលតាមមាត្រា១២០ថ្មីនេះ គឺមុខងារនៃសមាជិករាជរដ្ឋាភិបាលមានវិសមិតភាពនឹងសកម្មភាពខាងវិជ្ជាជីវៈ ផ្នែកពាណិជ្ជកម្ម ឬឧស្សាហកម្ម ហើយនិងការកាន់តំណែងណាមួយក្នុងមុខងារ សាធារណៈ។

៦.រដ្ឋាភិបាលអាចត្រូវបានរំលាយដោយធ្វើរដ្ឋប្រហារ ឬការដូររបបដឹកនាំ។ បើការបញ្ចប់អាណត្តិរដ្ឋាភិបាលតាមចំណុចទី១ខាងលើ គេត្រូវរៀបចំបោះឆ្នោតជ្រើសរើសរដ្ឋសភា និងរៀបចំបង្កើតរដ្ឋាភិបាលជាថ្មីម្តងទៀតទាំងអស់គ្នា ហើយគេបង្កើតរដ្ឋសភា និងរដ្ឋាភិបាលដូចរៀបរាប់ខាងលើ ប៉ុន្តែបើការបញ្ចប់អាណត្តិរាជរដ្ឋាភិបាលតាមចំណុចទី២ ទី៣ ទី៤ និងទី៥ គេមិនបាច់រៀបចំបោះឆ្នោតជ្រើសរើសរដ្ឋសភាជាថ្មីទេ ដោយបង្កើតរដ្ឋាភិបាលតែម្តងតាមមាត្រា១១៩ថ្មី និងមាត្រា៩០ថ្មី(ពីរ)នៃរដ្ឋធម្មនុញ្ញ គឺជ្រើសរើសបេក្ខជន នាយករដ្ឋមន្ត្រីពីគណៈបក្សដែលទទួលអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ឲ្យរៀបចំបញ្ជីឈ្មោះសមាជិករដ្ឋាភិបាលជាថ្មី នឹងទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភាតាមសម្លេងឆ្នោតភាគច្រើនដាច់ខាត។ បើនាយករដ្ឋមន្ត្រីធ្លាក់ពីតំណែងគឺ សមាជិករាជរដ្ឋាភិបាលត្រូវរំលាយទាំងអស់។

# ជំពូកទី៣ ស្ថាប័នតុលាការ

ជាគោលការណ៍ ការរៀបចំជារាងសាជីជ្រុងនូវតុលាការកម្ពុជាគឺមានចែងនៅក្នុងមាត្រា១២៨ នៃរដ្ឋធម្ម-នុញ្ញដែលបញ្ញត្តិថា អំណាចតុលាការត្រូវប្រគល់ទៅឲ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។ នៅខាងក្រោមសាជីជ្រុងមានសាលាជម្រះក្តីថ្នាក់ទីមួយ និងសាលាជម្រះក្តីថ្នាក់ទីពីរ ហើយនៅកំពូលនៃសាជីជ្រុងមានសាលាជម្រះក្តីផ្នែកអង្គច្បាប់គឺតុលាការកំពូល។

## ៣.១ សាលាជម្រះក្តីថ្នាក់ទី១

អំណាចតុលាការជាអំណាចឯករាជ្យដែលគ្របដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផងដែរ។[43] នៅក្នុងច្បាប់វិជ្ជមាន គេឃើញមានសាលាដំបូងជាសាលាជម្រះក្តីជាន់ទាបដែលត្រូវបែងចែកជាតុលាការជំនាញ និងតុលាការពិសេសមួយគឺតុលាការយោធា។ តុលាការជាន់ទាបនេះទទួលដោះស្រាយរឿងក្តីដំបូងគេបំផុត។

### ៣.២.១. សាលាដំបូង

សាលាដំបូងជាសាលាជម្រះក្តីថ្នាក់ទីមួយ ដែលបង្កើតឲ្យមាននៅរាជធានីភ្នំពេញ និងនៅគ្រប់ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

#### ៣.២.១.១ អង្គការលេខនៃសាលាដំបូង

រចនាសម្ព័ន្ធរបស់សាលាដំបូងរួមមាន៖

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅសាលាដំបូង។

#### ៣.២.១.២ សមត្ថកិច្ចរបស់សាលាដំបូង

សាលាដំបូង គឺជាសាលាជម្រះក្តីទូទៅដែលមានសមត្ថកិច្ចជំនុំជម្រះក្តីទៅលើរឿងក្តីទាំងអស់ លើកលែងតែរឿងក្តីដែលស្ថិតនៅក្រោមសមត្ថកិច្ចនៃសាលាជម្រះក្តីពិសេស ឬសាលាជម្រះក្តីវិសាមញ្ញដែលបង្កើតឡើងដោយច្បាប់ដោយឡែក។ ក្នុងករណីមានវិវាទសមត្ថកិច្ចរវាងតុលាការជំនាញផ្សេងៗនៅក្នុងសាលាដំបូង ប្រធានសាលាដំបូងត្រូវកោះប្រជុំប្រធានតុលាការជំនាញដើម្បីសម្រេចអំពីសមត្ថកិច្ច។[44]

---

[43] មាត្រា១២៨ថ្មី វាក្យខណ្ឌទី៣, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

[44] មាត្រា១៩-៣, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ២០១៤។

**៣.២.១.៣ នីតិវិធីក្នុងពេលសវនាការរបស់សាលាដំបូង**

នៅក្នុងពេលសវនាការ អ្នកគ្រប់គ្នាអាចបញ្ចេញយោបល់របស់ខ្លួនបាន លុះត្រាតែប្រធានសវនាការអនុញ្ញាតឲ្យបញ្ចេញយោបល់ ហើយសវនាការអាចប្រព្រឹត្តទៅបានលុះត្រាប្រធានសវនាការប្រកាសបើកជាមុនសិន ប្រសិនបើមេធាវីចង់មោឃភាពនីតិវិធីសវនាការ ត្រូវសុំធ្វើមុនដំណាក់កាលសួរដេញដោល បើសិនជាចូលដំណាក់កាលសួរដេញដោលហើយ គឺមិនអាចមោឃភាពនីតិវិធីបានទេ។

-ដំណាក់កាលចុងក្រោយ គឺនៅពេលប្រកាសសាលក្រមជនទាំងឡាយត្រូវក្រោកឈរឡើង ហើយចៅក្រមប្រកាសថាលើកលែង ឬដាក់ពន្ធនាគារទៅលើជននោះ។ ក្រឡាបញ្ជីត្រូវឲ្យជនជាប់ចោទផ្ដិតមេដៃទទួលដឹងឮខ្លួនឯង។

**៣.១.២ តុលាការយោធា**

តុលាការយោធាមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ដែលជាប្រភេទតុលាការជាន់ទាបដែលមានសមត្ថកិច្ចជំនុំជំរះរឿងក្ដី ដែលទាក់ទងទៅនឹងបទល្មើសមានលក្ខណៈយោធា ឬបទល្មើសប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធ ដែលប្រព្រឹត្តិដោយសមាជិកយោធិន។ ចំពោះយោធាដែលប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌសាមញ្ញត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការនៃនីតិរួម។ រាល់សកម្មភាពទាំងអស់របតុលាការយោធា ត្រូវរាយការណ៍ទៅក្រសួងការពារជាតិ ដូចជាស្ថិតិនៃការស៊ើបអង្កេត និងការជំនុំជម្រះជាដើម។ បើផ្អែកតាមច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំនុំជម្រះក្ដីរដ្ឋកម្ពុជាឆ្នាំ១៩៩៣ គេមិនបានចែងអំពីតំបន់ភូមិសាស្ត្រ ដែលតុលាការយោធាមានសមត្ថកិច្ចគ្របដណ្ដប់ឡើយ ប៉ុន្តែគេយល់ថា គឺគ្របដណ្ដប់លើដែនដីទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា។

## ៣.២ សាលាជម្រះក្ដីថ្នាក់ទី២

សាលាឧទ្ធរណ៍គឺជាសាលាជម្រះក្ដីថ្នាក់ទី២។ សាលាជម្រះក្ដីជាន់ខ្ពស់នេះជំនុំជម្រះលើអង្គហេតុ និងអង្គច្បាប់លើបណ្ដឹងឧទ្ធរណ៍អំពីសាលក្រមនៃសាលាដំបូងរាជធានី-ខេត្ត និងតុលាការយោធាដោយបើផ្លូវឲ្យប្ដឹងសា-ទុក្ខ។ កាលដែលសាលាឧទ្ធរណ៍បំពេញតួនាទីដូចគ្នា នឹងតុលាការថ្នាក់ក្រោមលើអង្គហេតុ និងអង្គច្បាប់នេះ អាចមានប្រយោជន៍ដល់គូក្ដីដែលចាញ់ក្ដីត្រង់ថា គេអាចសាកល្បងរកលទ្ធផលសារជាថ្មីបាន ប៉ុន្តែវាបានផ្ដល់នូវផលវិបាក ធ្វើឲ្យសំណុំរឿងក្នុងតុលាការនេះកាន់តែកើនឡើងច្រើនៗផងដែរ និងម្យ៉ាងទៀតអាចធ្វើឲ្យគូភាគីដែលចាញ់ក្ដីមានគំនិតខិលខូច អាចធ្វើការពន្យាការអនុវត្តសាលក្រម ដោយយកបណ្ដឹងឧទ្ធរណ៍ធ្វើជាមធ្យោបាយពន្យាពេលវេលាឲ្យចេះតែវែងអន្លាយ។ គេមិនទាន់ឃើញមានច្បាប់ចែងអំពីនីតិវិធីបណ្ដឹងឧទ្ធរណ៍ ឬការកំណត់ដាក់ពិន័យដល់បណ្ដឹងឧទ្ធរណ៍ណាដែលមិនសមហេតុផលនោះដាច់ ដោយឡែកនៅឡើយទេដើម្បីបន្ថយបណ្ដឹងឧទ្ធរណ៍ ដែលមិនសមហេតុផល។

### ៣.២.១ អង្គការលេខនៃសាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍រួមមានសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានទីតាំងនៅរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍តំបន់ ដែលមានដូចជា សាលាឧទ្ធរណ៍តំបន់បាត់ដំបង សាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ។ សមាសភាពនៅក្នុងសាលាឧទ្ធរណ៍ និងសាលាឧទ្ធរណ៍តំបន់នីមួយៗរួមមាន៖

- ប្រធាន

- អនុប្រធាន

- ចៅក្រម

- ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាន និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការនៅក្នុងសាលាឧទ្ធរណ៍។[45] ម្យ៉ាងវិញទៀត នៅក្នុងសាលាឧទ្ធរណ៍នីមួយៗត្រូវបានចែកចេញជាសភា ដើម្បីដោះស្រាយទៅតាមរឿងក្តីដែលបានកើតឡើង។ ចំពោះនៅក្នុងករណីដែលតុលាការកំពូលបានបង្វិលមកវិញ នោះសាលាឧទ្ធរណ៍ត្រូវជំនុំជម្រះនៅក្នុងសវនាការមួយ ដែលមានចៅក្រមចំនួន០៥រូប ហើយសុទ្ធតែជាចៅក្រមដែលមិនបានចូលរួមជំនុំជម្រះលើកមុន ដោយអនុវត្តតាមបទបញ្ញត្តិស្តីពីនីតិវិធីជាធរមាន។

### ៣.២.២ សមត្ថកិច្ចរបស់សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍មានសមត្ថកិច្ចជំនុំជម្រះរឿក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនលើកលែងតែរឿងក្តីទាំងឡាយណាដែលច្បាប់ប្រគល់សមត្ថកិច្ចឲ្យទៅតុលាការផ្សេង។[46]

### ៣.២.៣ នីតិវិធីក្នុងពេលសវនាការរបស់សាលាឧទ្ធរណ៍

ពេលសវនាការ មុនពេលចាប់ផ្តើមក្រឡាបញ្ជីអាននូវបទបញ្ជាផ្ទៃក្នុងជូនអង្គសវនាការ។ នៅពេលចៅក្រមមកដល់ជនគ្រប់ត្រូវក្រោកឈរ រួចអង្គុយចុះវិញ ក្រោយបានឮប្រសាសន៍របស់លោកចៅក្រមឲ្យអង្គុយចុះ។ បន្ទាប់មកក្រឡាបញ្ជីប្រកាសអំពីវត្តមាន និងអវត្តមាននៃអ្នកចូលរួម។ ប្រធានចៅក្រម(ប្រធានក្រុមប្រឹក្សា) ថ្លែងប្រកាសបើកសវនាការជាសារធារណៈសំណុំរឿង និងប្រកាសពីសមាសភាពចៅក្រមក្រុមប្រឹក្សា។

## ៣.៣ តុលាការកំពូល

តុលាការកំពូលជាស្ថាប័នជំនុំជម្រះក្តីជាន់ខ្ពស់ ហើយមានសមត្ថកិច្ចគ្របដណ្តប់ លើដែនដីទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ។ ការរៀបចំដំណើរការប្រព្រឹត្តទៅរបស់តុលាការកំពូល មានប្រធាន អនុប្រធាន និង ចៅក្រមនៅអមតុលាការកំពូល នៅអង្គការមហាអយ្យការមានអគ្គព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារង ព្រមទាំងក្រឡាបញ្ជីដែលមានកាតព្វកិច្ចចូលរួមក្នុងនីតិវិធីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌក្នុងនាមគូរក្តីដើម។

[45] មាត្រា៣៦, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ២០១៤។
[46] មាត្រា៤១, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ២០១៤។

**៣.៣.១. អង្គការលេខរបស់តុលាការកំពូល**

នៅតុលាកំពូលសមាសភាព រួមមាន៖

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាល ហើយអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការនៅក្នុងតុលាការកំពូល។[47]

**៣.៣.២ សមត្ថកិច្ចរបស់តុលាការកំពូល**

តុលាការកំពូលមានសមត្ថកិច្ចដោះស្រាយរឿងក្តី ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់កំណត់។[48] នៅក្នុងសមត្ថកិចជម្រះក្តីរបស់តុលាការកំពូលគឺមាននីតិវិធីពរដែលរួមមាន។ នីតិវិធីក្នុងពេលសវនាការលើអង្គច្បាប់ និងនីតិវិធីក្នុងពេលសវនាការលើអង្គហេតុ និងអង្គច្បាប់។

**៣.៣.២.១ នីតិវិធីក្នុងពេលសវនាការលើអង្គច្បាប់**

នៅតុលាការកំពូល ជំនុំជម្រះលើបណ្តឹងសាទុក្ខ អំពីសាលដីការបស់សាលាឧទ្ធរណ៍ដោយជំនុំជម្រះតែលើអង្គហេតុទេ ដែលដំណាក់កាលនេះមានចៅក្រមចំនួន៥រូប ហើយ១រូបជាប្រធាន។ តុលាការកំពូលមានដែនសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីការបស់សាលាឧទ្ធរណ៍លើកទី១អំពីអង្គច្បាប់តែប៉ុណ្ណោះ ដែលមានសមាសភាពជំនុំជម្រះធ្វើឡើយដោយចៅក្រមចំនួន៥រូប តែមិនជំនុំជម្រះលើអង្គហេតុទេ។ ការជំនុំជម្រះលើអង្គច្បាប់នេះ គឺដើម្បីពិនិត្យលើសាលដីការបស់សាលាឧទ្ធរណ៍ អំពីលក្ខណៈត្រឹមត្រូវគតិច្បាប់របស់សាលាឧទ្ធរណ៍ ឬមួយក្រែងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍នោះមានកំហុសត្រង់ទម្រង់ច្បាប់ណាមួយ។ ប្រសិនបើការពិនិត្យទៅឃើញថាសាលដីការបស់សាលាឧទ្ធរណ៍ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ហើយនោះ នោះសេចក្តីសម្រេចរបស់តុលាការកំពូល មានអនុភាពអនុវត្តភ្លាមដោយគ្មានការតវ៉ាឡើយ។ ផ្ទុយទៅវិញ ប្រសិនបើសាលដីការបស់តុលាការកំពូលសម្រេចថា សាលដីការបស់សាលាឧទ្ធរណ៍ត្រូវទុកជាមោឃៈ តុលាការកំពូលត្រូវបង្វិលសំណុំរឿងនោះមកឲ្យសាលាឧទ្ធរណ៍ធ្វើការជំនុំជម្រះឡើងវិញ ហើយមានសមាសភាពចៅក្រមចូលរួមជំនុំជម្រះលើកទី២នៃរឿងក្តីនេះ ត្រូវជាសមាសភាពថ្មីដែលមិនមែនជាចៅក្រមដែលជំនុំជម្រះលើកទី១ទេ។

**៣.៣.២.២ នីតិវិធីក្នុងពេលសវនាការលើអង្គហេតុ និងអង្គច្បាប់**

រឿងក្តីដែលមានបណ្តឹងសាទុក្ខលើកទី២ ដែលធ្វើឡើងដោយភាគីណាមួយ មិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ដោយហេតុមកពីចៅក្រមសាលាឧទ្ធរណ៍នេះ មិនបានសម្រេចសេចក្តីឲ្យត្រឹមត្រូវ

[47] មាត្រា៥៦, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ២០១៤។

[48] មាត្រា៦១, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ២០១៤។

តាមការណែនាំរបស់តុលាការកំពូល ដូចនេះតុលាការកំពូលមានសិទ្ធិលើកយកសំណុំរឿងទាំងមូលនោះមកធ្វើការជំនុំជម្រះ រួមទាំងអង្គហេតុ និងអង្គច្បាប់ ហើយមានសមាសភាពចៅក្រមជំនុំជម្រះចំនួន០៩រូប។

## ៣.៤ ការចេញសេចក្តីសម្រេចរបស់សាលាជម្រះក្តីថ្នាក់ទី១ និងថ្នាក់ទី២

### ៣.៤.១ រឿងក្តីព្រហ្មទណ្ឌ

ក្នុងរឿងក្តីព្រហ្មទណ្ឌ ដើម្បីកំណត់បានថា ជនណាម្នាក់មានទោស ឬមិនមានទោស គឺអាស្រ័យលើសេចក្តីសម្រេចចុងក្រោយរបស់សាលាជម្រះក្តីនីមួយៗ ដោយត្រូវឆ្លងកាត់នីតិវិធីសវនាការ ដែលក្នុងន័យច្បាប់ត្រូវបានហៅថាសាលក្រម ឬសាលដីកា។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ សេចក្តីសម្រេចចុងក្រោយដែលកំណត់អំពីពិរុទ្ធភាព ឬការឲ្យរួចផុតពីបទចោទណាមួយ សាលាជម្រះក្តីជាន់ទាប(សាលាដំបូងរាជធានី-ខេត្តនិងតុលាការយោធា) ត្រូវបានហៅថា "សាលក្រម" និងសម្រាប់សាលាជម្រះក្តីជាន់ខ្ពស់ (សាលាឧទ្ធរណ៍ និងតុលាការកំពូល) ត្រូវបានហៅថា "សាលដីកា"។ សាលក្រម និងសាលដីកាមានពីរប្រភេទដូចគ្នាគឺ៖

(១) សាលក្រម ឬសាលដីកាមុនអង្គសេចក្តី ឬហៅថា (សាលក្រម ឬសាលដីកាចាត់របៀប) ។

(២) សាលក្រម ឬសាលដីកាអង្គសេចក្តីរួមមាន៖ សាលក្រម ឬសាលដីកាចំពោះមុខ សាលក្រមឬសាលដីកាដែលចាត់ទុកថាចំពោះមុខ និងសាលក្រម ឬសាលដីកាកំបាំងមុខ។

ចំពោះសាលក្រម ឬសាលដីកាមុនអង្គសេចក្តី (សាលក្រម ឬសាលដីកាចាត់របៀប) គឺជាសាលក្រម ឬសាលដីកាដែលសម្រេចអំពីបញ្ហានីតិវិធី ហើយមិនជំនុំជម្រះដល់អង្គសេចក្តីនោះទេ នៅពេលលេចឡើងនូវអញ្ញត្រកម្ម ឬអង្គហេតុថ្មី ត្រូវចាត់របៀប។

ចំពោះសាលក្រម ឬសាលដីកាអង្គសេចក្តី គឺជាសេចក្តីសម្រេចដែលវិនិច្ឆ័យសេចក្តីដល់អង្គហេតុ និងអង្គច្បាប់ទាំងមូល ក្រោយបញ្ចប់កិច្ចពិភាក្សាដេញដោល(សវនាការ) រួមមាន៖

-សាលក្រម ឬសាលដីកាចំពោះមុខ គឺជាសាលក្រម ឬសាលដីកា ដែលសម្រេចសេចក្តីក្នុងករណីដែលជនជាប់ចោទចូលបង្ហាញខ្លួនក្នុងពេលសវនាការ។ សាលក្រម ឬសាលដីកានៅតែចំពោះមុខដដែល បើទោះបីជនជាប់ចោទចាកចេញពីបន្ទប់សវនាការភ្លាមៗក៏ដោយ។ ម៉្យាងវិញទៀត សាលក្រម ឬសាលដីកាអាចជាចំពោះមុខផងដែរ កាលណាជនជាប់ចោទត្រូវបានសួរចម្លើយនៅទីកន្លែងដែលជននោះនៅ។[49] ចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដែលបានចូលបង្ហាញខ្លួននៅពេលសវនាការ ឬមានអ្នកតំណាងដោយត្រឹមត្រូវនោះ សាលក្រម ឬសាលដីកាត្រូវតែជាសាលក្រម ឬសាលដីកាចំពោះមុខ។ សាលក្រម ឬសាលដីកាចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងចំពោះមុខជនជាប់ចោទនេះ មិនតម្រូវឲ្យមានការបញ្ជូនឡើយ(មិនចាំបាច់ជូនដំណឹងដល់សាមីជនទាំងនោះទៀតឡើយ)។ សាលក្រម ឬសាល

[49] មាត្រា៣០៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧ ។

ដីកាចំពោះមុខអាចប្តឹងឧទ្ធរណ៍ និងប្តឹងសាទុក្ខបាន។[50]

-សាលក្រម ឬសាលដីកាដែលចាត់ទុកថាចំពោះមុខ គឺជាសាលក្រម ឬសាលដីកាដែលសម្រេចសេចក្តីក្នុងករណីដែល នៅពេលសវនាការជនជាប់ចោទមិនបានចូលមកបង្ហាញខ្លួននៅពេលនោះទេ ប៉ុន្តែសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីការកោះហៅនោះ សាលក្រម ឬសាលដីការបៀបនេះត្រូវចាត់ទុកថាចំពោះមុខជនជាប់ចោទ។ សាលក្រម ឬសាលដីកាអាចចាត់ទុកថាចំពោះមុខនេះត្រូវឲ្យដំណឹងដល់ជនជាប់ចោទ ហើយអាចប្តឹងឧទ្ធរណ៍ និងប្តឹងសាទុក្ខបាន។[51]

-សាលក្រម ឬសាលដីកាកំបាំងមុខ គឺជាសាលក្រម ឬសាលដីកាសម្រេចសេចក្តីមួយ នៅពេលសវនាការប្រសិនបើជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលនោះទេ ហើយនឹងប្រសិនបើគ្មានភស្តុតាងបង្ហាញឲ្យឃើញថាសាមីខ្លួនដឹងពីដីកាបញ្ជូនខ្លួនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ។ សាលក្រម ឬសាលដីកា ត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។ ម្យ៉ាងវិញទៀត ចំពោះបុគ្គលកោះហៅក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ឬជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនចូលបង្ហាញខ្លួននៅពេលសវនាការ និងគ្មានអ្នកតំណាងត្រឹមត្រូវទេ សាលក្រម ឬសាលដីកាត្រូវសម្រេចដោយកំបាំងមុខដូចគ្នានឹងជនជាប់ចោទដែរ។ សាលក្រម ឬសាលដីកាកំបាំងមុខនេះ ត្រូវឲ្យដំណឹងដល់សាមីជនទាំងនោះ ហើយសាលក្របុសាលដីកានេះអាចប្តឹងទាស់បាន។[52]

ករណីដែលថាជនម្នាក់ត្រូវបានតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល៦ខែ ជាគោលការណ៍ច្បាប់ចែងថា ប្រសិនបើសាលក្រម ឬសាលដីកាមិនទាន់ចូលជាស្ថាពរទេ គឺតុលាការមិនអាចចាប់ជននោះដាក់ពន្ធនាគារបានភ្លាមៗទេ ព្រោះតុលាការមិនអាចចេញដីកាចាប់ខ្លួនជននោះមុនសាលក្រម ឬសាលដីកាស្ថាពរបានឡើយ។

សរុបជារួម បើទោសរបស់ជននោះនៅកម្រិតក្រោម១ឆ្នាំ ហើយបើសាលក្រម ឬសាលដីកាមិនទាន់ចូលជាស្ថាពរទេ តុលាការគ្មានសិទ្ធិចេញដីកាភ្លាមៗចាប់មនុស្សនោះមកដាក់ពន្ធនាគារមុនពេលសាលក្រម ឬសាលដីកាចូលជាស្ថាពរបានទេ។ តែបើសាលក្រម ឬសាលដីកាចូលជាស្ថាពរហើយ គឺតុលាការអាចចេញដីកាចាប់ជននោះតាមអំណាចរបស់សាលក្រម ឬសាលដីកាស្ថាពរនោះបាន។ ចំពោះផុតការផុតរយៈពេលប្តឹង ដោយតាមនីតិវិធីបើសាលក្រម ឬសាលដីកានោះធ្វើឡើងដោយកំបាំងមុខ គឺគេគិតចាប់ពីថ្ងៃប្រកាស ឬពេលជូនដំណឹងទៅ ដូចជាជូនដំណឹងផ្ទាល់មាត់ ជូនដំណឹងតាមរយៈសារព័ត៌មាន ឬជូនដំណឹងទៅតាមមធ្យោបាយផ្សេងៗទៀតតាមនីតិវិធីច្បាប់។ ប៉ុន្តែក្រោយរយៈពេលជូនដំណឹង១ខែហើយ បើជននោះមិនបានប្តឹងទាស់ទេគឺសាល

[50] មាត្រា៣៦០ ៣៦៣ ៣៦៤ និង៤២០, ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧។

[51] មាត្រា៣៦១ និង៤២០, ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧។

[52] មាត្រា៣៦២ ៣៦៣ ៣៦៤ និង៤០៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧។

ក្រម ឬសាលដីកានោះចូលជាស្ថាពរ។ បើសិនការកាត់ទោសនៅចំពោះមុខវិញ ហើយជននោះទុកមិនប្ដឹងឧទ្ធរណ៍រហូតដល់១ខែគឺចូលជាស្ថាពរហើយ។

### ៣.៤.២ រឿងក្ដីរដ្ឋប្បវេណី

សាលក្រម និងសាលដីការដ្ឋប្បវេណី គឺជាប្រភេទនៃសេចក្ដីសម្រេចរបស់តុលាការផ្នែករដ្ឋប្បវេណី ចំពោះបណ្ដឹងរដ្ឋប្បវេណីណាមួយ។ សាលក្រមរដ្ឋប្បវេណី គឺជាប្រភេទនៃសេចក្ដីសម្រេចរបស់សាលាជម្រះក្ដី រដ្ឋប្បវេណីជាន់ទាប ដែលមានសាលាដំបូងរាជធានី/ខេត្ត លើបណ្ដឹងរដ្ឋប្បវេណីទាំងឡាយណាដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន។ ចំពោះសាលដីការដ្ឋប្បវេណី គឺជាប្រភេទនៃសេចក្ដីសម្រេចចំពោះបណ្ដឹងឧបាស្រ័យផ្នែករដ្ឋប្បវេណីដែលចេញដោយតុលាការជាន់ខ្ពស់ ដែលមានសាលាឧទ្ធរណ៍ និងតុលាការកំពូល។ សាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ ជាសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ផ្នែករដ្ឋប្បវេណីទាំងឡាយណា ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន។ ចំណែកឯសាលដីការបស់តុលាការកំពូល គឺជាប្រភេទនៃសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខផ្នែករដ្ឋប្បវេណីទាំងឡាយណា ដែលបានប្ដឹងមកតុលាការកំពូល។

## ៣.៥ ស្ថាប័នអយ្យការ និងមហាអយ្យការអមសាលាជម្រះក្ដី

ស្ថាប័នអយ្យការ និងមហាអយ្យការគឺជាស្ថាប័នអយ្យការទាំងឡាយ ដែលត្រូវបានដាក់ពង្រាយឲ្យអមនៅតាមសាលាជម្រះក្ដីនីមួយៗគ្រប់ជាន់ថ្នាក់។ អយ្យការ គឺជាស្ថាប័នដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា និងការពារផលប្រយោជន៍សាធារណៈ។[53] អង្គការអយ្យការមិនមែនជាស្ថាប័នដែលទទួលបន្ទុកជម្រះក្ដីដូចតុលាការនោះទេ តែអយ្យការគឺជាភាគីក្នុងរឿងក្ដីព្រហ្មទណ្ឌ ដែលជាអ្នកតំណាងឲ្យផលប្រយោជន៍ទូទៅ និងមានសិទ្ធិក្នុងការធ្វើបណ្ដឹងអាជ្ញា។ ដូចនេះ ដើម្បីអាចបំពេញតួនាទីរបស់ខ្លួនក្នុងនាមជាភាគីរឿងក្ដី អយ្យការត្រូវមានអ្នកតំណាងរបស់ខ្លួននៅក្នុងសាលាជម្រះក្ដី អ្នកតំណាងនោះគឺជាមន្ត្រីស្ថាប័នអយ្យការដែលគេហៅថា "តំណាងអយ្យការ"។ អង្គការអយ្យការគឺមាននៅគ្រប់សាលាជម្រះក្ដី ដែលនៅអមសាលាដំបូង ហៅថា អយ្យការអមសាលាដំបូង នៅអមសាលាឧទ្ធរណ៍ ហៅថាមហាអយ្យការអមសាលាឧទ្ធរណ៍ និងនៅអមតុលាការកំពូល ហៅថាមហាអយ្យការអមតុលាការកំពូល"។

### ៣.៥.១ អយ្យការអមសាលាដំបូង

#### ៣.៥.១.១ សមាសភាពអយ្យការអមសាលាដំបូង

នៅគ្រប់សាលាដំបូងរាជធានី-ខេត្ត គឺមានស្ថាប័នអយ្យការមួយ គេហៅថា អយ្យការអមសាលាដំបូង។ អយ្យការអមសាលាដំបូង គឺជាអ្នកដែលបើកការស៊ើបអង្កេតជាបឋម ឬដំបូងទៅលើរឿងក្ដីព្រហ្មទណ្ឌដែលខ្លួនទទួលបាន។ ក្នុងការស៊ើបអង្កេតនេះស្ថាប័នអយ្យការអមតុលាការដំបូងមានតំណាងអយ្យការដូចជា៖

[53] មាត្រា១៣១ថ្មី, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

- ព្រះរាជអាជ្ញា
- និង ព្រះរាជអាជ្ញារង។[54]

យោងតាមច្បាប់ស្តីពី ការរៀបចំអង្គការតុលាការបានកំណត់ថា សមាសភាពរបស់អយ្យការអមសាលាដំបូងមានដូចជាៈ

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅអយ្យការអមសាលាដំបូង។

**៣.៥.១.២ មុខងារ និងភារកិច្ចរបស់ស្ថាប័នអយ្យការសាលាដំបូង**

អង្គការអយ្យការជាអង្គអវិភាគ។ អយ្យការមានមុខងារធ្វើបណ្តឹងអាជ្ញា និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ព្រមទាំងអនុវត្តមុខងារផ្សេងទៀតតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ។ ព្រះរាជអាជ្ញារងចូលរួមអនុវត្តមុខងាររបស់អយ្យការក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង។ ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន ព្រះរាជអាជ្ញាត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ ដើម្បីជំនួសបាន។ ក្នុងករណីដែលព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពទំនេរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ឲ្យធ្វើជាព្រះរាជអាជ្ញាស្តីទីជំនួសបាន ដើម្បីធានាដំណើរការរបស់អយ្យការអមសាលាដំបូង រហូតដល់មានការតែងតាំងព្រះរាជអាជ្ញាជាផ្លូវការ។[55]

ព្រះរាជអាជ្ញាមានអំណាចលើព្រះរាជអាជ្ញារងទាំងអស់ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ព្រះរាជអាជ្ញាចាត់តាំង និងបែងចែកការងារដល់ព្រះរាជអាជ្ញារងទាំងអស់។ ព្រះរាជអាជ្ញាមានសិទ្ធិធ្វើអធិបញ្ជាឲ្យព្រះរាជអាជ្ញារងធ្វើការចោទប្រកាន់ ឬក៏ចាត់ឲ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ។ សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារងត្រូវតែបញ្ជូនទៅព្រះរាជអាជ្ញាពិនិត្យនៅមុនពេលសវនាការ។

ប្រសិនបើព្រះរាជអាជ្ញាមិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ ហើយតំណាងអយ្យការដែលជាអ្នកធ្វើសេចក្តីសន្និដ្ឋាននោះនៅតែមិនព្រមធ្វើតាមព្រះរាជអាជ្ញាៗអាចចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀតបាន ឬក៏ចាត់តាំងខ្លួនឯងតែម្តង ឲ្យធ្វើជាតំណាងអយ្យការនៅក្នុងសវនាការនៃសាលាដំបូង។[56]

---

[54] មាត្រា២៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, ២០០៧។

[55] មាត្រា៣០, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ២០១៤។

[56] មាត្រា៣១, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ២០១៤។

### ៣.៥.២ មហាអយ្យការអមសាលាឧទ្ធរណ៍

នៅក្នុងសាលាឧទ្ធរណ៍ គឺមានអយ្យការមួយ គេហៅថា មហាអយ្យការអមសាលាឧទ្ធរណ៍ ដែលនៅក្នុងនោះ គឺមានអគ្គព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញាជាដំណាងអយ្យការក្នុងស្ថាប័នោះ។

#### ៣.៥.២.១ សមាសភាពមហាអយ្យការអមសាលាឧទ្ធរណ៍

នៅអមសាលាឧទ្ធរណ៍ មានមហាអយ្យការដែលមានសមាសភាពដូចខាងក្រោម៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍។[57]

#### ៣.៥.២.២ មុខងារ និងភារកិច្ច

តំណាងអយ្យការនៅសាលាឧទ្ធរណ៍ ដែលមានអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិការកិច្ចនៅអង្គការអយ្យការទាំងឡាយដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[58]

### ៣.៥.៣ មហាអយ្យការអមតុលាការកំពូល

មហាអយ្យការអមតុលាការកំពូល គឺជាស្ថាប័នមួយ ដែលមានអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាដែលជាតំណាងអយ្យការនៅអមតុលាការកំពូល។

#### ៣.៥.៣.១ សមាសភាពមហាអយ្យការអមតុលាការកំពូល

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺមានសមាសភាពមួយរូប ក្នុងចំណោមសមាជិក១១រូប នៃសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានព្រះមហាក្សត្រជាប្រធាន ហើយស្ថាប័ននេះមានតួនាទីចម្បងក្នុងការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ ការលុបឈ្មោះ និងការដាក់វិន័យទៅលើទាំងចៅក្រមអាសនៈ និងចៅក្រមអយ្យការទាំងអស់។ នៅអមតុលាការកំពូល មានមហាអយ្យការដែលមានសមាសភាពដូចខាងក្រោម៖

---

[57] មាត្រា៤៩, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ២០១៤។

[58] មាត្រា៣៥, ក្រមនីតិវិធីក្រមព្រហ្មទណ្ឌ, ២០០៧។

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការតុលាការកំពូល។[59]

**៣.៥.៣.២ មុខងារ និងភារកិច្ចរបស់មហាអយ្យការអមតុលាការកំពូល**

ចំណែកនៅក្នុងតួនាទីជំនុំជម្រះវិញ អយ្យការអមតុលាការកំពូល ជាអ្នកចូលរួមស្នើសុំឲ្យមានការគោរពច្បាប់នៅក្នុងពេលដែលមានបណ្តឹងសាទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗទៀត ដែលបានដាក់ជូនតុលាការកំពូលពិនិត្យ។

## ៣.៦. ការដាក់វិន័យចំពោះអ្នកវិជ្ជាជីវៈក្នុងការប្រព្រឹត្តកំហុស

ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស[60]។ ទណ្ឌកម្មខាងវិន័យមាន២ថ្នាក់គឺ ទណ្ឌកម្មថ្នាក់ទី១ និងទណ្ឌកម្មថ្នាក់ទី២។

### ៣.៦.១ ទណ្ឌកម្មថ្នាក់ទី១

ទណ្ឌកម្មថ្នាក់ទី១ រួមមាន៖

ក.ការស្តីបន្ទោសដោយផ្ទាល់មាត់

ខ.ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ.ការផ្អាកមិនឲ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈ តែមិនត្រូវឲ្យលើសពី២ឆ្នាំទេ ឬលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិវិញក្នុងករណីដែលមានចុះឈ្មោះរួចហើយ។

### ៣.៦.២ ទណ្ឌកម្មថ្នាក់ទី២

រីឯទណ្ឌកម្មថ្នាក់ទី២ រួមមាន៖

ក.ការផ្លាស់ដោយបង្ខំ អាចតម្រូវឲ្យទទួលការបណ្តុះបណ្តាលបន្ថែម

ខ.ការព្យួរពីការងារមិនឲ្យមានបៀវត្ស ក្នុងរយៈពេលមិនឲ្យលើសពី១ឆ្នាំ

គ.ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ

ឃ.ការដាក់ឲ្យចូលនិវត្តន៍ដោយបង្ខំ

[59] មាត្រា៦៨, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ២០១៤។

[60] មាត្រា១៣៣ថ្មី, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

ង.ការបញ្ឈប់ពីមុខងារដោយបង្ខំ ការបណ្ដេញចេញពីក្របខណ្ឌ។

ទណ្ឌកម្មថ្នាក់ទី២ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

## ៣.៧ ឯករាជ្យភាពនៃស្ថាប័នតុលាការ

### ៣.៧.១ ការកំណត់ដោយច្បាប់

នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យ៉ាងច្បាស់អំពី អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។

### ៣.៧.២ លក្ខណៈសម្បត្តិនៃចៅក្រម

វិជ្ជាជីវៈចៅក្រមមិនអាចត្រូវបានគេដកហូតពីការងារទេ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេចដាក់ពិន័យលើចៅក្រមដែលប្រព្រឹត្តខុស។

ដោយអំណាចតុលាការជាអំណាចមួយឯករាជ្យ អំណាចតុលាការត្រូវធានារក្សាអានាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងគ្មានអង្គការណាមួយនៃអំណាចនីតិប្រតិបត្តិអាចទទួលអំណាចតុលាការនេះឡើយ។ មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្ដី ហើយចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឹងម៉ាត់ ឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។[61]

ដោយសារចៅក្រមជាអ្នកជម្រះក្ដី ដូចនេះដើម្បីឲ្យការសម្រេចសេចក្ដីរបស់ចៅក្រម ប្រកបទៅដោយយុត្តិធម៌នោះ ចៅក្រមត្រូវមានលក្ខណៈសម្បត្តិដូចតទៅៈ

#### ៣.៧.២.១ ការមានម្ចាស់ការក្នុងការកាត់ក្ដី

វាជាបញ្ហាមួយដ៏សំខាន់នៅក្នុងការជម្រះក្ដី ដោយចៅក្រមត្រូវមានទំនុកចិត្តលើខ្លួនឯង ដោយឈរលើការយល់ឃើញនូវភាពត្រឹមត្រូវ ក្រោយពីធ្វើការពិចារណាថ្លឹងថ្លែងយ៉ាងល្អិតល្អន់ ដោយផ្អែកលើភស្តុតាងដែលមាន និងច្បាប់ដែលមានចែងជាធរមាន។ ការមិនសេចក្ដី?របស់ខ្លួនមិនចាំបាច់មានការសួរយោបល់ពីសំណាក់បុគ្គលណាមួយនោះឡើយ មិនថានោះជាអ្នកមានឋានៈជាអ្វីទេ ខ្លួនត្រូវឈរលើឧត្តមគតិឈរលើភាពពិតប្រាកដដែលបានកើតឡើង ហើយសង្ឃឹមយ៉ាងម៉ុតមាំថា ការសម្រេចសេចក្ដីរបស់ខ្លួនមិនថាអ្នកនោះជានរណា។

#### ៣.៧.២.២ ការមិនមានភាពលម្អៀងនៃចៅក្រម

បានសេចក្ដីថា ដើម្បីឲ្យមានភាពយុត្តិធម៌នោ ចៅក្រមមិនត្រូវមានភាពលម្អៀងទៅលើភាគីណាមួយឡើយ ដោយខ្លួនត្រូវឈរលើជំហរអព្យាក្រឹត្យ និងសច្ចភាពជានិច្ច មិនថាភាគីទាំងនោះជាគ្រួសារសាច់ញាតិ មិត្តភក្ដិ អ្នកស្គាល់គ្នា ឬអ្នកដែលមានការឈ្លោះប្រកែកជាមួយគ្នាក៏ដោយ។ ចៅក្រមក៏មិនត្រូវយកគំនុំផ្ទាល់ខ្លួនធ្វើជាមូលដ្ឋាននៃការសម្រេចរបស់ខ្លួននោះដែរ ពោលគឺចៅក្រមត្រូវកំណត់នូវគោលដៅតែមួយគត់របស់ខ្លួន គឺយក

[61] មាត្រា១២៨ថ្មី និង១២៩ថ្មី, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣។

ភាពយុត្តិធម៌ជូនទៅដល់ភាគីទាំងនោះឲ្យបានសមស្រប។

**៣.៧.២.៣ ការមិនស្ថិតក្រោមឥទ្ធិពលនៃមជ្ឈដ្ឋានដទៃ**

ដោយហេតុអំណាចតុលាការជាអំណាចមួយឯករាជ្យ មានតែចៅក្រមដែលមានសិទ្ធិជម្រះក្តី ដូច្នេះដោយយោងទៅលើអំណាចឯករាជ្យនេះ ចៅក្រមមិនត្រូវទទួលបានការគាបសង្កត់ បង្ខិតបង្ខំ គំរាមកំហែងពីសំណាក់ភាគី ឬក្រុមណាមួយ អង្គការ ឬស្ថាប័នណាមួយ ក្នុងការធ្វើសម្រេចសេចក្តីនោះឡើយ។ ចៅក្រមត្រូវសម្រេចទៅតាមច្បាប់ និងតាមការយល់ឃើញរបស់ខ្លួន ដើម្បីជៀសវាងកុំឲ្យគេចោទប្រកាន់ថាគាត់កាត់ក្តីដោយលម្អៀងលើភាគីម្ខាងៗ ឬស្ថិតនៅក្នុងក្រុមនេះ ឬក្រុមនោះ និងដើម្បីកុំឲ្យប៉ះពាល់ដល់ភាពឥតលម្អៀងរបស់គាត់។

**៣.៧.២.៤ ការជៀសវាងឲ្យផុតនូវអនាគតិទាំងបួន**

ចៅក្រមគ្រប់រូបត្រូវប្រកាន់នូវអនាគតិទាំង៤រួមមាន៖

- ឆន្ទាគតិ៖ ការលម្អៀងទៅតាមមនោសញ្ចេតនា ឬស្អប់
- ទោសាគតិ៖ លម្អៀងដោយការខឹងសម្បារ ក្រេវក្រោធ
- មោសាគតិ៖ លម្អៀងដោយភាពមិនចេះដឹង
- ភ័យាគតិ៖ លម្អៀងដោយភាពភ័យខ្លាច

**៣.៧.២.៥ ការប្រកាន់ខ្ជាប់នូវសីលធម៌ និងគុណធម៌**

ដោយហេតុថា ចៅក្រមត្រូវសម្រេចថាតើត្រូវដាក់ទោស ឬមិនត្រូវដាក់ទោសទៅលើជនល្មើសណាមួយនោះ ដូច្នេះដើម្បីឲ្យការសម្រេចសេចក្តីរបស់ចៅក្រម មានការគោរពកោតខ្លាចពីសំណាក់អ្នកទាំងអស់នោះ ចៅក្រមត្រូវប្រកាន់ខ្ជាប់នូវសីលធម៌ បានសេចក្តីថា ចៅក្រមត្រូវចេះគោរពមនុស្សដែលមានវ័យចំណាស់ជាងខ្លួន ត្រូវចេះនិយាយស្តីដោយក្តីគោរព ទោះបីអ្នកទាំងនោះមានចំណេះដឹងទាបជាងខ្លួនក៏ដោយ ចៅក្រមមិនត្រូវប្រកាន់យកនូវគំនិតមួយថា មានតែខ្លួនដែលខ្លាំងពូកែជាងគេ មានអំណាចលើគេ ចង់ឲ្យស្លាប់គឺស្លាប់ ចង់ឲ្យរស់គឺរស់ ចង់ឲ្យជាប់គុកគឺត្រូវតែជាប់គុកនោះឡើយ។ មិនតែប៉ុណ្ណោះ ផ្នែកគុណធម៌ចៅក្រមត្រូវតែមានផងដែរ ត្រូវគោរពស្រលាញ់ អាណិតអាសូរដល់អ្នកមានភាពស្អាតស្អំស្លូតបូត។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

សរុបជារួមមក នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាក្រកម្ពុជា ត្រូវបានបែងចែកចេញស្ថាប័នជាច្រើន ប៉ុន្តែក្នុងស្មាដៃសារណានេះគឺផ្តោតទៅលើអំណាចទាំង៣ ដែលក្នុងនោះរួមមាន អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ។ អំណាចទាំងបីនោះគឺដាច់ចេញពីគ្នា ប៉ុន្តែវាក៏មានទំនាក់ទំនងទៅលើគ្នាទៅវិញទៅមកផងដែរ។

នៅក្នុងនោះ ស្ថាប័នតុលាការ គឺជាស្ថាប័នឯករាជ្យមួយដែលមានអំណាចដាច់ដោយឡែកពីគេ។ ស្ថាប័នតុលាការនេះផងដែរ គឺជាស្ថាប័នដែលមានកាតព្វកិច្ច ធានារក្សាអនាគតិ ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ និង ស្វែងរកនូវយុត្តិធម៌មក្នុងសង្គម ដោយអនុលោមទៅតាមច្បាប់ដែលត្រូវបានអនុម័តឲ្យប្រើប្រាស់ដោយស្ថាប័ននីតិប្បញ្ញត្តិ។ លើសពីនេះទៅទៀត រាល់សកម្មភាព និងការអនុវត្តច្បាប់របស់អង្គការតុលាការ ត្រូវបានតាមដាន និងឃ្លាំមើលដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានព្រះមហាក្សត្រជាព្រះប្រធាន។ រីឯអំណាចនីតិប្បញ្ញត្តិគឺត្រូវបានបែងចែកជាស្ថាប័នពីរ គឺស្ថាប័នរដ្ឋសភា និងស្ថាប័នព្រឹទ្ធសភា។ ស្ថាប័នទាំងពីរនេះ គឺមានតួនាទីក្នុងការតាក់តែង និងអនុម័តច្បាប់។ លើសពីនេះ ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកឃ្លាំមើលរាល់សកម្មភាព និងកិច្ចការងាររបស់អង្គការនីតិប្បញ្ញត្តិផងដែរ។ ចំណែកឯស្ថាប័ននីតិប្រតិបត្តិក៏ជាស្ថាប័នដាច់ដោយឡែកមួយផ្សេងទៀតដែរ ដោយស្ថាប័ននេះគឺត្រូវបានដឹកនាំដោយរាជរដ្ឋាភិបាល ដែលមាននាយករដ្ឋមន្ត្រីជាប្រមុខ និងឆ្លងកាត់ការបោះឆ្នោតជ្រើសរើសជារៀងរាល់៥ឆ្នាំម្តង។ ស្ថាប័ននេះ គឺមានតួនាទីអនុវត្តច្បាប់ដែលបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិឲ្យបានតឹងរឹង និងមានប្រសិទ្ធភាព។ លើសពីនេះ អង្គការនីតិប្រតិបត្តិក៏មានបេសកកម្មដ៏សំខាន់គឺ ដឹកនាំ គ្រប់គ្រងប្រទេសឲ្យមានការរីកចម្រើន ប្រកបដោយសេចក្តីសុខ សន្តិភាពជូនប្រជាពលរដ្ឋ។

ស្ថាប័នកំពូលទាំងបីនេះ ពិតជាទំនាក់ទំនងយ៉ាងស៊ីសង្វាក់ ដើម្បីឲ្យដំណើរអភិវឌ្ឍន៍នៅក្នុងប្រទេសមានការរីកចម្រើន ដោយហេតុថាស្ថាប័ននីតិប្បញ្ញត្តិជាស្ថាប័នដែលតាក់តែង និងអនុម័តច្បាប់ ដោយច្បាប់ទាំងនេះ ត្រូវបានដាក់ស្នើរដោយស្ថាប័ននីតិប្រតិបត្តិ ដោយមើលទៅលើស្ថានភាពជាក់ស្តែងនៅក្នុងសង្គម។ ច្បាប់ដែលត្រូវបានដាក់ស្នើដោយស្ថាប័ននីតិប្រតិបត្តិ និងបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ និងត្រូវបានយកអនុវត្តដោយស្ថាប័នតុលាការដើម្បីរកយុត្តិធម៌ជូនពលរដ្ឋ និងសង្គម។

## ២. អនុសាសន៍

ដោយឆ្លងតាមការស្រាវជ្រាវនៅក្នុងប្រធានបទស្ថាប័នធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមក ក្រុមរបស់យើងខ្ញុំយល់ឃើញថា នៅកម្ពុជាយើងបានទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ ហើយប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញស្ថាប័នទាំង៣ ដែលរួមមាន ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័នរាជរដ្ឋាភិបាល និងស្ថាប័នតុលាការ គឺជាធាតុផ្សំដែលធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព។ ជាការពិតណាស់ប្រជាជនរស់ពឹងផ្អែកលើរដ្ឋ ហើយរដ្ឋក៏ត្រូវមានរាស្ត្រដែរ។ ប្រជាជនរស់នៅបានសុខក៏អាស្រ័យដោយការដឹកនាំរដ្ឋនៃមេដឹកនាំប្រទេស បើការដឹកនាំរបស់ប្រធានស្ថាប័ន ឬមន្ត្រីដែលធ្វើការរបស់តាមស្ថាប័ន ក្នុងនាមជាអ្នកបម្រើរាស្ត្រមិនមានទសពិត និងព្រះរាជធម៌ និងក្រមសីលធម៌ដូចដែលមានកំណត់នៅក្នុងច្បាប់ ឬលក្ខន្តិកៈនៃមន្ត្រីរាជការ ប្រជារាស្ត្រច្បាស់ជាមានទុក្ខលំបាកយ៉ាងប្រត្យក្រ។ ភាពខ្វះខាតដែលក្រុមយើងខ្ញុំសង្កេតឃើញ យើងខ្ញុំសូមចូលរួមជាយោបល់ដូចខាងក្រោម៖

១. សមាជិករាជរដ្ឋាភិបាល ត្រូវមានមនសិកាក្នុងយកចិត្តទុកដាក់រឿងសុខទុក្ខពលរដ្ឋ ជាជាងគិតតែប្រយោជន៍ផ្ទាល់ខ្លួន និងបក្សពួករបស់ខ្លួន ហើយធ្វើការរំលោភបំពានសិទ្ធិពលរដ្ឋ ក្នុងនាមខ្លួនជាអ្នកបម្រើរាស្ត្រ និងជាអ្នកធ្វើបទបញ្ជា ហើយត្រូវគោរពច្បាប់ និងបទបញ្ជាដែលខ្លួនបានដាក់ចេញមក។

២. អំណាចតុលាការ ជាអំណាចឯករាជ្យ អំណាចតុលាការ ធានារក្សាអនាគតិ និង ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ ចៅក្រមគឺជាអ្នកវិជ្ជាជីវៈដែលមានសិទ្ធិការដាក់ទោស ឬលើកលែងទោសដល់អ្នកដែលស្ថិតក្រោមអំណាចនៃការកាត់ក្តីរបស់ខ្លួន ដូចចៅក្រមត្រូវតែប្រកាន់ខ្ជាប់នូវក្រមសីលធម៌ រួមជាមួយការជៀសឲ្យនូវអនាគតិទាំងបួន។

# ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។
- ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី,លេខ នស/រកម/ ០៦១៨ ២៨ មិថុនា ២០១៨
- ច្បាប់ស្តីពីការជ្រើសតាំងសមាជិកព្រឹទ្ធសភា, លេខ នស/រកម/០៧១៧/០០៦, ២០ មិថុនា ២០១៧
- ច្បាប់ស្តីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤
- ច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម,លេខ នស/រកម/០៧១៤/០១៧, ១៦ កក្កដា ២០១៤
- ច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា, លេខ នស/រកម/ ០១០៨, ១៨ មករា ២០០៨
- ក្រមនីតិវិធីក្រមព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧

## អនុក្រឹត្យ

- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី, លេខ ១១៦អនក្រ.បក, ៦ កញ្ញា ២០១៨។

## សៀវភៅច្បាប់

- ឈុន ណារ៉េត, "សេចក្តីផ្តើមនីតិ", ២០១៦។
- ដុំ អ៊ីម, "ស្ថាប័ននយោបាយនៃព្រះរាជាណាចក្រកម្ពុជា", បោះពុម្ពលើកទី១, ២០១២។
- កាន ច័ន្ទមេត្តា, កើត រិទ្ធិ, ចាំង ស៊ីណាត, ថេង ច័ន្ទសង្វារ, បេអាទ្រីស បាលីវ និង ឡូអ៊ីក អាវីឡាណឺដា "សេចក្តីផ្តើមនៃនីតិកម្ពុជា", សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០០៥។

## គេហទំព័រ

http://national-assembly.org.kh/

https://senate.gov.kh/

https://www.ocm.gov.kh/

http://www.supremecourt.gov.kh/

http://courtofappealpp.gov.kh

http://www.moj.gov.kh/

# បញ្ជីឧបសម្ព័ន្ធ

**១ ឧបសម្ព័ន្ធទី១**

- រចនាសម្ព័ន្ធរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា
- រចនាសម្ព័ន្ធរបស់គណៈកម្មជំនាញនៃរដ្ឋសភា
- អង្គការលេខរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញនៃរដ្ឋសភា
- រចនាសម្ព័ន្ធរបស់ អគ្គលេខាធិការដ្ឋាន

**២ ឧបសម្ព័ន្ធទី ២**

- រចនាសម្ព័ន្ធទីស្តីការគណៈរដ្ឋមន្ត្រី
- រចនាសម្ព័ន្ធក្រសួងពាណិជ្ជកម្ម
- សេចក្តីប្រកាសពត៌មានស្តីពី លទ្ធផលនៃការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីថ្ងៃ២៥ តុលា ២០១៩

**៣ ឧបសម្ព័ន្ធទី៣**

- ដីកាកោះរឿងរដ្ឋប្បវេណីរបស់សាលាដំបូងភ្នំពេញ
- ព្រះរាជក្រឹត្រលេខ នស /០៨១៩/១៣០២, ១៧ សីហា ២០១៩ ស្តីពីការដាក់ដំណើការសាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការងមសាលាឧទ្ធរតំបន់បាត់ដំបង
- ព្រះរាជក្រឹត្រលេខ នស /០៨១៩/១៣០៣, ១៧ សីហា ២០១៩ ស្តីពីការដាក់ដំណើការសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងមហាអយ្យការងមសាលាឧទ្ធរតំបន់ព្រះសីហនុ
- ព្រះរាជក្រឹត្រលេខ នស /០៨១៩/១៣០០, ១៧ សីហា ២០១៩ ស្តីពីការដាក់ដំណើការសាលាឧទ្ធរណ៍តំបន់ភ្នំពេញ និងមហាអយ្យការងមសាលាឧទ្ធរតំបន់ភ្នំពេញ
- ព្រះរាជក្រឹត្រលេខ នស /០៨១៩/១៣០១, ១៧ សីហា ២០១៩ ស្តីពីការដាក់ដំណើការសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការងមសាលាឧទ្ធរតំបន់ត្បូងឃ្មុំ
- សាលដីការរឿងព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ
- រចនាសម្ពន្ធ័ តុលាការសាលាដំបូង និងអយ្យការអមសាលាដំបូង តុលាការសាលាឧទ្ធរណ៍ និង មហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំង តុលាការកំពូលនិង មហាអយ្យការអមតុលាការកំពូល

# ឧបសម្ព័ន្ធទី១

## អង្គការលេខរបស់រដ្ឋសភា



## ឧបសម្ព័ន្ធ

-សេចក្ដីសម្រេចលេខ ២០/២០១៩ កបធ.សសរ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩

-សេចក្ដីសម្រេចលេខ ២៦/២០២០ កបធ.សសរ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២០

## អង្គការលេខរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ





អគ្គាធិការដ្ឋាន
អគ្គលេខាធិការដ្ឋាន
អគ្គាធិការដ្ឋាន
អគ្គនាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ
នាយកដ្ឋាន រដ្ឋបាល
នាយកដ្ឋាន ហិរញ្ញវត្ថុ
នាយកដ្ឋាន គ្រប់គ្រងបុគ្គលិក
នាយកដ្ឋាន អភិវឌ្ឍន៍ធនធានមនុស្ស
នាយកដ្ឋានគ្រប់គ្រងអគារ សារពើភ័ណ្ឌនិងសំណង់
នាយកដ្ឋាន ផែនការ និងសរុប
អង្គភាព សន្តិសុខ
អគ្គនាយកដ្ឋាន ព័ត៌មាន និងទំនាក់ទំនង សាធារណៈ
នាយកដ្ឋាន ព័ត៌មាន
នាយកដ្ឋាន ព័ត៌មានវិទ្យា(ICT)
បណ្ណាល័យ
បណ្ណសារដ្ឋាន
អគ្គនាយកដ្ឋាន សេវាច្បាប់ និងសមូហភាពដែនដី
នាយកដ្ឋាន នីតិវិធី
នាយកដ្ឋាន ភូមិភាគ និងសមូហភាពដែនដី
លេខាធិការដ្ឋាន គណៈកម្មការទាំង១០
លេខាធិការដ្ឋានក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ
លេខាធិការដ្ឋាន គណៈកម្មការក្រម សីលធម៌
លេខាធិការដ្ឋាន អ្នកនាំពាក្យរបស់ព្រឹទ្ធសភា
អគ្គនាយកដ្ឋាន ស្រាវជ្រាវ
នាយកដ្ឋាន ស្រាវជ្រាវច្បាប់
នាយកដ្ឋាន ស្រាវជ្រាវទូទៅ
នាយកដ្ឋាន ស្រាវជ្រាវកិច្ចការសភា
នាយកដ្ឋាន ស្រាវជ្រាវថវិកា
អគ្គនាយកដ្ឋាន ពិធីការ និងទំនាក់ទំនង អន្តរជាតិ
នាយកដ្ឋាន ពិធីការ
នាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ
នាយកដ្ឋានស្រាវជ្រាវ កិច្ចការអន្តរជាតិ

# ឧបសម្ព័ន្ធទី២

# រចនាសម្ព័ន្ធគ្រប់គ្រងទីស្តីការគណៈរដ្ឋមន្ត្រី

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨



# រចនាសម្ព័ន្ធក្រសួងពាណិជ្ជកម្ម



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ :** ០៨ ប្រកត

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
## ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩

នៅព្រឹកថ្ងៃសុក្រ ១២រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

**១-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។**
**២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។**
**៣-បញ្ហាផ្សេងៗ៖** សេចក្តីប្រកាសរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការដាក់ឱ្យអនុវត្ត "យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥" និង "យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣"។

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

### ១-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានរៀបចំឡើងនៅក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជាបាននិងកំពុងទទួលផលពីសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ និងស្ថេរភាពនយោបាយ ដែលកើតចេញពីនយោបាយឈ្នះ-ឈ្នះ។ ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជានៅក្នុងរយៈពេលមធ្យមខាងមុខ ពោលគឺចាប់ពីពេលនេះរហូតដល់ឆ្នាំ២០២៥ គឺជាការបន្តកសាងនូវមូលដ្ឋានគ្រឹះមិនអាចខ្វះបានសម្រាប់ការឈានទៅសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៩ ត្រូវបានប៉ាន់ស្មានថាអាចសម្រេចបានកំណើន៧,១% ធៀបនឹង៧,៥% ក្នុងឆ្នាំ២០១៨។ ដោយឡែក កំណើននេះត្រូវបានព្យាករថានឹងថមថយមកក្នុងអត្រា៦,៥% ក្នុងឆ្នាំ២០២០ ដែលធ្វើឱ្យផ.ស.ស. ថ្លៃបច្ចុប្បន្នស្ថិតក្នុងរង្វង់ ១១៩ ០៣៤ប៊ីលានរៀល សមមូលនឹងប្រមាណ ២៩ ៣៦២លានដុល្លារអាម៉េរិកហើយផ.ស.ស. សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១ ៨១៦ដុល្លារអាមេរិក ធៀបនឹង ១ ៦៧៩ដុល្លារអាម៉េរិកក្នុងឆ្នាំ២០១៩។

ថវិកាឆ្នាំ២០២០ ត្រូវបានគិតគូរនិងរៀបចំឡើងដើម្បីទ្រទ្រង់ដល់និរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងចលនការនៃការកែទម្រង់ស៊ីជម្រៅនិងមុតស្រួច ដើម្បីពង្រឹងប្រព័ន្ធផ្ទៃក្នុងកម្ពុជា សំដៅពង្រឹងភាពធន់ម្ចាស់ទៅអនាគត ក៏ដូចជាត្រៀមខ្លួនទប់ទល់ និងផ្តល់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះរាល់បញ្ហាប្រឈមនិងហានិភ័យទាំងខាងក្នុងនិងខាងក្រៅប្រទេស។ លើសពីនេះទៅទៀត គឺដើម្បីសម្រេចឱ្យបាន

ជាអតិបរមានូវគោលដៅជាយុទ្ធសាស្រ្តទាំង៤ ដូចមានចែងក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព "កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០" ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ដែលរួមមាន៖ ទី១.-) ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំក្នុងរង្វង់៧% ប្រកបដោយចីរភាពនិងធន់នឹងវិបត្តិ ជាមួយនិងការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ទី២.-) បង្កើតការងារឱ្យបានកាន់តែច្រើនទាំងបរិមាណនិងគុណភាពជូនប្រជាជនកម្ពុជា ពិសេសសម្រាប់ស្រទាប់យុវជន ទី៣.-) សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ឱ្យស្ថិតនៅក្នុងអត្រាទាបជាង១០% និងការពារមិនឱ្យភាពក្រីក្រត្រឡប់មកវិញ និង ទី៤.-) បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ទន្ទឹមនឹងនេះ ថវិកាឆ្នាំ២០២០ ក៏បន្តផ្តោតការយកចិត្តទុកដាក់លើវិស័យអាទិភាព៤ គឺ **មនុស្ស ផ្លូវ ភ្លើង និងទឹក** ព្រមទាំងកិច្ចការមួយចំនួនទៀត ដែលឆ្លើយតបនឹងតម្រូវការអភិវឌ្ឍកម្ពុជានៅក្នុងដំណាក់កាលថ្មី ដែលរួមមាន៖ ទី១.-) ការអភិវឌ្ឍធនធានមនុស្ស ដោយនឹងបន្តផ្តោតលើការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងការបណ្តុះបណ្តាលជំនាញបច្ចេកទេស ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងការគាំពារសង្គម ទី២.-) ការបន្តកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល និងការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ ព្រមទាំងការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលនិងបដិវត្តន៍ឧស្សាហកម្មទី៤ ទី៣.-) ការពង្រឹងការប្រកួតប្រជែង និងការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ព្រមទាំងសហគ្រិនភាព ដើម្បីបង្កើនផលិតភាពនិងប្រសិទ្ធភាពសេដ្ឋកិច្ច និង ទី៤.-) ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ ការគ្រប់គ្រងនគរូបនីយកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ ព្រមទាំងការធានាចីរភាពបរិស្ថាន ក្នុងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។

ផ្អែកលើគោលការណ៍គ្រឹះជាយុទ្ធសាស្រ្តខាងលើ ក្របខណ្ឌថវិកាឆ្នាំ២០២០ ត្រូវបានកំណត់ដូចតទៅ៖

- ចំណូលថវិកាថ្នាក់ជាតិ៖ ត្រូវបានគ្រោងក្នុងចំនួន ៣០ ៣៩៥ ៨៥៥លានរៀល ក្នុងនោះចំណូលចរន្តថ្នាក់ជាតិ ត្រូវសម្រេចឱ្យបានចំនួន ២៣ ៨៩៩ ៣២៤លានរៀល ត្រូវជា២០,០៨%នៃផ.ស.ស. គឺមានកំណើន២២,០% ធៀបនឹងឆ្នាំ២០១៩ និង ចំណូលមូលធន ត្រូវបានគ្រោងចំនួន ៦ ៤៩៦ ៥៣១លានរៀល ត្រូវជា៥,៤៦%នៃផ.ស.ស. គឺមានកំណើន១២,៧% ធៀបនឹងឆ្នាំ២០១៩។

ក្របខណ្ឌថវិកាឆ្នាំ២០២០ មានគោលដៅបង្កើនចំណូលចរន្តថវិការដ្ឋ ឱ្យបានស្មើនឹង ២៩,៩៦% នៃផ.ស.ស. ដែលមានកំណើនចំនួន ២,៦៣ពិន្ទុភាគរយនៃផ.ស.ស. ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ ពោលគឺនឹងសម្រេចបានលើសគោលដៅនៃការប្រមូលចំណូលចរន្តថវិការដ្ឋ ដែលត្រូវបានកំណត់ឱ្យកើនជាមធ្យម ០,៣ពិន្ទុភាគរយនៃផ.ស.ស.ក្នុង១ឆ្នាំ នៅក្នុងយុទ្ធសាស្រ្តកៀរគរចំណូលឆ្នាំ ២០១៩-២០២៣។

ចំពោះចំណូលសារពើពន្ធ ត្រូវសម្រេចឱ្យបានចំនួន ២១ ០៩១ ១៤៥លានរៀល ត្រូវជា១៧,៧២% នៃផ.ស.ស. គឺមានកំណើន២៥,០% ធៀបនឹងច្បាប់ឆ្នាំ២០១៩ ដោយក្នុងនោះ៖

- ចំណូលគយនិងរដ្ឋាករ ត្រូវបានគ្រោងចំនួន ១១ ៦៤៦ ១៤៥លានរៀល ត្រូវជា៩,៧៨% នៃផ.ស.ស. គឺមានកំណើន២៨,១%ធៀបនឹងច្បាប់ឆ្នាំ២០១៩
- ចំណូលពន្ធដារ ត្រូវបានគ្រោងចំនួន ៩ ៤៤៥ ០០០លានរៀល ត្រូវជា៧,៩៣%នៃផ.ស.ស. គឺមានកំណើន២១,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៩ ក្នុងពេលដែលឆ្នាំ២០២០ រាជរដ្ឋាភិបាលមិនបានដាក់ចេញនូវប្រភេទពន្ធថ្មីឬបង្កើនអត្រាពន្ធនោះទេ។

- ចំណាយថវិកាថ្នាក់ជាតិ៖ ត្រូវបានគ្រោងក្នុងចំនួន ៣១ ០៩៥ ៨៥៥លានរៀល ក្នុងនោះចំណាយចរន្តថ្នាក់ជាតិ ត្រូវបានកំណត់ឱ្យបានស្ថិតក្នុងកម្រិតចំនួន ១៨ ០៣៦ ៨៨៤លានរៀល ត្រូវជា១៥,១៥% នៃផ.ស.ស. គឺមានកំណើន៧,២% ធៀបនឹងឆ្នាំ២០១៩ និង ចំណាយមូលធនថ្នាក់ជាតិ ត្រូវបានគ្រោងក្នុងចំនួន ១៣ ០៥៨ ៩៧១លានរៀល ត្រូវជា១០,៩៧%នៃផ.ស.ស. គឺមានកំណើន៤៦,១% ធៀបនឹងឆ្នាំ២០១៩។

Scanned with CamScanner

ចំពោះ ចំណាយបន្ទុកបុគ្គលិក ក្នុងឆ្នាំ២០២០ ដែលរួមមាន បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ លាភការ រង្វាន់ផ្សេងៗ និងប្រាក់វិភាជន៍សង្គមសម្រាប់ថ្នាក់ដឹកនាំនៃស្ថាប័នសាធារណៈ បុគ្គលិកក្របខណ្ឌ អចិន្ត្រៃយ៍ មន្ត្រីជាប់កិច្ចសន្យា ត្រូវបានគ្រោងចំនួន ៨ ៥៣៩ ៧៥២ លានរៀល សមាមាត្រនឹង៤៧,៣% នៃចំណាយចរន្តថ្នាក់ជាតិ ត្រូវជា៧,១៧%នៃផ.ស.ស. និងមានកំណើន៨,៦%ធៀបនឹងច្បាប់ឆ្នាំ២០១៩។

ក្នុងឆ្នាំ២០២០ បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ នឹងត្រូវបានដំឡើងដូចខាងក្រោម៖

- បៀវត្សមន្ត្រីរាជការស៊ីវិល៖ នឹងត្រូវបានដំឡើងពីប្រមាណ ១ ១០០ ១០០រៀល នៅឆ្នាំ២០១៩ ដល់ប្រមាណ ១ ១៤២ ៥០០រៀល នៅខែមករា ឆ្នាំ២០២០ ហើយចាប់ពីខែមេសា ឆ្នាំ២០២០ នឹងត្រូវដំឡើងដល់ប្រមាណ ១ ១៧២ ៥០០រៀល
- បៀវត្សគ្រូបង្រៀននិងគ្រូពេទ្យ៖ នឹងត្រូវបានដំឡើងពីប្រមាណ ១ ២០០ ១០០រៀល នៅឆ្នាំ២០១៩ ដល់ប្រមាណ ១ ២៤២ ៥០០រៀល នៅខែមករា ឆ្នាំ២០២០ ហើយចាប់ពីខែមេសា ឆ្នាំ២០២០ នឹងត្រូវដំឡើងដល់ប្រមាណ ១ ២៧២ ៥០០រៀល
- បៀវត្សនគរបាលជាតិ៖ (ពលបាលត្រី) នឹងត្រូវបានដំឡើងពីប្រមាណ ១ ១៨៤ ៥៧៧រៀល (គិតបញ្ចូលរបបអង្គរ) នៅឆ្នាំ២០១៩ ទៅប្រមាណ ១ ២២៦ ៩៧៧រៀល (គិតបញ្ចូលរបបអង្គរ) នៅខែមករា ឆ្នាំ២០២០ ហើយចាប់ពីខែមេសាឆ្នាំ២០២០ នឹងត្រូវឡើងដល់ប្រមាណ ១ ២៥៦ ៩៧៧រៀល (គិតបញ្ចូលរបបអង្គរ)
- បៀវត្សយោធិន៖ (ពលទោ) នឹងត្រូវបានដំឡើងពីប្រមាណ ១ ០៥៥ ៩០០រៀល នៅឆ្នាំ២០១៩ ដល់ប្រមាណ ១ ០៩៣ ៥០០រៀល នៅខែមករា ឆ្នាំ២០២០ (មិនគិតបញ្ចូលរបបអង្គរ) ហើយចាប់ពីខែមេសា ឆ្នាំ២០២០ នឹងត្រូវដំឡើងដល់ប្រមាណ ១ ១២៣ ៥០០រៀល (មិនគិតបញ្ចូលរបបអង្គរ) ហើយបើគិតបញ្ចូលរបបអង្គរត្រូវជាប្រមាណ ១ ១៨១ ៩៧៧រៀល។

លើសពីនេះ ប្រាក់បំណាច់របស់មន្ត្រីជាប់កិច្ចសន្យាក៏នឹងត្រូវដំឡើងពី ៦៥០ ០០០រៀល នៅឆ្នាំ២០១៩ ដល់ចំនួន ៦៧០ ០០០រៀល នៅឆ្នាំ២០២០ផងដែរ។

ទន្ទឹមនឹងការដំឡើងបៀវត្សជូនមន្ត្រីសាធារណៈ សម្រាប់ឆ្នាំ២០២០ រាជរដ្ឋាភិបាលបានគ្រោងថវិកាចំនួន ៨០ប៊ីលានរៀល ដោយឡែកផ្សេងទៀត សម្រាប់ផ្តល់លទ្ធភាពដល់ក្រសួងស្ថាប័នអាចជ្រើសរើសមន្ត្រីមានសមត្ថភាពនិងជំនាញខ្ពស់ចូលបម្រើការងាររដ្ឋ។ រាជរដ្ឋាភិបាល ក៏បានគ្រោងថវិកាចំនួន ៥០ប៊ីលានរៀល ជាមូលនិធិថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន និងបន្តគ្រោងថវិកាចំនួន ៦ប៊ីលានរៀល ដើម្បីទ្រទ្រង់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈផងដែរ។ បន្ថែមពីលើនេះ ចំពោះប្រាក់សោធននិវត្តន៍ក៏ត្រូវបានគ្រោងចំនួន៦០ប៊ីលានរៀល ហើយចំពោះការបើកប្រាក់សោធននិវត្តន៍ក៏នឹងបន្តធ្វើឡើងចំនួន២ដងក្នុងមួយខែតាមប្រព័ន្ធធនាគារផងដែរ។

ចំពោះ ចំណាយក្រៅបន្ទុកបុគ្គលិក ក្នុងឆ្នាំ២០២០ ត្រូវបានគ្រោងចំនួន ៩ ៤៩៧ ១៣២លានរៀល សមាមាត្រនឹង៥២,៧%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា៧,៩៨%នៃផ.ស.ស. និងមានកំណើន៥,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៩។ គួរបញ្ជាក់ថា ចំណាយចរន្តថ្នាក់ជាតិ ឆ្នាំ២០២០ ត្រូវបានវិភាជន៍តាមវិស័យគ្របដណ្តប់លើក្រសួងស្ថាប័នទាំង៣៩ ដែលរួមមាន៖

- វិស័យសង្គមកិច្ច ត្រូវបានគ្រោងថវិកាស្មើនឹង៣៧,៨% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា៥,៦៧% នៃផ.ស.ស. គឺមានកំណើន៨,៩% ធៀបនឹងឆ្នាំ២០១៩
- វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានគ្រោងថវិកាស្មើនឹង ២៥,៨% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា៣,៩២% នៃផ.ស.ស. គឺមានកំណើន៩,៣% ធៀបនឹងឆ្នាំ២០១៩
- វិស័យរដ្ឋបាលទូទៅ ត្រូវបានគ្រោងថវិកាស្មើនឹង១៣,០% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា១,៩៧% នៃផ.ស.ស. គឺមានកំណើន៤,៧% ធៀបនឹងឆ្នាំ២០១៩
- វិស័យសេដ្ឋកិច្ច ត្រូវបានគ្រោងថវិកាស្មើនឹង៨,៦% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា១,៣១% នៃផ.ស.ស. គឺមានកំណើន៣,៣% ធៀបនឹងឆ្នាំ២០១៩។

រាជរដ្ឋាភិបាលគ្រោងថវិកាចំនួន ១ ៦៣៦ ៩៩៨ លានរៀល ស្មើនឹង៩,១%នៃចំណាយចរន្តថ្នាក់ជាតិ ត្រូវជា១,៣៧%នៃផ.ស.ស. គឺមានកំណើន៥,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៩ ដើម្បី៖ បន្តលើកកម្ពស់គុណភាពនិង ពង្រីកសេវាសុខាភិបាល បន្តគាំទ្រកម្មវិធីមូលនិធិសមធម៌ក្នុងការផ្តល់សេវាសុខាភិបាលដោយឥតគិតថ្លៃ ជូនប្រជាពលរដ្ឋក្រីក្រ និងកម្មករនិយោជិតដែលមិនស្ថិតក្រោមប.ស.ស. ឧបត្ថម្ភកម្មការិនីក្រោយពេល សម្រាលកូន (សម្រាលកូនមួយទទួលបាន ៨០០ ០០០រៀល សម្រាលកូនភ្លោះពីរទទួលបាន ៨០០ ០០០រៀល និងសម្រាលកូនភ្លោះបីទទួលបាន ១ ២០០ ០០០រៀល) ឧបត្ថម្ភស្ត្រីក្រីក្រមានផ្ទៃពោះជា៣ដំណាក់កាល (ដំណាក់កាលទី១ ឧបត្ថម្ភចំនួន៤លើក ដោយក្នុង១លើកចំនួន៤ម៉ឺនរៀល នៅពេលទៅទទួលសេវាពិនិត្យ ផ្ទៃពោះនៅមណ្ឌលសុខភាពឬមន្ទីរពេទ្យរបស់រដ្ឋ, ដំណាក់កាលទី២ ឧបត្ថម្ភចំនួន២០ម៉ឺនរៀល នៅពេល សម្រាលកូននៅមណ្ឌលសុខភាពឬមន្ទីរពេទ្យរបស់រដ្ឋ, ដំណាក់កាលទី៣ ឧបត្ថម្ភចំនួន១០លើក ដោយក្នុង ១លើកចំនួន៤ម៉ឺនរៀល នៅពេលម្តាយនាំទារកទៅទទួលថ្នាំបង្ការឬសេវាគាំពារហូតដល់កុមារអាយុ២ឆ្នាំ)។

ចំពោះ ចំណាយថវិកាថ្នាក់ក្រោមជាតិ (ថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និង ឃុំ សង្កាត់) នៅឆ្នាំ២០២០ ត្រូវបង្កើនដល់ ៣ ៣២៩ ២៣៦លានរៀល ស្មើនឹង១០%នៃចំណាយថវិកាជាតិសរុប ដែល ត្រូវជា២,៨%នៃផ.ស.ស.។ បន្ថែមពីនេះ ការឧបត្ថម្ភរបស់រាជរដ្ឋាភិបាលលើគម្រោងចំណូល-ចំណាយរបស់ រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២០ មានការកើនឡើង៣៥,៧% ធៀបនឹងឆ្នាំ២០១៩ ដោយក្នុងនោះ ការឧបត្ថម្ភមូលនិធិក្រុង ស្រុក មានកំណើន២២,៤% ការឧបត្ថម្ភមូលនិធិឃុំ-សង្កាត់ មានកំណើន១៦% និង ការឧបត្ថម្ភមូលនិធិអភិវឌ្ឍឃុំ-សង្កាត់ មានកំណើន២២,៤% (កើនឡើងទ្វេដង ពីប្រមាណ ១៤២លានរៀល ឬសមមូល ៣៥ ០០០ដុល្លារអាមេរិកជាមធ្យមក្នុងមួយឆ្នាំ ទៅប្រមាណ ២៨៤លានរៀល ឬសមមូល ៧០ ០០០ ដុល្លារអាមេរិកជាមធ្យមក្នុងមួយឆ្នាំ)។

ចំពោះ ចំណូលចរន្តថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងឆ្នាំ២០២០ ត្រូវបានគ្រោងចំនួន ២ ២៤៣ ៧៧៨លានរៀល មានសមាមាត្រស្មើនឹង៨,៥៨%នៃចំណូលចរន្តថវិការដ្ឋ ត្រូវជា១,៨៨%នៃផ.ស.ស. មានកំណើន៦០,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៩។

ក្នុងឆ្នាំ២០២០ ប្រាក់បំណាច់របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ក៏ដូចជា ក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ នឹងត្រូវបានដំឡើងដូចខាងក្រោម៖

- ក្រុមប្រឹក្សារាជធានី ខេត្ត៖
  - ប្រាក់បំណាច់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត នឹងទទួលបានចំនួន ១ ៤៨០ ០០០រៀល
  - ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត នឹងទទួលបានចំនួន ១ ១៣៥ ០០០រៀល។
- ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ៖
  - ប្រាក់បំណាច់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នឹងទទួលបានចំនួន ១ ១៥៥ ០០០រៀល
  - ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នឹងទទួលបានចំនួន ៩១០ ០០០រៀល។
- ក្រុមប្រឹក្សាឃុំ សង្កាត់៖
  - ប្រាក់បំណាច់មេឃុំ ចៅសង្កាត់ នឹងទទួលបានចំនួន ១ ១១០ ០០០រៀល
  - ប្រាក់បំណាច់ជំទប់ទី១ ទី២ ចៅសង្កាត់រងទី១ ទី២ នឹងត្រូវបានដំឡើងពី ៨៥០ ០០០រៀល នៅឆ្នាំ២០១៩ ដល់ ៨៧០ ០០០រៀល នៅឆ្នាំ២០២០
  - ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នឹងត្រូវបានដំឡើងពី ៧៨០ ០០០រៀល នៅឆ្នាំ២០១៩ ដល់ ៧៦០ ០០០រៀល នៅឆ្នាំ២០២០
  - ប្រាក់បំណាច់មេភូមិ នឹងត្រូវបានដំឡើងពី ៤០០ ០០០រៀល នៅឆ្នាំ២០១៩ ដល់ ៤៣០ ០០០រៀល នៅឆ្នាំ២០២០
  - ប្រាក់បំណាច់អនុប្រធានភូមិ នឹងត្រូវបានដំឡើងពី ២៨០ ០០០រៀល នៅឆ្នាំ២០១៩ ដល់ ៣១០ ០០០រៀល នៅឆ្នាំ២០២០
  - ប្រាក់បំណាច់សមាជិកភូមិ នឹងត្រូវបានដំឡើងពី ២៥០ ០០០រៀល នៅឆ្នាំ២០១៩ ដល់ ២៨០ ០០០រៀល នៅឆ្នាំ២០២០។

ក្នុងក្របខណ្ឌថវិកាខាងលើ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលនឹងអាចរក្សាអតិរេកចរន្ត ឱ្យបានក្នុងកម្រិតប្រមាណ៥,៣១%នៃផ.ស.ស. នៅឆ្នាំ២០២០ ធៀបនឹងច្បាប់ឆ្នាំ២០១៩ ដែលមាន២,៨៤% នៃផ.ស.ស.។

ដើម្បីអនុវត្តគោលនយោបាយវិត្ថារកម្មថវិការបស់រាជរដ្ឋាភិបាល ក្នុងឆ្នាំ២០២០ ទំហំហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានអនុម័តឱ្យខ្ចីក្នុងកម្រិត ១,៨ប៊ីលានអេសដេអ៊ែ (SDR) ត្រូវជា៥,០៩%នៃផ.ស.ស. មូលនិធិទ្រទ្រង់ថវិកាគឺប្រមាណជា០,២១%នៃផ.ស.ស. និង ប្រាក់បញ្ញើរាជរដ្ឋាភិបាលគឺប្រមាណជា០,៥៩% នៃផ.ស.ស.(ស្មើនឹង៧០០ ០០០លានរៀល ឬសមមូល១៧៣លានដុល្លារអាមេរិក)។

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានរៀបចំឡើងដោយមាន ៧ជំពូក និង១៥មាត្រា រួមមាន៖ ជំពូកទី១ ថវិកាថ្នាក់ជាតិ ជំពូកទី២ ការខ្ចីនិងការធានារបស់រដ្ឋ ជំពូកទី៣ បទប្បញ្ញត្តិស្តីពីពន្ធដារ ជំពូកទី៤ និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ជំពូកទី៥ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ជំពូកទី៦ បទប្បញ្ញត្តិស្តីពីការធ្វើវិសោធនកម្មមាត្រា៨២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជំពូកទី៧ អវសានប្បញ្ញត្តិ និងឧបសម្ព័ន្ធ។

## ២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ គឺជាការឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។

ការអនុវត្តថវិកាឆ្នាំ២០១៨ បានរួមចំណែកដល់ការធានានូវនិរន្តរភាពនិងកិច្ចដំណើរការជាប្រក្រតីនៃស្ថាប័នរដ្ឋ ការរក្សាបាននូវសន្តិសុខ និងស្ថិរភាពនយោបាយ ក៏ដូចជាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលនាំឱ្យរាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលធំៗ ស្របតាមគោលដៅនៃរបៀបវារៈគោលនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍប្រទេសជាតិ និងការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

លទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០១៨ រួមមាន៖

- **ចំណូលថវិការដ្ឋ** (ថវិកាថ្នាក់ជាតិនិងថវិកាថ្នាក់ក្រោមជាតិ) ឆ្នាំ២០១៨ អនុវត្តបានចំនួន ២៧ ៦១៩ ៨៨៥,៨ លានរៀល ស្មើនឹង ២៧,៩៦%នៃផ.ស.ស. គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ១៨,៣% ដោយក្នុងនោះ៖ ចំណូលក្នុងប្រទេសអនុវត្តបានចំនួន ២២ ១១៨ ៥០២,២លានរៀល ស្មើនឹង២២,៣៩%នៃផ.ស.ស. គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ១៩,០% និងចំណូលមូលធនក្រៅប្រទេសអនុវត្តបានចំនួន ៤ ៦៤៩ ០០៤,១លានរៀល ស្មើនឹង ៤,៧១%នៃផ.ស.ស. គឺទាបជាងច្បាប់ហិរញ្ញវត្ថុ៣,១%។
- **ចំណាយថវិការដ្ឋ** (ថវិកាថ្នាក់ជាតិនិងថវិកាថ្នាក់ក្រោមជាតិ) ឆ្នាំ២០១៨ អនុវត្តបានចំនួន ២៤ ២៧៦ ៨០១ លានរៀល ស្មើនឹង ២៤,៥៨%នៃផ.ស.ស. គឺទាបជាងច្បាប់ហិរញ្ញវត្ថុ០,៥% ដោយក្នុងនោះ៖ ចំណាយចរន្តថវិការដ្ឋ (ថវិកាថ្នាក់ជាតិនិងថវិកាថ្នាក់ក្រោមជាតិ) អនុវត្តបានចំនួន ១៦ ២៧៧ ០៦៧,២លានរៀល ស្មើនឹង ១៦,៤៨%នៃផ.ស.ស. គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ២,៤%។

លទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០១៨ បានបង្ហាញឱ្យឃើញថារាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវសូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ ជាអាទិ៍៖ កំណើនសេដ្ឋកិច្ចសម្រេចបាន៧,៥%នៃផ.ស.ស. ធៀបនឹងការគ្រោងទុកគឺក្នុងរង្វង់៦,៩% ការកាត់បន្ថយភាពក្រីក្រនៅក្រោម១០% ផ.ស.ស. សម្រាប់មនុស្សម្នាក់សម្រេចបាន ១ ៥៤៨ដុល្លារអាម៉េរិក អតិផរណាជាមធ្យមប្រចាំឆ្នាំ២០១៨ មាន ២,៥% ធៀបនឹងការគ្រោងទុកគឺក្នុងរង្វង់៣,៥% អត្រាប្តូរប្រាក់ជាមធ្យម៤០៤៥រៀលក្នុង១ដុល្លារអាមេរិក ធៀបនឹងការគ្រោងទុក ៤០៣៧រៀល។ ចំពោះក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ កំណើនចំណូលចរន្តសរុបសម្រេចបាន១,៩៨ពិន្ទុភាគរយនៃផ.ស.ស. ធៀបនឹងគោលដៅ០,១៧ពិន្ទុភាគរយនៃផ.ស.ស.។ ដោយសារលទ្ធផលនៃការប្រមូលចំណូលបានខ្ពស់ និងការអនុវត្តចំណាយថវិកាប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលមិនត្រឹមតែពុំបានប្រើប្រាស់ប្រាក់សន្សំក្នុងបញ្ញើរាជរដ្ឋាភិបាលដែលគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៨ ចំនួន៩៩១,២ប៊ីលានរៀលប៉ុណ្ណោះទេ តែថែមទាំងសម្រេចបាននូវអតិរេកពីការអនុវត្តថវិកាក្នុងឆ្នាំសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ចំនួន ២ ៤៣៩,២ប៊ីលានរៀលទៀត ដែលត្រូវបានដាក់បង្កើនជាប្រាក់សន្សំបន្ថែម សម្រាប់រួមចំណែកគាំទ្រដល់ការអនុវត្តអាទិភាពគោលនយោបាយផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល។

សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានរៀបចំឡើង ដោយមាន៣ជំពូក និង២២មាត្រា រួមមាន៖ ជំពូកទី១ កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ ជំពូកទី២ កិច្ចប្រតិបត្តិការថវិកាថ្នាក់ក្រោមជាតិ ជំពូកទី៣ អវសានប្បញ្ញត្តិ និងឧបសម្ព័ន្ធ។

**៣-បញ្ហាផ្សេងៗ៖**

៣.១. សេចក្តីប្រកាសរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការដាក់ឱ្យអនុវត្ត "យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥" និង "យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣" មានខ្លឹមសារសង្ខេបជាអាទិ៍ដូចខាងក្រោម៖

យុទ្ធសាស្ត្រទាំងពីរនេះ ត្រូវបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបានដាក់ឆ្លងកិច្ចពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ជាបន្តបន្ទាប់ ហើយចុងក្រោយត្រូវបានដាក់ឆ្លងការពិនិត្យ ពិភាក្សា និងយល់ព្រម នៅក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការចំនួន២ដាច់ដោយឡែកពីគ្នា ដែលមានឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាប្រធាន គឺ៖ ១) គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ "យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥" និង ២) គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈសម្រាប់ "យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣"។

ក្នុងបរិការណ៍ថ្មីនៃសេដ្ឋកិច្ចកម្ពុជាដែលកាន់តែរីកលូតលាស់និងមានភាពស្មុគស្មាញជាងមុន រាជរដ្ឋាភិបាលសម្រេចដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រទាំងពីរនេះ សំដៅរួមចំណែកក្នុងការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការបន្តរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាពនិងបរិយាបន្ន ឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ជាប្រទេសមានចំណូលខ្ពស់ ដែលក្នុងនោះ៖

- យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥៖ បានដាក់ចេញនូវវិធានការបន្ទាន់ចំពោះមុខ និងវិធានការរយៈពេលមធ្យមមួយចំនួន សំដៅបង្កើតប្រព័ន្ធរួមមួយរបស់ជាតិ សម្រាប់ពង្រឹងការគ្រប់គ្រងការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន គ្រប់កម្រិតរដ្ឋបាលទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡា។ ជារួម ការឈានទៅបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិ នឹងធ្វើឱ្យមានការប្រែប្រួលសមត្ថកិច្ចការទទួលខុសត្រូវ និងរបៀបរបបបំពេញការងារមួយចំនួន ដែលចាំបាច់តម្រូវឱ្យក្រសួងស្ថាប័នពាក់ព័ន្ធត្រូវតែបុរេសកម្ម សកម្ម អន្តរសកម្ម និងម៉ឺងម៉ាត់ជាងមុន ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងចីរភាពនៃការវិនិយោគសាធារណៈ។ ក្នុងស្មារតីនេះ អភិក្រមនៃការអនុវត្តយុទ្ធសាស្ត្រនេះ ត្រូវធ្វើដោយ ប្រយ័ត្នប្រយែង សន្សឹមៗ ឈរលើគោលការណ៍ប្រាកដនិយម ទន់ភ្លន់ និង "រៀនផង-ធ្វើផង" ។

- យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣៖ បានដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រចំនួន១០ ហើយនៅតែបន្តអនុវត្តគោលការណ៍គន្លឹះនៃការគ្រប់គ្រងបំណុលសាធារណៈរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ទាំង៤ រួមមាន៖ ១.) ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកានិងសេដ្ឋកិច្ចអាចទ្រាំទ្របាន ២.) ខ្ចីតែឥណទានដែលមានកម្រិតសម្បទានឬលក្ខខណ្ឌអនុគ្រោះខ្ពស់ ៣.) ខ្ចីសម្រាប់តែវិស័យអាទិភាព ទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម និង ៤.) ប្រើប្រាស់ឥណទានប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត។ ទន្ទឹមនឹងនេះ ក្នុងបរិការណ៍ថ្មីរបស់កម្ពុជា សម្តេចតេជោនាយករដ្ឋមន្ត្រី បានបន្ថែមគោលការណ៍គន្លឹះទី៥មួយទៀត ដើម្បីបន្តពង្រឹងប្រសិទ្ធភាពទាំងការគ្រប់គ្រងបំណុលសាធារណៈ និងទាំងការគ្រប់គ្រងការវិនិយោគសាធារណៈ គឺ *«ប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវមានស្តង់ដារនិងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិក្នុងដំណាក់កាលថ្មី ពិសេសធានាបាននូវចីរភាពសេដ្ឋកិច្ច សង្គម បរិស្ថាន និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ»*។ ៧៥ ...

៣.២. សម្តេចតេជោនាយករដ្ឋមន្ត្រី បានលើកឡើងថា៖

- ក្នុងរយៈពេលរាជរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា គឺនៅបន្តអនុវត្តមិនយកពន្ធលើដីស្រែចម្ការរបស់ប្រជាពលរដ្ឋដែលធ្វើការបង្កបង្កើនផលជាលក្ខណៈគ្រួសារ និងមិនយកពន្ធលើប្រាក់បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ទោះបីប្រាក់បៀវត្សអប្បបរមានោះត្រូវបានដំឡើងដល់កម្រិតណាក៏ដោយ។ លើសពីនេះ ពិដាននៃពន្ធបៀវត្សអប្បបរមាត្រូវបានដំឡើងជារៀងរាល់ឆ្នាំ សំដៅឱ្យមន្ត្រីរាជការនិងកម្មករនិយោជិតដែលមានប្រាក់ខែទាបរួចផុតពីការជាប់ពន្ធ។ នៅឆ្នាំ២០២០ ពិដាននៃពន្ធបៀវត្សអប្បបរមានឹងត្រូវដំឡើងពី១លាន២សែនរៀល ដល់១លាន៣សែនរៀល។

- សម្តេចតេជោនាយករដ្ឋមន្ត្រី បានសម្រេចតាមសំណើរបស់អគ្គិសនីកម្ពុជាកាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ ដោយប្រកាសដកហូតសិទ្ធិប្រមូលសំរាមពីក្រុមហ៊ុនស៊ីនទ្រី និងដកថ្លៃសេវាប្រមូលសំរាមចេញពីវិក្កយបត្រថ្មីរបស់អគ្គិសនីកម្ពុជា ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ តទៅ។ ការកែសម្រួលវិក្កយបត្រអគ្គិសនីថ្មីនេះ ក៏ត្រូវអនុវត្តដូចគ្នាដែរចំពោះបណ្តាខេត្តដែលមានការភ្ជាប់ថ្លៃប្រមូលសំរាមនៅក្នុងវិក្កយបត្រអគ្គិសនីផងដែរ។ ការធ្វើដូចនេះជាការវះកាត់ជំងឺរ៉ាំរ៉ៃមួយ ដែលមិនត្រឹមតែឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋនោះទេ ប៉ុន្តែវាជាការចាំបាច់ដើម្បីកុំអោយបញ្ហាសំរាមក្លាយជាកត្តាដែលប្រជាពលរដ្ឋមើលមិនឃើញពីការវិវត្តជាវិជ្ជមាននៃការកែទម្រង់របស់អគ្គិសនីកម្ពុជា ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលបានខិតខំកែលម្អការផ្តល់សេវារួមទាំងបានបញ្ចុះថ្លៃអគ្គិសនីជាបន្តបន្ទាប់រួចហើយ។

- រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូនក្រសួងរ៉ែ និងថាមពល គិតគូរស្វែងរកការវិនិយោគបង្កើតរោងចក្រអគ្គិសនីដោយការដុតសំរាមនៅទីលានចាក់សំរាម និងមិនអនុញ្ញាតឱ្យមានការនាំចូលសំរាមពីក្រៅប្រទេសដើម្បីមកដំណើរការរោងចក្រផលិតអគ្គិសនីនេះឡើយ។

- សម្តេចតេជោនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ថា បច្ចុប្បន្នភូមិចំនួន៩២% ទូទាំងប្រទេសមានបណ្តាញអគ្គិសនីជាតិប្រើប្រាស់រួចហើយ រាជរដ្ឋាភិបាលនឹងបន្តមិនយកភាគលាភរយៈពេល៥ឆ្នាំបន្តទៀតពីអគ្គិសនីកម្ពុជា ដើម្បីយកថវិកានេះទៅវិនិយោគបន្ថែម ក្នុងការពង្រីកបណ្តាញអគ្គិសនីជាតិឱ្យបាន១០០% ដល់ភូមិទាំងអស់នៅទូទាំងប្រទេស។

- រាជរដ្ឋាភិបាលកម្ពុជា ស្វាគមន៍ចំពោះការលើកឡើងរបស់ ឯកឧត្តម W.Patrick Murphy ឯកអគ្គរដ្ឋទូតអាម៉េរិកថ្មីប្រចាំកម្ពុជា ដែលបានបញ្ជាក់ពីជំហរយ៉ាងច្បាស់លាស់របស់សហរដ្ឋអាម៉េរិកក្នុងការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ប្រទេសកម្ពុជា និងមិនគាំទ្រការផ្លាស់ប្តូររបបរដ្ឋាភិបាលតាមរយៈការប្រើអំពើហិង្សាឬសកម្មភាពផ្សេងណាមួយក្រៅពីតាមបែបប្រជាធិបតេយ្យ។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានលើកឡើងថា ទំនាក់ទំនងកម្ពុជានិងសហរដ្ឋអាម៉េរិកមិនមែនចាប់ផ្តើមពីចំណុចសូន្យនោះទេ គឺជាការបន្តនូវទំនាក់ទំនងល្អដែលធ្លាប់មានពីមុនមក។ ក្នុងបរិបទថ្មីដែលមាន ឯកឧត្តម W.Patrick Murphy ជាឯកអគ្គរដ្ឋទូតអាម៉េរិកប្រចាំកម្ពុជា សម្តេចតេជោនាយករដ្ឋមន្ត្រី បានណែនាំដល់គ្រប់ក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើសកម្មភាពឱ្យបានព្រមៗគ្នាក្នុងការខិតខំបន្តពង្រឹងនិងពង្រីកទំនាក់ទំនងល្អជាមួយសហរដ្ឋអាម៉េរិក មានជាអាទិ៍ ការសហការរៀបចំទិវាបុណ្យខួបលើកទី៧០ នៃទំនាក់ទំនងការទូតកម្ពុជា-អាម៉េរិក រៀបចំជាការសម្តែងសិល្បៈ កីឡា ការជួបជុំអតីតនិស្សិតធ្លាប់រៀននៅអាម៉េរិក បេសកកម្មរុករកអដ្ឋិធាតុទាហានអាម៉េរិកបាត់ខ្លួននៅកម្ពុជា និងកម្មវិធីភីសខប (Peace Corps) ដែលជាការងារលើកកម្ពស់មិត្តភាព សន្តិភាពអន្តរជាតិ តាមរយៈសេវាកម្មអ្នកស្ម័គ្រចិត្តអាម៉េរិក។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១២និង៥០នាទី។

ថ្ងៃសុក្រ ១២រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩

CS Scanned with CamScanner

# ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីលេខ [redacted]

ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១

# ដីកាកោះ

យើង [redacted] ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

អញ្ជើញ ឈ្មោះ [redacted] ភេទស្រី អាយុ៣៩ឆ្នាំ សញ្ជាតិខ្មែរ ជាដើមចោទ។

អាសយដ្ឋាន [redacted] នៅផ្ទះលេខ៥៣ ១ង ផ្លូវលំ ភូមិព្រែកតាសេក សង្កាត់ព្រែកតាសេក ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

[redacted] មកកាន់សាលាដំបូ [redacted] ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក(ជាន់ទី៤ [redacted]

ដើម្បីចូលរួម: នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

ពីដំណើររឿង: ប្ដឹងសុំសាលក្រមលែងលះ។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផងប្រសិនបើមាន។

ថ្ងៃសុក្រ ០៨រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១

ចៅក្រម

[redacted]

ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ២១៥
ថ្ងៃ: ពុធ ទី ២១ ខែ សីហា ឆ្នាំ ២០១៩
ម៉ោង: ១៥:០០

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៩/១៣០១

## ស្តីពី

## ការដាក់ឱ្យដំណើរការ
## សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ២.-**

សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ មានទីតាំងស្ថិតនៅខេត្តត្បូងឃ្មុំ។

**មាត្រា ៣.-**

សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ ត្រូវទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានារបស់ សាលាដំបូងខេត្តកំពង់ចាម និងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម សាលាដំបូងខេត្តកំពង់ធំ និងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ សាលាដំបូងខេត្តព្រះវិហារ និងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ សាលាដំបូងខេត្តក្រចេះ និងអយ្យការអមសាលាដំបូងខេត្តក្រចេះ សាលាដំបូងខេត្តស្ទឹងត្រែង និងអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង សាលាដំបូងខេត្តរតនគិរី និងអយ្យការអមសាលាដំបូងខេត្តរតនគិរី សាលាដំបូងខេត្តមណ្ឌលគិរី និងអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី សាលាដំបូងខេត្តព្រៃវែង និងអយ្យការអមសាលាដំបូងខេត្តព្រៃវែង សាលាដំបូងខេត្តស្វាយរៀង និងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង និងសាលាដំបូងខេត្តត្បូងឃ្មុំ និងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នស/រកត.១៩០៧.១៣១៥

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៩*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ៤១៣
ថ្ងៃ: ពុធ ទី ៣១ ខែ សីហា ឆ្នាំ ២០១៩
ម៉ោង: ១៥:០០

នស/រកត/០៨១៩/១៣០៤

## ស្តីពី
## ការដាក់ឱ្យដំណើរការ
## សាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

ROYAUME DU CAMBODGE

**មាត្រា ១.-**

ត្រូវបានដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់

សាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង មានទីតាំងស្ថិតនៅខេត្តបាត់ដំបង។

**មាត្រា ៣.-**

សាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង ត្រូវទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានារបស់ សាលាដំបូងខេត្តកំពង់ឆ្នាំង និងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង សាលាដំបូងខេត្តពោធិ៍សាត់ និងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ សាលាដំបូងខេត្តបាត់ដំបង និងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង សាលាដំបូងខេត្តប៉ៃលិន និងអយ្យការអមសាលាដំបូងខេត្តប៉ៃលិន សាលាដំបូងខេត្តបន្ទាយមានជ័យ និងអយ្យការអមសាលាដំបូងខេត្តបន្ទាយ-មានជ័យ សាលាដំបូងខេត្តឧត្តរមានជ័យ និងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ និងសាលាដំបូងខេត្តសៀមរាប និងអយ្យការអមសាលាដំបូងខេត្តសៀមរាប ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នស/រកត.០៨១៩.១៣១៦

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៩*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ៦១៧
ម៉ោង: ១៥:០០

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៩/១៣០៣

## ស្តីពី
## ការដាក់ឱ្យដំណើរការ
## សាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** ត្រូវបានដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ តទៅ។

សាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ មានទីតាំងស្ថិតនៅខេត្តព្រះសីហនុ។

**មាត្រា ៣.-**

សាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ ត្រូវទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានារបស់ សាលាដំបូងខេត្តតាកែវ និងអយ្យការអមសាលាដំបូងខេត្តតាកែវ សាលាដំបូងខេត្តកំពត និងអយ្យការអមសាលាដំបូងខេត្តកំពត សាលាដំបូងខេត្តកំពង់ស្ពឺ និងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ សាលាដំបូងខេត្តកោះកុង និងអយ្យការអមសាលាដំបូងខេត្តកោះកុង និងសាលាដំបូងខេត្តព្រះសីហនុ និងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

នស/រកត.១៩០៨.១៣១៧

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៩*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ២១៤
ថ្ងៃ: ...ខែសីហា ឆ្នាំ២០១៩
ម៉ោង: ១៥:០០

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៩/១៣០០

## ស្តីពី

## ការដាក់ឱ្យដំណើរការ
## សាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ១**

ត្រូវបានដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

សាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ មានទីតាំងស្ថិតនៅរាជធានីភ្នំពេញ។

**មាត្រា២.-**

សាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ត្រូវទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានារបស់ សាលាដំបូងរាជធានីភ្នំពេញ និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងសាលាដំបូងខេត្តកណ្តាល និងអយ្យការអមសាលាដំបូងខេត្តកណ្តាល ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ។

**មាត្រា៣.-**

សំណុំរឿងទាំងឡាយដែលសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ បានទទួលជាសមត្ថកិច្ច ត្រូវបន្តចាត់ការសំណុំរឿងទាំងអស់នោះ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្នុងករណីសាលាឧទ្ធរណ៍តំបន់ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ណាមួយ មិនទាន់អាចដំណើរការទៅបាន បណ្តឹងឧទ្ធរណ៍ក្នុងតំបន់នោះ ត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

**មាត្រា៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

នស/រកត.១៩០៥.១៣១៤

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៩*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

៤០/៦៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ[redacted]

ចុះថ្ងៃទី២៩-០៦-២០២០

សាលដីកា

លេខ:[redacted]

ចុះថ្ងៃទី១៦-១១-២០២០

# នាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាម ព្រះរាជក្រមលេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-៧-២០១៤ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០ ដោយមានសមាសភាព ដូចតទៅ:

<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ:</u>

លោកស្រី [redacted] ជាប្រធាន

ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted] ជាព្រះរាជអាជ្ញា

<u>ក្រឡាបញ្ជីសវនាការ</u>

លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងក្តីព្រហ្មទណ្ឌលេខ:៩៩១ ចុះថ្ងៃទី២៩-០៦-២០២០ ដែលមាន:

-ជនជាប់ចោទឈ្មោះ [redacted]ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ រៀនថ្នាក់ទី៦ មុខរបរបើកបរតាក់ស៊ី មានទីកន្លែងកំណើតភូមិព្រែកចង្ក្រាន ឃុំព្រែកចង្ក្រាន ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង និងលំនៅបច្ចុប្បន្នភូមិអន្លង់ស ឃុំរំលេច ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted]រ) ប្រពន្ធឈ្មោះ [redacted] ទោសពីមុនគ្មាន ។(ក្រៅឃុំ) (ប្តឹងឧទ្ធរណ៍)

<u>ជាប់ចោទពីបទ:</u> បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬ មិនគោរពកាតព្វកិច្ច បណ្តាលឱ្យ មានរបួសដល់អ្នកដទៃ និងស្លាប់ ប្រព្រឹត្តនៅភូមិត្រកៀក ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៣ និងមាត្រា៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] ភេទប្រុស អាយុ ៤០ឆ្នាំ មុខរបរកសិករ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិព្រៃគុយ ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។ (ប្ដឹងឧទ្ធរណ៍)

មានលោ[redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ។

**<u>អំពីអង្គហេតុ</u>**

កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល ១០ព្រឹក ជនជាប់ចោទឈ្មោះ[redacted] និង ម្ចាស់ឡានឈ្មោះ [redacted] ភេទប្រុស បានបើកឡានដើរប្រមូលយកភ្ញៀវតាមផ្ទះនៅភ្នំពេញ ។ ពេលប្រមូលភ្ញៀវ បានចំនួន ១៥នាក់ ជនជាប់ចោទក៏បានបើកឡានចេញមកតាមផ្លូវជាតិលេខ៦ កាត់ស្ពានព្រែកតាមាក់ ហើយឡើង មកផ្លូវជាតិលេខ៨ ។ ពេលជិះមកដល់ភូមិត្រកៀក ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ក៏ជួបគ្រោះថ្នាក់ចរាចរណ៍ ដោយមានម៉ូតូ ០១គ្រឿងម៉ាកសង់ C១២៥ ពណ៌ខ្មៅ ជិះរួមដំណើរ ០១នាក់ បើកបរបញ្ច្រាសទិសជាមួយជនជាប់ចោទ ពេលបើកមកដល់ចំណុចកើតហេតុបានប្ដូរគន្លងផ្លូវមកឆ្វេង ក៏ជ្រុលចង្កូតបណ្ដាលឱ្យរថយន្តម៉ាកសាំយ៉ុង ពណ៌បៃតង ពាក់ស្លាកលេខ ភ្នំពេញ 2V-6701 បើកពីកើតទៅលិចបានបុកម៉ូតូនោះតែម្ដង ។ ក្រោយកើតហេតុរួច អ្នកបើកបរបានគេចខ្លួនបាត់ ។ ករណីនេះបណ្ដាលឱ្យអ្នកបើកបរម៉ូតូស្លាប់ និងអ្នករួមដំណើររងរបួសធ្ងន់ រីឯវត្ថុតាងទាំង ០២ គ្រឿង សមត្ថកិច្ចយកមករក្សាទុកនៅអធិការនគរបាលស្រុកពារាំង ។

-បានឃើញ: សាលក្រមព្រហ្មទណ្ឌលេខ: [redacted]ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រៃវែង ដែលមានខ្លឹមសារដូចតទៅ:

១-ទណ្ឌកម្ម:

ផ្ដន្ទាទោសលើ:

-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ (សាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤,០០០,០០០ ៛ (បួនលានរៀល) ។

ពីបទ: បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬ មិនគោរពកាតព្វកិច្ចបណ្ដាលអោយមាន របួសដល់អ្នកដទៃ និងស្លាប់ ប្រព្រឹត្តនៅភូមិត្រកៀក ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៨៣ និងមាត្រា៨៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ។

២-អំពីវត្ថុតាងរួមមាន:

ក.រថយន្តម៉ាកសាំយ៉ុង ពណ៌សំបកឪឡឹក ពាក់ស្លាកលេខ (ភ្នំពេញ 2Y-6701) បែកចង្កៀងផ្នែកខាងឆ្វេង បាក់កាងមុខផ្នែកខាងឆ្វេង ដាច់កញ្ចក់មើលក្រោយខាងឆ្វេងចំនួន ០១គ្រឿង ។

ខ.ម៉ូតូម៉ាកហុងដា C125 ពណ៌ខ្មៅ ពាក់ស្លាកលេខ (ភ្នំពេញ 1AQ-6710) ខូចខាតទាំងស្រុងចំនួន ០១ គ្រឿង ដែលសព្វថ្ងៃរក្សាទុកនៅអធិការនគរបាលស្រុកពារាំង ត្រូវរឹបអូសប្រគល់អោយម្ចាស់ដើមវិញ ។

ចម្លើយរបស់ជនរងគ្រោះ ត្រង់ចំណុចនេះសូមឱ្យក្រុមប្រឹក្សាពិចារណា ។ តំណាងមហាអយ្យការស្នើសុំឱ្យក្រុមប្រឹក្សាពិនិត្យ និងសម្រេចតាមច្បាប់ ។

-មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ការពិភាក្សាដេញដោល និងការពិនិត្យភស្តុតាងក្នុងសំណុំរឿងឃើញថា ការសន្និដ្ឋានរបស់សមត្ថកិច្ចថាខាងម៉ូតូជាអ្នកខុស គឺមិនបានសួរសាក្សីដែលនៅកន្លែងកើតហេតុនោះទេ ។ ម្ចាស់រថយន្តឈ្មោះ[redacted]ានហៅជនជាប់ចោទឈ្មោះ [redacted]មកជួយបើកឡានក្នុងរដូវភ្ជុំបិណ្ឌ ដែលជនជាប់ចោទរូបមិនសូវបានបើកបរញឹកញាប់ទេ ហើយនៅរដូវភ្ជុំមានភ្ញៀវច្រើន រថយន្តតែងបើកបរលឿន ព្រោះប្រញាប់ដឹកភ្ញៀវ ។ សំណូមពរឱ្យក្រុមប្រឹក្សាផ្តន្ទាទោសជនជាប់ចោទឱ្យធ្ងន់ធ្ងរ ដើម្បីកុំឱ្យបើកបរគ្រោះថ្នាក់ដល់អ្នកដទៃផ្សេងទៀត និងសុំឱ្យក្រុមប្រឹក្សាសម្រេចឱ្យម្ចាស់ឡានចូលរួមសងសំណងក្នុងរឿងនេះ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យគ្រប់ឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវហើយ

## <u>សាលាឧទ្ធរណ៍ភ្នំពេញ</u>

## <u>យល់ឃើញថា</u>

១-បណ្តឹងឧទ្ធរណ៍លេខ: ០៥ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] និងបណ្តឹងឧទ្ធរណ៍លេខ: ២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: [redacted] "ក" ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រៃវែង ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ ផ្អែកតាមមាត្រា ៣៧៥, មាត្រា ៣៧៦ និងមាត្រា ៣៨២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានជាសមត្ថកិច្ច ។

២-ក្រោយកិច្ចពិភាក្សាដេញដោលនាពេលសវនាការ ក៏ដូចជាការពិនិត្យភស្តុតាងនៅក្នុងសំណុំរឿងឃើញថា៖ កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល ១០ព្រឹក ជនជាប់ចោទឈ្មោះ[redacted]និងម្ចាស់ឡានឈ្មោះ[redacted] ភេទប្រុស បានបើកឡានដើរប្រមូលយកភ្ញៀវតាមផ្ទះនៅភ្នំពេញ ពេលប្រមូលភ្ញៀវបានចំនួន ១៥ នាក់ ជនជាប់ចោទក៏បានបើកឡានចេញមកតាមផ្លូវជាតិលេខ៦ កាត់ស្ពានព្រែកតាមាក់ ហើយឡើង មកផ្លូវជាតិលេខ ៨ ។ ពេលជិះមកដល់ភូមិត្រកៀក ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ក៏ជួបគ្រោះថ្នាក់ចរាចរណ៍ ដោយមានម៉ូតូ ០១ គ្រឿងម៉ាកសង់ C១២៥ ពណ៌ខ្មៅ ជិះរួមដំណើរ ០១នាក់ បើកបរបញ្ច្រាសទិសជាមួយជនជាប់ចោទ ពេលបើកមកដល់ចំណុចកើតហេតុបានប្តូរគន្លងផ្លូវមកឆ្វេង ក៏ជ្រុលចង្កូតបណ្តាលឱ្យរថយន្តម៉ាកសាំយ៉ុង ពណ៌បៃតង ពាក់ស្លាក

លេខ ភ្នំពេញ 2V-6701 បើកពីកើតទៅលិចបានបុកម៉ូតូនោះតែម្តង ។ ក្រោយកើតហេតុរួច អ្នកបើកបរបានគេចខ្លួនបាត់ ។ ករណីនេះបណ្តាលឱ្យអ្នកបើកបរម៉ូតូស្លាប់ និងអ្នករួមដំណើររងរបួសធ្ងន់ រីឯវត្ថុតាងទាំង ០២ គ្រឿង សមត្ថកិច្ច យកមករក្សាទុកនៅអធិការដ្ឋាននគរបាលស្រុកពារាំង ។

៣-សកម្មភាពរបស់ជនជាប់ចោទជាទម្រង់មួយនៃអំពើដែលមានធាតុផ្សំនៃបទល្មើស និងភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទៈ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬ មិនគោរពតាមកាតព្វកិច្ចបណ្តាលឱ្យមានរបួសដល់អ្នកដទៃ និងស្លាប់ ដែលច្បាប់បានចែង និងតម្រូវឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៣ និងមាត្រា៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដូចមានចែងក្នុងសំអាងហេតុនៃសាលក្រមព្រហ្មទណ្ឌលេខៈ [redacted]“ក” ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រៃវែង ដែលសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បានឯកភាព ហេតុនេះសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍មិនលើកយកសំអាងហេតុដែលនេះមកធ្វើការបញ្ជាក់ជាថ្មីទៀតទេ ។

៤-នាពេលសវនាការសាលាឧទ្ធរណ៍ ជនជាប់ចោទឈ្មោះ [redacted] អវត្តមាន ប៉ុន្តែតាមចម្លើយនៅសាលាដំបូងបានឆ្លើយថា៖ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល ១០ព្រឹក ខ្លួន និងម្ចាស់ឡានឈ្មោះ [redacted] បានបើកឡានដើរប្រមូល យកភ្ញៀវតាមផ្ទះនៅភ្នំពេញ ។ ខ្លួនបានបើកឡាន កាត់ស្ពានព្រែកតាមាក់ ហើយឡើងមកផ្លូវជាតិលេខ៨ មកដល់ចំណុចភូមិត្រកៀត ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ក៏ជួបគ្រោះថ្នាក់ចរាចរណ៍ ដោយមានម៉ូតូ ០១គ្រឿង ម៉ាកសង់ C125 ពណ៌ខ្មៅ ជិះគ្នាពីរនាក់ បានបើកបញ្ច្រាសទិសគ្នា បើកវ៉ាកុងទីន័រមកបុកឡានខ្លួន ដែលកំពុងបើកបរលើគន្លងផ្លូវរបស់ខ្លួនបណ្តាលឱ្យម៉ូតូ ខ្ទាតទៅខាងកុងទីន័រ ឯមនុស្សខ្លួនមិនដឹងថាមានរបួសស្រាល ឬ ធ្ងន់ ឬ ស្លាប់ នោះទេ ខ្លួនដឹងតែពីរត់យករួចខ្លួនសិន ម៉ូតូបើកបុកពីខាងឆ្វេងរថយន្ត ខ្លួនបើកវេបមកកៀនបន្តិច ខ្លួនក៏រត់គេចខ្លួនសិន ដោយខ្លាចគេវាយ ។

៥-នាពេលសវនាការសាលាឧទ្ធរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនប្តឹងឧទ្ធរណ៍ព្រោះខ្លួនចំណាយច្រើនពេក គ្រាន់តែចំណាយបុណ្យសពខ្ទង់ចំនួន ៣០០០ ដុល្លារ ។ សាលាដំបូងបានសម្រេចឱ្យសងចំនួន ២០ លាននេះខ្លួនក៏យល់ព្រមទទួលដែរ ប្រសិនបើជនជាប់ចោទសងភ្លាមៗនៅពេលនោះ ប៉ុន្តែជនជាប់ចោទមិនបានសងទេ មកដល់សាលាឧទ្ធរណ៍ពេលនេះខ្លួនទាមទារសំណងសរុប ១ម៉ឺន ៥ ពាន់ដុល្លារ ។ កូនខ្លួនពេលគ្រោះថ្នាក់អាយុ ២០ ឆ្នាំ ធ្វើការជាសន្តិសុខ បានប្រាក់ខែ ២០០ ដុល្លារក្នុងមួយខែ ។ ខ្លួនសំណូមពរឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទធ្ងន់ជាងនេះ ។

៥-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមការពិនិត្យសំណុំរឿង និងស្តាប់ការពិភាក្សាដេញដោលក្នុងពេលសវនាការ តំណាងមហាអយ្យការយល់ឃើញថា ការចោទប្រកាន់ និងសម្រេចសេចក្តីឱ្យអ្នកបើកបរឡានខុស មិនត្រឹមត្រូវទេ ព្រោះអ្នកបើកបរឡានបើកបរក្នុងគន្លងរបស់ឡាន អ្នកបើកបរម៉ូតូទេ ដែលជិះម៉ូតូវ៉ារថយន្តធំចូលទៅក្នុងគន្លងរបស់ឡាន ក៏ប៉ះនឹងផ្នែកខាងឆ្វេងរថយន្តរបស់ជនជាប់ចោទបណ្តាលឱ្យគ្រោះថ្នាក់ ។ ក្នុងរឿងនេះមានចម្លើយផ្ទុយគ្នារវាងកំណត់ហេតុរបស់សមត្ថកិច្ច និងចម្លើយរបស់ជនរងគ្រោះ ត្រង់ចំណុចនេះសូមឱ្យក្រុមប្រឹក្សា

ពិចារណា ។ តំណាងមហាអយ្យការស្នើសុំឱ្យក្រុមប្រឹក្សាពិនិត្យ និងសម្រេចតាមច្បាប់ ។ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍នឹងពិចារណាចំពោះការលើកឡើងនេះ ។

៦-មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ការពិភាក្សាដេញដោល និងការពិនិត្យភស្តុតាងក្នុងសំណុំរឿងឃើញថា ការសន្និដ្ឋានរបស់សមត្ថកិច្ចថាខាងម៉ូតូជាអ្នកខុស គឺមិនបានសួរសាក្សីដែលនៅកន្លែងកើតហេតុនោះទេ ។ ម្ចាស់រថយន្តឈ្មោះ [redacted] បានហៅជនជាប់ចោទឈ្មោះ [redacted] មកជួយបើកឡានក្នុងរដូវភ្ជុំបិណ្ឌ ដែលជនជាប់ចោទរូបនេះមិនសូវបានបើកបរញឹកញាប់ទេ ហើយនៅរដូវភ្ជុំមានភ្ញៀវច្រើន រថយន្តតែងបើកបរលឿន ព្រោះប្រញាប់ដឹកភ្ញៀវ ។ សំណូមពរឱ្យក្រុមប្រឹក្សាផ្តន្ទាទោសជនជាប់ចោទឱ្យធ្ងន់ធ្ងរ ដើម្បីកុំឱ្យបើកបរគ្រោះថ្នាក់ដល់អ្នកដទៃផ្សេងទៀត និងសុំឱ្យក្រុមប្រឹក្សាសម្រេចឱ្យម្ចាស់ឡានចូលរួមសងសំណងក្នុងរឿងនេះ ។ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍នឹងពិចារណាចំពោះការលើកឡើងនេះ ។

៧-តាមរបាយការណ៍លេខ ២៩៧/២០១៧ របស់អធិការដ្ឋាននគរបាលស្រុកពារាំង បញ្ជាក់ថា ជនរងគ្រោះបើកបរក្នុងទិសដៅពីកើតទៅលិច លុះមកដល់កន្លែងកើតហេតុខាងលើបានប្តូរកន្លងផ្លូវមកខាងឆ្វេង ក៏បណ្តាលឱ្យបុករថយន្តបើកបរដោយជនជាប់ចោទឈ្មោះ [redacted] ក្នុងកន្លងអទិភាពរបស់រថយន្តនោះ ពុំបានបញ្ជាក់បង្ហាញលើល្បឿនបើកបររថយន្តរបស់ជនជាប់ចោទនោះទេ ។ ផ្អែកតាមការពិនិត្យគំនូសស្នាមគ្រោះថ្នាក់ចរាចរណ៍ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៧ របស់ការិយាល័យចរាចរផ្លូវគោក នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ឃើញថាម៉ូតូជនរងគ្រោះខ្ទាតចម្ងាយ ១៩ម៉ែត្រពីចំណុចបុក ដែលអាចសន្និដ្ឋានបានថាជនជាប់ចោទបើកបរក្នុងល្បឿនលឿនខ្វះការប្រុងប្រយ័ត្នគ្រប់គ្រងលើល្បឿនបើកបររបស់ខ្លួនស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីអាចបញ្ឈប់យានជំនិះបានទាន់ពេលវេលា និងដោយគ្មានគ្រោះថ្នាក់ ។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ ពីបទ៖ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬ មិនគោរពកាតព្វកិច្ចបណ្តាលអោយមាន របួសដល់អ្នកដទៃ និងស្លាប់ ប្រព្រឹត្តនៅភូមិត្រកៀក ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៣ និងមាត្រា៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

៩-សាលក្រមព្រហ្មទណ្ឌលេខ: [redacted] របស់សាលាដំបូងខេត្តព្រៃវែង បានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ហើយ គប្បីសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍សម្រេចតម្កល់ទុកជាបានការ ប៉ុន្តែដោយជនជាប់ចោទទើបប្រព្រឹត្តបទល្មើសលើកទី ១ គប្បីសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍សម្រេចព្យួរទោសធម្មតា តាមមាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១/ក-ទទួលបណ្តឹងឧទ្ធរណ៍លេខ: ០៥ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមច្បាប់ ។

ខ-ទទួលបណ្តឹងឧទ្ធរណ៍លេខ: ២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ នី ម៉េន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: [redacted] របស់សាលាដំបូងខេត្តព្រៃវែង ទុកជាបានការ លើកលែងតែចំណុចទី១ នៃសេចក្តីសម្រេច ត្រូវកែប្រែមកជាផ្តន្ទាទោសឈ្មោះ [redacted]ាក់ពន្ធនាគារកំណត់រយៈពេល ១ ឆ្នាំព្យួរធម្មតា និងពិន័យជាប្រាក់ចំនួន ២ លានរៀល ។

ចំណុចផ្សេងពីនេះនៃសេចក្តីសម្រេច ត្រូវរក្សាទុកជាបានការដដែល ។

សាលដីកានេះបានជំនុំជម្រះជាសាធារណៈ កាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ ។

ទុកសិទ្ធិប្តឹងតវ៉ាតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

# រចនាសម្ព័ន្ធសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា




រៀបចំចងក្រងដោយ លោក ឡោ ក្រឹម
រាជធានីភ្នំពេញ ឆ្នាំ២០១៨